# រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា

ព្រះបាទសម្ដេច ព្រះនរោត្តម - សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថបរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋឯករាជ្យ ជាភាគមួយក្នុងសហភាពបារាំង ក្នុងឋានៈជាសមាគតរដ្ឋ ។ ទ្រង់ប្រោសព្រះរាជទាន ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ក្នុងក្របខណ្ឌសីមានៃសន្ធិសញ្ញាទាំងឡាយ ដែលមានរវាងប្រទេសខ្មែរនឹងប្រទេសបារាំង នូវរដ្ឋធម្មនុញ្ញដូចមានសេចក្ដីតទៅនេះ ៖ ។

សេចក្ដីខាងលើនេះ ជាពាក្យលំនាំ ជាពាក្យប្រារព្ធ ឈ្មោះជាអារម្ភកថា, យើងអាចចែកសេចក្ដីនៃអារម្ភកថាជា ៣ ប្រការ ដើម្បីអធិប្បាយដោយឡែកពីគ្នា ។

ប្រការ ១.— ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ព្រះមេត្តាប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញ ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ។ ប្រែសេចក្ដីថារដ្ឋធម្មនុញ្ញ ជាព្រះរាជអំណោយនៃព្រះមហាក្សត្រិយ៍ មិនមែនរាស្ត្របានមកដោយការបះបោរ ដណ្ដើមអំណាចពីព្រះមហាក្សត្រិយ៍ដូចនៅប្រទេសបារាំង ដែលមានការបដិវត្តន៍ (révolution) ក្នុង គ.ស. ១៧៨៩ នោះទេ ។ ពាក្យ "ប្រជា-

រាស្ត្រ” បានដល់មនុស្សទាំងអស់គ្នា ដែលនៅក្នុងព្រះរាជអាណាចក្រ ទាំងរាស្ត្រ ទាំងនាម៉ឺន ទាំងក្សត្រិយ៍ វៀរតែជនបរទេស (étrangers, ជនជាតិក្រៅ)ដែលមកអាស្រ័យនៅក្នុងប្រទេសយើង ។

ប្រការ ២.– វគ្គទី ២ កំណត់ប្រភេទនៃសង្គមខ្មែរ ហើយ កំណត់ស្ថានភាព (situation) នៃសង្គមនេះ ចំពោះប្រទេសផ្សេង ៗ

ក) មនុស្សយើងមិនអាចនៅតែម្នាក់ឯងបានឡើយ, រមែងនៅរួមគ្នាជាសង្គម (société) ។ សង្គមមានច្រើនប្រភេទ៖ សង្គមតូចបំផុតគឺគ្រួសារ (famille, société conjugale) មានប្ដីប្រពន្ធនិងកូន ។ សង្គមធំជាងនេះ ហៅថាត្រកូល (famille,société domestique) មានញាតិសាច់សាលោហិតកប់បញ្ចូលផង ។ សង្គមធំទៅទៀតឈ្មោះ បក្ខសម្ព័ន្ធ (clan) ។ មនុស្សក្នុងបក្ខសម្ព័ន្ធនីមួយៗ ទុកខ្លួនជាតំណពីបុព្វបុគ្គលជាមួយគ្នា ។ បុព្វបុគ្គលនេះ តាមធម្មតា មិនមែនជាមនុស្សទេ ផ្សេងហៅថា តូតែម (totem) ។ មានតូតែមខ្លាឃ្មុំ តូតែមពីងពាង តូតែមក្រែង តូតែមខ្សាប់ ។ល។ បក្ខសម្ព័ន្ធសន្មតឈ្មោះតាមតូតែមជាបក្ខសម្ព័ន្ធខ្លាឃ្មុំ បក្ខសម្ព័ន្ធពីង-ពាង បក្ខសម្ព័ន្ធក្រែង ។ល។ បក្ខសម្ព័ន្ធបែបនេះ មានក្នុងពួក

មនុស្សស្បែកក្រហម នៅទ្វីបអាមេរិក, ក្នុងពួកមនុស្សព្រៃនៅប្រទេសយើងដូចពួកព្នង ក៏អាចមានការរួមគ្នាបែបបក្ខសម្ព័ន្ធខ្លះដែរ ។ មនុស្សក្នុងបក្ខសម្ពន្ធជាមួយគ្នានឹងផ្សំផ្គុំគ្នាជាប្ដីប្រពន្ធពុំបាន ។ នៅប្រទេសចិនមនុស្សដែលមានសែជាមួយគ្នា ក៏មានលក្ខណៈដូច្នេះដែរ ។ ត្រកូលផ្សេង ៗ អាចផ្គុំគ្នាជាស័ង្គមមួយមានមនុស្សកាប់ពាន់នាក់ នៅក្រោមបង្គាប់នាយចៅហ្វាយជាមួយគ្នា ហៅថាកុលសម្ព័ន្ធ (tribu) ដូចជាកុលសម្ព័ន្ធព្នង កុលសម្ព័ន្ធរ៉ាដែ កុលសម្ព័ន្ធជ្រាយ ។

ស័ង្គមតាំងប៉ុន្មានដែលបានពណ៌នាមកនេះ ច្រើនសំគាល់ចំពោះតែមនុស្ស មិនសំគាល់ដល់ទីដីដែលស័ង្គមនោះតាំងនៅផងទេ ស័ង្គមតាំងនោះអាចលែងនៅក្នុងទីកន្លែងមួយ លើកគ្នាទៅនៅក្នុងទីកន្លែងមួយទៀតបាន ដោយគង់នៅជាស័ង្គមដដែល ។ ស័ង្គមតូចៗអាចផ្គុំគ្នាជាស័ង្គមធំមួយ ដោយកាប់យកទីដីដែលតាំងនៅ មានព្រំជុំវិញជាសំគាល់ នៅក្រោមអំណាចតែមួយយ៉ាងដូចគ្នាហៅថាផែនដីឬប្រទេសមួយ ។ កាលបើមនុស្សដែលនៅក្នុងប្រទេសជាមួយគ្នានោះ មានចិត្តថ្លើមនឹងសេចក្ដីបំណងប្រហែលគ្នា (communauté de sentiments et de volontés) ដ៏ងខ្លួនជាខ្លួនរួមគ្នាជាបាច់

ជាដុំ ជាសង្គមតែមួយ (conscience collective) មានការគ្រប់គ្រងរៀបរយ ដោយចំពោះបំផុតមានតំណាងរដ្ឋាភិបាលមួយសម្រេចកិច្ចការរបស់ប្រទេស ។

សង្គមដែលមនុស្សតាំងនោះ រួមគ្នាតាំងឡើងជាប្រជាជាតិមួយ (nation) ។ តាមន័យរដ្ឋធម្មសាស្ត្រ (au point de vue du droit constitutionnel) មនុស្សតាំងឡាយដែលរួមគ្នាជាសង្គមមួយនៅក្រោមអំណាចរាជការតែមួយយ៉ាងដូចគ្នា ជាប្រជាជាតិមួយ ។

តាមន័យនយោបាយ គេអាចទុកប្រជាជាតិដូចជាមនុស្សម្នាក់ បេះមានទ្រព្យសម្បត្តិ បេះជំពាក់គេ បេះឲ្យគេជំពាក់ខ្លួន មានអំណាចបង្គាប់បញ្ជា ។ បុគ្គលនេះគ្មានរូបគ្មានអង្គទេ គេហៅថានីតិបុគ្គល (personne morale) ។ នីតិបុគ្គលនេះឈ្មោះជារដ្ឋ (Etat) ។

ដូចយើងបានឃើញមកនេះ សង្គមរបស់មនុស្សមានច្រើនប្រភេទច្រើនថ្នាក់ ។ តើសង្គមខ្មែរយើងនឹងត្រូវទុកជាសង្គមប្រភេទណា ? រដ្ឋធម្មនុញ្ញឆ្លើយថា ប្រទេសខ្មែរជារដ្ឋមួយ ។

១) ពាក្យថា "រដ្ឋ" មួយម៉ាត់នេះ ស៊ីសេចក្ដីថាអាណាចក្រនិងអំណាចបង្គាប់បញ្ជាទៅលើប្រជារាស្ត្រក្នុងអាណាចក្រនោះ ។ អំណាចដែលខ្ពស់បំផុតហៅថាអំណាចអធិបតេយ្យ (Souveraineté) ។

អំណាចអធិបតេយ្យមានពីរយ៉ាងគឺ  អំណាចអធិបតេយ្យខាងក្នុងអាណាចក្រក្នុងប្រទេស  និងអំណាចអធិបតេយ្យខាងក្រៅប្រទេស ។ រដ្ឋឯករាជ្យមានអំណាចអធិបតេយ្យទាំងពីរយ៉ាង ។ ប្រទេសកម្ពុជាជារដ្ឋឯករាជ្យ ប្រែសេចក្ដីថាប្រទេសកម្ពុជាមានអំណាចអធិបតេយ្យទាំងខាងក្នុងនិងខាងក្រៅប្រទេស ។

អ្វីដែលហៅថាសហភាពបារាំង (Union française)? តាមមាត្រា ៦០ នៃរដ្ឋធម្មនុញ្ញប្រទេសបារាំងថា ប្រទេសបារាំងនៅអឺរ៉ុប ខេត្តបារាំងនិងដែនដីបារាំងឯនាយសមុទ្រដែលបញ្ចូលគ្នាជាសាធារណរដ្ឋបារាំង (République française) នេះជាប៉ែកមួយ, ដែនដីសមាគតរដ្ឋ នេះជាប៉ែកមួយទៀត រួមគ្នាជាសហភាពបារាំង ។

— ខេត្ត (Département) បារាំងឯនាយសមុទ្រ បានដល់ដែនដីខ្លះដូចជាខេត្តអាល់ស៊េរី ខេត្តអ៊ូរ៉ង់ ខេត្តកុងស្តង់ទីន ខេត្តទាំងបីនេះរួមគ្នាជាប្រទេសអាល់ស៊េរី ។

— ដែនដីបារាំងឯនាយសមុទ្រ បានដល់អាណានិគម (Colonies) ផ្សេងៗ របស់បារាំង ដូចជាកោះឡារ៉េអ៊ុយនីញ៉ុង ដែនដីសេណេកាល ដែនដីប៉ុងឌីសេរី ជាដើម ។

— សមាគតរដ្ឋ គឺរដ្ឋដែលនៅក្នុងសហភាពបារាំង ។ សហ-

ឲ្យតែយូរលើសពី៣ខែ ។ កំណត់៣ខែនេះ ក៏ដូចជារបងកំពង់ឲ្យដើរហួសទៅតាមចិត្តមួយទៀត ។ សេចក្ដីឧបមាដូចជាស្រមោចមួយវារលើតុកក្ដារដែលមានក្រប ហើយត្រូវជាក់កំណត់ ឲ្យវារទៅណាបានតាំងអស់ កុំឲ្យតែហួសពីក្របក្ដារនោះ ។ ហេតុនេះទើបប្រើពាក្យ "ក្រប" (cadre) ។ ឬមួយដូចជាមនុស្សដែលត្រូវដើរបានតែក្នុងខេត្តដែនណាមួយ តែមិនឲ្យចេញពីព្រំដែន ឬខណ្ឌសីមា (limites) នៃខេត្តដែននោះ ។

ការប្រើរដ្ឋធម្មនុញ្ញ នៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញា នឹងប្រទេសបារាំង ប្រែសេចក្ដីថាសន្ធិសញ្ញាតាំងនោះ អាចជាក់គំរិតក្នុងការប្រើរដ្ឋធម្មនុញ្ញយើង ។ នេះជាការធម្មតានៃសន្ធិសញ្ញាដែលប្រទេសមួយធ្វើជាមួយនឹងប្រទេសមួយទៀត ។ ក្នុងមាត្រា២៦ នៃរដ្ឋធម្មនុញ្ញប្រទេសបារាំង ក៏មានបញ្ញត្តថា សន្ធិសញ្ញាដែលធ្វើជាមួយនឹងប្រទេសក្រៅ ហើយដែលបានទទួលសច្ចាប័នត្រឹមត្រូវហើយ ត្រូវប្រើដូចជាច្បាប់ បើទោះជាទាស់នឹងច្បាប់ក្នុងប្រទេសបារាំងក៏ដោយ ។

សន្ធិសញ្ញា (traité) គ.ស.១៨៦៣ នឹងអនុសញ្ញា (convention) គ.ស.១៨៨៤ ដែលយើងបានធ្វើជាមួយប្រទេសបារាំង ហើយ

ដែលតាំងប្រទេសយើង ក្នុងការអាណាព្យាបាលបារាំងនោះ បានលុបលាងចោលទៅហើយ ។ កិច្ចសញ្ញាតាំងឡាយដែលនៅប្រើរវាងបារាំងនិងខ្មែរសព្វថ្ងៃនេះ ជាកិច្ចសញ្ញាបណ្ដោះអាសន្នទាំងអស់ ។ យើងនឹងត្រូវធ្វើសន្ធិសញ្ញាពេញទីមួយ សម្រាប់ប្រើជួសកិច្ចសញ្ញាតាំងនោះ ។ ដោយហេតុដែលបានពោលមកខាងលើនេះ ការធ្វើសន្ធិសញ្ញាថ្មីនេះជាការសំខាន់ខ្លាំងណាស់ គួរនៅជាទីទាក់ចិត្តដល់ប្រជាជនខ្មែរទាំងឡាយពន់ពេក ។

## ជំពូក ១

# ធម្មជាតិនិងសណ្ឋានរបស់រដ្ឋ

មាត្រា ១.– ប្រទេសកម្ពុជា ជាប្រជាជាតិមួយ មានព្រះមហាក្សត្រិយ៍សោយរាជ្យ ។

សេចក្ដីអធិប្បាយ:

ក្នុងអារម្ភកថា មានសំដែងមកហើយថាប្រទេសកម្ពុជាជារដ្ឋមួយ តែរដ្ឋអាចមានធម្មជាតិនិងសណ្ឋានផ្សេងៗពីគ្នា ។

–ក្នុងរដ្ឋ អំណាចអធិបតេយ្យអាចនៅលើជនតែម្នាក់ គឺព្រះ

មហាក្សត្រិយ៍ ។ ធម្មជាតិនៃការគ្រប់គ្រងបែបនេះ ហៅថា រាជា-ធិបតេយ្យ (monarchie) ។

–ក្នុងរដ្ឋ អំណាចអធិបតេយ្យអាចនៅលើជនតែមួយពួកដែលខ្ពស់ជាងជនឯទៀតដោយជាតិកំណើត ។ ជនពួកនេះគេហៅថាអភិជន ( nobles ) ហើយធម្មជាតិនៃការគ្រប់គ្រងដោយអភិជនហៅថាអភិជនាធិបតេយ្យ (aristocratie) ។

–ក្នុងរដ្ឋ អំណាចអធិបតេយ្យអាចនៅលើប្រជារាស្ត្រទាំងពួងក្នុងប្រទេស ។ ធម្មជាតិនៃការគ្រប់គ្រងបែបនេះហៅថា ប្រជា-ធិបតេយ្យ (démocratie) ។

ក្នុងរបៀបរាជាធិបតេយ្យ ព្រះមហាក្សត្រិយ៍អាចទ្រង់ប្រើអំណាចអធិបតេយ្យរបស់រដ្ឋតាមទំនើងព្រះរាជហឫទ័យ ។ សណ្ឋាននៃរបៀបប្រជាធិបតេយ្យបែបនេះ ហៅថាសម្បូណ៌ាញ្ញាសិទ្ធិរាជ្យ(១) (monarchie absolue) ។

ក្នុងរបៀបប្រជាធិបតេយ្យ ព្រះរាជអំណាចនៃព្រះមហាក្សត្រិយ៍អាចមានកំណត់ដែលត្រាទុកក្នុងរដ្ឋធម្មនុញ្ញ ( monarchie constitutionnelle ) ។ យើងអាចហៅសណ្ឋាននៃរាជាធិបតេយ្យបែបនេះថា

(១) សម្បូណ៌ ប្រែថាពេញ, ពេញទី; "អាជ្ញា" ប្រែថាអំណាច ។

បរិមិតាជ្ញាសិទ្ធិរាជ្យ[២] (monarchie limitée) ។

ក្នុងរដ្ឋរាជាធិបតេយ្យ ព្រះមហាក្សត្រិយ៍គាប់ទ្រង់ព្រះរាជទានអធិបតេយ្យទៅឲ្យប្រជារាស្ត្រប្រើ ។ របៀបនេះជារបៀបប្រជាធិបតេយ្យមួយយ៉ាងដែរ ហៅថា រាជប្រជាធិបតេយ្យ (démocratie monarchique) នេះហើយជាធម្មជាតិនៃសណ្ឋានរបស់រដ្ឋយើង ។

ក្នុងរបៀបប្រជាធិបតេយ្យមួយយ៉ាងទៀត គ្មានព្រះមហាក្សត្រិយ៍សោយរាជ្យទេ ។ រដ្ឋបែបនេះឈ្មោះថា សាធារណរដ្ឋ ។ ឯរបៀបប្រជាធិបតេយ្យ សណ្ឋាននេះ ឈ្មោះថាសាធារណរដ្ឋប្រជាធិបតេយ្យ (démocratie républicaine) ។

មាត្រា ២.— ភាសាដែលប្រើជាផ្លូវការ គឺភាសាខ្មែរ ។ ភាសាបារាំងជាភាសាផ្លូវការ សម្រាប់ប្រើក្នុងការដែលទាក់ទងនឹងសហភាពបារាំងហើយនឹងយកមកប្រើក្នុងការក្រៅពីនោះផងក៏បានដែរ ទំរាំភាសាខ្មែរមានពាក្យបរិបូណ៌គ្រប់គ្រាន់នឹងប្រើការសម្រាប់ប្រជាជាតិសម័យថ្មី ។

សេចក្តីអធិប្បាយ :

១.— មុននឹងអធិប្បាយសេចក្តីនៃមាត្រានេះ យើងគួរពិនិត្យ

---

(២) “បរិមិត” ប្រែថាមានកំណត់, មានរង្វាស់រង្វាល់; “អាជ្ញា” ប្រែថាអំណាច ។

ពាក្យ "ផ្លូវការ" ដែលជាពាក្យមិនសូវធ្លាប់ប្រើពីដើមមក ។ ពាក្យ "ផ្លូវការ" (officiel) នឹងប្រែថា "ផ្លូវរាជការ" ក៏បាន តែពាក្យ "ផ្លូវការ" មានសេចក្ដីធំទូលាយទៅទៀត ។ "ភាសាផ្លូវការ" អាចប្រែថា "ភាសាដែលយកជាការ" ។ "ដណ្ដឹងកូនគេជាផ្លូវការ" គឺមានចាស់ទុំទៅនិយាយត្រឹមត្រូវពេញមុខ បើគ្រាន់តែនិយាយ "លេងៗ" មិនរាប់ថាដណ្ដឹងជាផ្លូវការទេ ។

២–សេចក្ដីក្នុងមាត្រានេះ អាចចែកជាបីភាគ ។

ក) សម្រាប់កិច្ចការក្នុងប្រទេស ទោះជាការរាជការក្ដី ទោះជាការក្រៅរាជការក្ដី (ដូចជាធ្វើសំបុត្រសញ្ញាលក់ដូរដួលព័ទ្ធជាដើម) ត្រូវប្រើភាសាខ្មែរ ជាភាសាផ្លូវការ ។

ខ) សម្រាប់កិច្ចការដែលទាក់ទងនឹងរាជការបារាំងក្នុងប្រទេសខ្មែរក្ដី ក្រៅប្រទេសខ្មែរក្ដី សម្រាប់ការទាក់ទងនឹងប្រទេសឯទៀត ដូចជាប្រទេសយួន-លាវ-ម៉ាដាកាស្កា អាល់ស៊េរី ។ល។ ដែលនៅក្នុងសហភាពបារាំងជាមួយគ្នា នោះត្រូវប្រើភាសាបារាំងជាភាសាផ្លូវការ ។

គ) ភាគទាំងពីរខាងលើនេះ ចែកមុខគ្នាជ្រះស្រឡះល្អណាស់ តែខ្មែរបានធ្វេសក្នុងការប្រើភាសាខ្មែរមកជាយូរហើយ ភាសាខ្មែរ

គ្មានពាក្យគ្រប់គ្រាន់សម្រាប់ប្រើការ នឹងយកបទបញ្ញត្តិក្នុងភាគទាំងពីរខាងលើនេះមកប្រើតាមពុំបានស្រួល អាចនាំឲ្យរដើបរដួលក្នុងការប្រតិបត្តិ ដែលរត់ដូន្តមកយូរហើយ ។ ដូច្នេះទើបមានសេចក្ដីក្នុងភាគ (គ) នេះជាអន្តរបញ្ញត្តិ (disposition transitoire) សម្រាប់ប្រើបណ្ដោះអាសន្ន ។ អន្តរបញ្ញត្តិនេះមានសេចក្ដីថា នឹងយកភាសាបារាំងមកប្រើជាផ្លូវការជួសភាសាខ្មែរក៏បានដែរ ។

ការប្រើភាសាបារាំងជាផ្លូវការជួសភាសាខ្មែរ សម្រាប់កិច្ចការរវាងខ្មែរនឹងខ្មែរ នឹងប្រើរហូតទៅឬដូចម្ដេច? រដ្ឋធម្មនុញ្ញឆ្លើយថា អាចប្រើដរាបទៅ លុះត្រាតែភាសាខ្មែរមានពាក្យបរិបូណ៌គ្រប់គ្រាន់នឹងប្រើការ ។

គួរសង្កេតថា រដ្ឋធម្មនុញ្ញគ្រាន់តែបញ្ញត្តថា យើងអាចយកភាសាបារាំងមកប្រើជួសភាសាខ្មែរក្នុងការទាក់ទងរវាងខ្មែរនឹងខ្មែរតែប៉ុណ្ណោះ មិនមែនបញ្ញត្តថា ត្រូវយកមកប្រើទេ ។ ការយកមកប្រើឬទេ ស្រេចតែចិត្តយើង ។ ទើបកើតជាបញ្ហាថា យើងនឹងខំប្រឹងប្រើភាសាយើងក្នុងកាលគ្រប់ឱកាសដែលអាចនឹងធ្វើបាន ដើម្បីនឹងឲ្យភាសាយើងបានលូតលាស់ដោយស្រួលកាន់តែទាន់សម័យនឹងគេឬទេ? យើងសង្ឃឹមថា ខ្មែរគ្រប់គ្នានឹងព្យាយាមឆ្លើយបញ្ហានេះ ដោយការប្រព្រឹត្តិ

របស់ខ្លួនផងមិនខាន ។

## ជំពូក ២

# សេរីភាព - សិទ្ធិ និងករណីយកិច្ចរបស់ខេមរជន

ដូចមានពោលមកហើយ បុគ្គលរាប់សែនរាប់លាននាក់រួមគ្នាតាំងឡើងជារដ្ឋ ៗ រដ្ឋ (ឬរាជការ) មានអំណាចបង្គាប់បញ្ជាផ្ដន្ទាទោសលើបុគ្គលទីមួយៗ (ឬរាស្ត្រ) ។ អំណាចនេះខ្លាំងណាស់ ធំលើសម្បត្តិទ្រព្យរាងកាយរហូតដល់អាយុជីវិតនៃបុគ្គលទីមួយ ៗ ។ ទាំងនេះក៏ព្រោះជាប្រយោជន៍ដល់បុគ្គលទាំងអស់គ្នា ដូចជាការចាប់ចោរដាក់គុក រឹបជាន់សម្បត្តិទ្រព្យ ប្រហារជីវិតមនុស្សក្បត់ជាតិជាដើម ៗ តែរដ្ឋអាចប្រើអំណាចរំលោភលើបុគ្គលទីមួយៗដូចយើងធ្លាប់បានឃើញមកហើយ ។ ហេតុនេះទើបរដ្ឋធម្មនុញ្ញបញ្ញត្តកុំឲ្យរដ្ឋប្រើអំណាចជ្រុលហួសទៅលើបុគ្គលបាន ។

ក្នុងចំពូកនេះ និងក្នុងចំពូក ៣ ត្រង់មាត្រា ១៧ និង ១៨ មានស្រដីអំពីសេរីភាព (liberté) និងសមភាព (égalité) របស់ខេមរជន ។ គោលសេរីភាពនិងគោលសមភាព (les principes de liberté et d'égalité) ជាមូលដ្ឋាន (base) នៃសិទ្ធិរបស់បុគ្គល

(droits individuels) ។ សិទ្ធិរបស់បុគ្គលនេះ រដ្ឋមិនត្រូវល្មើសបាន

ឡើយ ។

ក្នុងចំពូកនេះ មានស្រដីអំពីករណីយកិច្ច របស់ខេមរជនផង

ព្រោះថាកាលបើមានសិទ្ធិ ក៏ត្រូវមានករណីយកិច្ចជាគូគ្នា ។

មាត្រា ៣.– សេរីភាពជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាង កុំឲ្យតែប៉ះពាល់

ឡូខូចសិទ្ធិអ្នកដទៃ ។ លក្ខខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបាន

ឡើយ ។

សេចក្ដីអធិប្បាយ.– មានសេរីភាព គឺធ្វើអ្វីក៏បាន តែ

ក៏មិនមែនតែបានដកបណ្ដោយទេ ត្រូវមានកំណត់ដែរ ។ ឧបមាដូចជា

ខ្ញុំចង់ស្រែកច្រៀង ខ្ញុំមានសេរីភាពស្រែកច្រៀងដូចម្ដេចក៏បាន ។

ប៉ុន្តែបើដល់ពេលយប់ជ្រៅ ខ្ញុំស្រែកច្រៀងខ្លាំងៗ ពេលអ្នករកសម្រាន្ត

ពុំលក់ ។ អ្នកមានសិទ្ធិសម្រាន្តពេលយប់ ។ បើខ្ញុំច្រៀងមិនឲ្យអ្នក

សម្រាន្តបាន នោះគឺខ្ញុំធ្វើឲ្យខូចសិទ្ធិរបស់អ្នកសម្រាន្តសម្រាកកាយ ។

ក្នុងករណីដូច្នេះ (dans ce cas) សេរីភាពរបស់ខ្ញុំកស់តែត្រឹមនេះ ។

នេះហើយជាព្រំដែននៃសេរីភាព ។ «លក្ខខណ្ឌនៃការប្រើសេរីភាពមានត្រា

ទុកក្នុងច្បាប់" ប្រែសេចក្ដីថា ការប្រើសេរីភាពទៅដោយវិធីណា តាមបែបណាខ្លះ នោះមានបញ្ញត្តិទុកក្នុងច្បាប់ ។ ដូចជាសេរីភាពខាងការធ្វើការសែត, ដើម្បីនឹងប្រើសេរីភាពនេះបាន ត្រូវឲ្យមានអ្នកចាត់-ការម្នាក់ជាអ្នកទទួលខុសត្រូវ អ្នកចាត់ការនោះត្រូវធ្វើពាក្យទៅដំរាបអ្នករាជការមុខក្រសួង ។ល។ នេះហើយហៅថាលក្ខខណ្ឌនៃការប្រើសេរីភាពខាងការធ្វើការសែត ។ លក្ខខណ្ឌទាំងនេះ មានត្រាទុកក្នុងច្បាប់ ។ បើច្បាប់នេះមិនទាន់មាន ក៏ត្រូវតាំងឲ្យមានឡើង ។

វគ្គទី២នៃមាត្រា ៣នេះ មានសេចក្ដីថា៖ "អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ" ។ សេចក្ដីនេះក៏ក្បោះក្បាយល្មមស្ដាប់បានហើយ តែដើម្បីឲ្យច្បាស់លាស់ឡើងទៀតគួរយើងរកឧទាហរណ៍មួយមកបញ្ជាក់ថែមផង ។ មនុស្សដែលដើរកាត់មុខវត្តអារាម ខ្លះក៏បើកមួក ខ្លះក៏មិនបើកមួក ការបើកមួកនៅមុខវត្តនេះ គ្មានច្បាប់ណាបង្គាប់ឲ្យធ្វើទេ គឺធ្វើដោយចិត្តឯង ។ ហេតុនេះ នរណានឹងបង្ខំនរណាឲ្យបើកមួកនៅមុខវត្តពុំបានឡើយ ។

មាត្រា ៤.— នឹងចោទចាប់ឬឃុំឃាំងជនណាមួយបាន លុះតែជននោះ

ប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់, ឯអ្នកចោទអ្នកចាប់ឬអ្នកឃុំឃាំង ត្រូវប្រព្រឹត្តតាមរបៀបដែលច្បាប់បានបញ្ញត្តទុក ។

នឹងឃុំឃាំងជនណាទុកបាន លុះត្រាតែមានចៅក្រមពិនិត្យការឃុំឃាំងនោះឃើញថាត្រឹមត្រូវតាមច្បាប់ហើយយល់ព្រមផង ដោយចង្អុលហេតុផលក្នុងរយៈវេលាដែលមានកំណត់ទុកក្នុងច្បាប់ ។

ទារុណកម្ម ឬការបង្ខំដែលឥតប្រយោជន៍ក្នុងខណៈចាប់ជនណាមួយ, ការសង្កត់សង្កិនចិត្ត ឬការធ្វើបាបដល់រាងកាយចំពោះអ្នកជាប់ឃុំណាមួយ, ការប្រព្រឹត្តដែលបណ្តាលឲ្យធ្ងន់ថែមទៅលើទណ្ឌកម្ម ដែលតុលាការបានតម្រូវតាមច្បាប់ទៅលើអ្នកមានទោសណាមួយស្រេចហើយ នោះច្បាប់ហាមមិនឲ្យប្រព្រឹត្ត ហើយក្នុងបទទាំងនេះ អ្នកដែនដល់ អ្នកមេគំនិតឬអ្នកសមគំនិត ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ។

*សេចក្តីអធិប្បាយ.— មាត្រានេះស្តីអំពីសេរីភាពខាងរាងកាយ*(១) *( liberté individuelle)។ សេរីភាពខាងរាងកាយគឺសេរីភាពនៃបុគ្គលគ្រប់រូប ដែលនឹងបិតនៅឬទៅណាមកណាបាន ដោយឥតនរណាអាចមកឃាត់ហាមបានឡើយ ។*

*សេចក្តីក្នុងមាត្រានេះមាន ៣ វគ្គ ។ យើងនឹងនាំមកអធិប្បាយមួយវគ្គម្តងៗ ។*

*វគ្គ* ទី១.— នឹងចោទ-ចាប់ឬឃុំឃាំងជនណាបាន លុះតែជននោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់ ឯអ្នកចោទ-អ្នកចាប់ឬអ្នកឃុំឃាំង ត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តទុក ។

---

(១) សេរីភាពខាងរាងកាយនេះ មានស្រដីក្នុងមាត្រា ៥-៦ នឹង ១១ ទៀតផង ។

សេចក្តីនេះ នាំឱ្យកើតឡើងជាបញ្ហា ៥ ប្រការ គឺៈ

១) បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះដូចម្តេចខ្លះ ?

២) នរណាជាអ្នកចោទ ?

៣) នរណាមានអំណាចចាប់ ? ដើម្បីនឹងចាប់ ត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ?

៤) នរណាមានអំណាចឃុំឃាំង ? ដើម្បីនឹងឃុំឃាំង ត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ?

៥) នរណាចាប់ឬឃុំឃាំងខុសពីច្បាប់ ត្រូវទទួលទោសយ៉ាងណាខ្លះ ?

យើងបានពិនិត្យច្បាប់ដែលមានប្រើសព្វថ្ងៃនេះ ហើយបានប្រឹក្សានឹងអ្នកច្បាប់ការក្នុងមុខក្រសួងតុលាការ ដោយចង់ដឹងថាច្បាប់ដែលមានប្រើសព្វថ្ងៃ ឱ្យសេចក្តីឃុំគ្រងរក្សាដល់សេរីភាពខាងកាយនៃខេមរជនប៉ុនណាទៅ ។ ទាំងនេះក៏ព្រោះយើងមានបំណងឲ្យបងប្អូនទាំងឡាយ ចេះប្រើបញ្ញត្តិច្បាប់ជាអាវុធការពារខ្លួន វៀរចាកការសង្កត់សង្កិនធ្វើបាប ដើម្បីឱ្យបានគ្រងជីវិតដោយថ្លៃថ្នូរសមល្មមនឹងឋានៈជាមនុស្សតទៅ ។ ដើម្បីឱ្យសាមញ្ញជនយល់បានដោយច្បាស់ហាស់នោះ ត្រូវពន្យល់ដល់ខ្ចប់ល្អិតណាស់ ។

បើនឹងពន្យល់ឲ្យល្អិតដល់ម៉្លោះ ក្នុងទីនេះពុំបានទេ ព្រោះនឹងនាំឲ្យសេចក្តីអធិប្បាយវែងពេក ។ យើងនឹងព្យាយាមសង្ខេបយ៉ាងបំផុត តែកំគង់នៅវែងមិនតិចដែរ ។

ប្រការ ១.– បទប្រព្រឹត្តដែលមានទោសក្នុងច្បាប់នោះដូចម្តេចខ្លះ?

បទប្រព្រឹត្តទាំងនោះ ជាបទល្មើស ដែលគេតែងចែកជាបីស្ថាន គឺបទឧក្រិដ្ឋ បទមជ្ឈិម នឹងបទលហុ ស្រេចតែទោសដែលត្រូវផ្តន្ទាជាទោសឧក្រិដ្ឋ (ធ្ងន់), មជ្ឈិម (កណ្តាល), ឬលហុ (ស្រាល) ។

បទឧក្រិដ្ឋជាបទល្មើសដែលត្រូវផ្តន្ទាទោស៖

– ប្រហារជីវិត (ថ្នាក់ទី៣)

– ដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត (ថ្នាក់ទី២)

– ឬដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់កំណត់វេលា (ថ្នាក់ទី១)

(មាត្រា២១ ក្រមព្រហ្មទណ្ឌ) ។

បទមជ្ឈិមជាបទល្មើសដែលត្រូវផ្តន្ទាទោស ៖

– ដាក់គុកពី ១ ឆ្នាំទៅដល់ ៥ ឆ្នាំ ហើយពិន័យពី ១០០៛ ទៅដល់១.០០០៛ (ថ្នាក់ទី៣) ។

-ដាក់គុកពី ១ ខែ ទៅដល់ ១ ឆ្នាំ និងពិន័យពី ៣០៛ , ទៅដល់ ១០០៛ (ថ្នាក់ទី២) ។ ឬ

-ដាក់គុកពី ៦ ថ្ងៃ ទៅដល់ ១ ខែ និងពិន័យពី ៦៛ ទៅដល់ ៣០៛ (ថ្នាក់ទី ១) ។

ទោសមជ្ឈិមទាំង ៣ ថ្នាក់នេះ គ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន (មាត្រា ២២ ក.ព.) ។

បទលហុជាបទល្មើសដែលត្រូវផ្តន្ទាទោស ដាក់គុកពី ១ ថ្ងៃ ទៅដល់ ៥ ថ្ងៃ និងពិន័យពី ៤០ស ទៅដល់ ៥៛ ឬគ្រាន់តែដាក់គុក ឬគ្រាន់តែពិន័យក៏បាន (មាត្រា ២៣ ក.ព.) ។

បើជនណាមិនបានប្រព្រឹត្តបទល្មើស ដែលមានត្រាទុកក្នុងច្បាប់នេះទេ គ្មាននរណាអាចចោទ-ចាប់ ឬ ឃុំឃាំងជននោះបានឡើយ ។ ជនណាចោទ-ចាប់ ឬឃុំឃាំងមនុស្សដែលពុំបានប្រព្រឹត្តបទ ដែលមានត្រាទុកក្នុងច្បាប់ ជននោះធ្វើខុសនឹងច្បាប់ហើយត្រូវទទួលទោសលើខ្លួន ដូចនឹងមានពណ៌នាទៅខាងក្រោមនេះ ។

ប្រការ ២- នរណាជាអ្នកចោទ ?

តាមធម្មតា កាលបើមានបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិមបណ្តាលកើតឡើង អ្នករងគ្រោះ ឬជនឯទៀត អាចប្តឹងជាបទអាជ្ញា

ផ្ទាន ។ តែដែលនឹងចោទប្រកាន់ឲ្យប្រើអំណាចបង្ហាប់ដាក់ទណ្ឌកម្ម នោះ មានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអ្នកតំណាងរដ្ឋមន្ត្រីនេះទើប ចោទបាន ។ ក្នុងជាន់ដំបូង អ្នកតំណាងនោះគឺព្រះរាជអាជ្ញា ។ ដូច្នេះក្នុងរឿងក្ដីបទអាជ្ញា អ្នកដើមចោទ គឺព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ពុំមែនអ្នកដើមបណ្ដឹងទេ ។ ក្នុងសាលាដំបូងណា ដែលគ្មានព្រះរាជអាជ្ញា ចៅហ្វាយសាលាដំបូងនោះទទួលមុខការជួស ។ (មាត្រា៨ នឹង៦៩ ក.ព.ព.) ។

ពាក្យប្ដឹង ក្នុងរឿងក្ដីបទអាជ្ញានឹងជូនផ្ទាល់ទៅព្រះរាជអាជ្ញាតែម្ដងក៏បាន នឹងជូនទៅនាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ណាមួយក៏បាន (officier de police judiciaire) (មាត្រា ៤៩ នឹង៧៣ ក.ព.ព.) ឬនឹងជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏បាន (មាត្រា ៨ ក.ព.ព,)

នាហ្មឺនដែលហៅថានាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌នោះគឺៈ

- ចៅហ្វាយខេត្តនឹងចៅហ្វាយស្រុក ;
- មេឃុំឬជំទប់ (បើឥតមេឃុំ) ;
- ស្នងការប៉ូលិស ;
- នាយអាវុធហត្ថ (offic'er de gendarmerie); មេកងអាវុធហត្ថ (chefs de brigarde) នឹងអាវុធហត្ថ; នាយប៉ុស្ដិ៍អាវុធហត្ថ;

–នាយក្រុមនគរបាលសម្ងាត់និងភូឈួយដែលស្ដីទីស្នងការប៉ូលីស ;

–នាយប៉ុស្ដិ៍រដ្ឋបាល និងនាយប៉ុស្ដិ៍ប្រទល់ដែន ;

–ចៅក្រមសាលាលហុ ;

–ព្រះរាជអាជ្ញា ;

–សភាចារបុរស (មាត្រា៤១ ក.ព.ព) ។

នាហ្មឺនណាបានទទួលបណ្ដឹងហើយ មិនបញ្ជូនទៅតុលាការមុខក្រសួង នាហ្មឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី២(មាត្រា២៤៤ ក.ព.) ។ បើនាហ្មឺននោះបំបិទបំបាំងឬមានបំណងនឹងបំបិទបំបាំងបទល្មើសឧក្រិដ្ឋឬមជ្ឈិម ដែលខ្លួនបានដឹងហើយ ឬមួយបំបាត់ឬមានបំណងនឹងបំបាត់ស័ក្ខតាងបទល្មើសនោះៗ អាចត្រូវទោសមជ្ឈិមថ្នាក់ទី ៣ (មាត្រា២៤៥ក.ព.) ។

បើព្រះរាជអាជ្ញាមិនព្រមចោទ ព្រោះយល់ថារឿងក្នុងពាក្យប្ដឹងមិនចូលជាបទល្មើស នោះព្រះរាជអាជ្ញាត្រូវចេញដីកាប្រាប់ទៅសាមីខ្លួនឲ្យដឹងផង(មាត្រា៧៦ក.ព.ព.) ។ សាមីខ្លួនអាចប្ដឹងដល់សាលាក្រមចោទមួយលើកទៀតបាន (មាត្រា៤៩៧ ក.ព.ព.) ។ បើសាលាក្រមចោទចេញសាលក្រមលើកពាក្យប្ដឹងចោលទៀតសាមីខ្លួនអាចឧទ្ធរណ៍ទៅសាលាវិនិច្ឆ័យជាទីបំផុត (មាត្រា ៥០០ក.ព.ព.) ។



បើព្រះរាជអាជ្ញាយល់ឃើញថារឿងក្នុងពាក្យប្ដឹងនោះចូលជាបទមជ្ឈិម ហើយក្នុងរឿងនោះ ពិបាករកសេចក្ដីពិតក្ដី អ្នកត្រូវចោទគេចខ្លួនបាត់ក្ដី ឬមួយបើព្រះរាជអាជ្ញាយល់ឃើញថារឿងក្នុងពាក្យប្ដឹងនោះ ចូលជាបទឧក្រិដ្ឋ នោះព្រះរាជអាជ្ញាធ្វើដីកាចាត់បញ្ជូនរឿងទៅសភាចារបុរសឲ្យស៊ើបសួរ ។

បើព្រះរាជអាជ្ញាយល់ឃើញថារឿងក្នុងពាក្យប្ដឹងនោះចូលជាបទមជ្ឈិម ហើយក្នុងរឿងនោះងាយរកសេចក្ដីពិត នោះព្រះរាជ-អាជ្ញាអាចធ្វើដីកាកោះអ្នកត្រូវចោទ ឲ្យចូលខ្លួនមកឲ្យសាលាមជ្ឈិមជំនុំជំរះតែម្ដងក៏បាន (មាត្រា៧៧-៧៩ ក.ព.ព.) ។

រឿងក្ដីបទអាជ្ញាច្បាប់ហាមមិនឲ្យនាហ្មឺនមុខក្រសួងផ្សះផ្សា ។ បើនាហ្មឺនមុខក្រសួងណាផ្សះផ្សា ទាល់តែរឿងរលាយបាត់ទៅ មិនបានប្ដឹងដល់តុលាការ នាហ្មឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ២ តាម មាត្រា [illegible]៤ ក.ព.ព. ។

សេចក្ដីសង្ខេប.— រឿងចោទប្រកាន់ដែលពោលមកខាងលើនេះ ប្រើបានតែកាលណាអ្នកប្រព្រឹត្តបទល្មើសជារាស្ត្រធម្មតា ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជានាម៉ឺន ត្រូវរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សុំអនុញ្ញាតពីគណៈរដ្ឋមន្ត្រីជាមុនសិន ទើបព្រះរាជអាជ្ញាចោទប្រកាន់បាន (មាត្រា១១ ក.ព.ព.) ។

បើអ្នកប្រព្រឹត្តបទល្មើសជាមេឃុំ ត្រូវឲ្យបានអនុញ្ញាតពីចៅហ្វាយខេត្តជាមុន ទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសទាន់ជាក់ស្តែង (មាត្រាដដែល) ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកតំណាងរាស្ត្រឬជាទីប្រឹក្សាព្រះរាជអាណាចក្រ ត្រូវបានទទួលអនុញ្ញាតពីរដ្ឋសភា ឬក្រុមប្រឹក្សាព្រះរាជអាណាចក្រជាមុនសិន ទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ជាក់ស្តែង (មាត្រា ៧៧ ទី ៣៣ នៃរដ្ឋធម្មនុញ្ញ) ។

បទល្មើសដែលរាប់ថាទាន់ជាក់ស្តែងនោះ គឺបទល្មើសដែលកំពុងប្រព្រឹត្ត ឬទើបនឹងប្រព្រឹត្តរួចភ្លាមៗ ក្នុងមួយរំពេចឬមួយអ្នកប្រព្រឹត្តបទល្មើសនោះ គេបានទាន់ឃើញមានកស្តុតាងនៅខ្លួន ដូចជាសំលៀកបំពាក់ អាវុធ គ្រឿងឧបករណ៍ ឬសំបុត្រស្នាមដែលធ្វើឲ្យសំគាល់បានជាអ្នកប្រព្រឹត្តបទល្មើសឬជាអ្នកសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសនោះមែន តែត្រូវឲ្យទាន់ឃើញក្នុងគ្រាដែលជិត



បន្ទាប់ពីពេលប្រព្រឹត្តបទល្មើសនោះ (មាត្រា៧៦ ក.ព.ព.) ។

ប្រការ៣. នរណាមានអំណាចចាប់? ដើម្បីនឹងចាប់ត្រូវធ្វើតាមរបៀបដូចម្តេច ទើបត្រឹមត្រូវតាមច្បាប់?

ត្រង់នេះ មានករណី ២ យ៉ាង៖

១) បទឧក្រិដ្ឋ ឬមជ្ឈិមទាន់ជាក់ស្តែង

២) ក្រៅពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលទាន់ជាក់ស្តែង

១.– បទឧក្រិដ្ឋ ឬ មជ្ឈិមដែលទាន់ជាក់ស្តែង.– ក្នុងបទឧក្រិដ្ឋ ឬ មជ្ឈិមដែលទាន់ជាក់ស្តែង នរណាក៏ដោយមិនចាំតែនាយក្នុងការក្រុមនគរបាលយុត្តិធម៌ទេ អាចចាប់អ្នកប្រព្រឹត្តបទល្មើសបាន ។ ច្បាប់បើកអំណាចឲ្យឯកជន (particulier) មានសិទ្ធិចាប់អ្នកប្រព្រឹត្តបទល្មើសដែលទាន់ជាក់ស្តែង ហើយនាំទៅប្រគល់ឲ្យនាយក្នុងការក្រុមនគរបាល (មាត្រា៦៨២ក.ព. នឹងមាត្រា ៧៧ ក.ព.ព.) ។

២– ក្រៅពីបទឧក្រិដ្ឋ ឬ មជ្ឈិមដែលទាន់ជាក់ស្តែង.– ក្រៅពីបទឧក្រិដ្ឋ ឬ មជ្ឈិមដែលទាន់ជាក់ស្តែង មានត្រឹមតែនាយក្នុងការក្រុមនគរបាលយុត្តិធម៌តែប៉ុណ្ណោះ ដែលនឹងចាប់មនុស្សបាន

ប៉ុន្តែក៏ត្រូវឲ្យមានលក្ខខណ្ឌណាមួយ បណ្តាលក្ខខណ្ឌ ២ យ៉ាងដូចតទៅនេះ ៖

ក) មានបង្គាប់ពីតុលាការ ឬ

ខ) បានទទួលបណ្តឹង ។

ក) – នាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ចាប់ដោយមានបង្គាប់ពីតុលាការ (មាត្រា២៤៣ក.ព.) .– ភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ ត្រូវចាប់មនុស្សណា ដែលមានដីកានាំខ្លួន ឬដីកាចាប់ខ្លួន ដែលតុលាការមុខក្រសួងចេញតម្រូវឲ្យចាប់ និងមនុស្សណាដែលមានសាលក្រមកាត់ទោសដាក់គុកផុតរយៈឧទ្ធរណ៍ ។

ដីកានាំខ្លួន.–ជាសំបុត្រដែលតុលាការមុខក្រសួង (តាមធម្មតាសភាចារបុរស ) ចេញបង្គាប់ឲ្យភ្នាក់ងារកំឡាំងអាជ្ញាទាំងពួងនាំខ្លួនអ្នកត្រូវចោទមកជូនតុលាការនេះ ។ ដីកានាំខ្លួននឹងចេញបានតែក្នុងរឿងឧក្រិដ្ឋ ឬ មជ្ឈិមទម្ងន់ ហើយបើអ្នកជាប់ចោទគ្មានទីលំនៅខ្ជាប់ខ្ជួន ឬ បើគួរខ្លាចក្រែងអ្នកត្រូវចោទគេចរត់បាត់ខ្លួន ឬកាលបើអ្នកត្រូវចោទ បានចូលទៅសាលាតាមដីកាបង្គាប់ឲ្យចូលខ្លួន ( មាត្រា ១៧៥-១៧៤ ក.ព.ព. ) ។



ភ្នាក់ងារដែលទទួលសំរេចដីកានាំខ្លួន ត្រូវបង្ហាញដីកានោះទៅអ្នកត្រូវចោទហើយប្រគល់ចុងដីកាទៅឲ្យផង ( មាត្រា ១៧៦ ក.ព.ព.) ។ រួចត្រូវនាំខ្លួនអ្នកត្រូវចោទទៅជូនតុលាការមុខក្រសួងដើម្បីសាកសួរក្នុងរយៈវេលា ២៤ ម៉ោង (មាត្រា ១៨០ ក.ព.ព.) ។ ដល់អ្នកត្រូវចោទចូលខ្លួនដល់តុលាការ ដែលបានចេញដីកានាំខ្លួនហើយ ដីកានាំខ្លួននោះអស់អំណាចតែប៉ុណ្ណោះ ។ តុលាការនោះ នឹងបើកឲ្យលែងនៅក្រៅឃុំក៏បាន បើនឹងដាក់ឲ្យឃុំខ្លួនក៏បាន តែត្រូវចេញដីកាមួយទៀត ហៅថាដីកាឃុំខ្លួន ( មាត្រា ១៨១ ក.ព.ព.) ។

ដីកាចាប់ខ្លួន.– បើអ្នកត្រូវចោទគេចខ្លួនបាត់ នោះតុលាការចេញដីកាឲ្យចាប់ខ្លួន ដោយបានសេចក្តីយល់ព្រមជាមុនពីក្រុមអយ្យការ ។ ដីកានេះ បើកអំណាចឲ្យភ្នាក់ងារដែលចាប់អ្នកត្រូវចោទ នាំខ្លួនត្រង់ទៅគុកតែម្តង ( មាត្រា១៨២ និង ១៨៣ ក.ព.ព.) ។

១.– នាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ចាប់ដោយបានទទួលបណ្តឹង.– អ្នកចេះច្បាប់ខ្លះយល់ថា កាលបានទទួលបណ្តឹងដោយត្រឹមត្រូវថាជនណាបានប្រព្រឹត្តបទឧក្រិដ្ឋឬមជ្ឈិម នាយភ្នាក់

ងារក្រុមនគរបាលយុត្តិធម៌ មានសិទ្ធិចាប់ជននោះមកសាកសួរធ្វើសេចក្តីកត់ហេតុបញ្ជូនទៅព្រះរាជអាជ្ញា ព្រមទាំងជននោះផងឬនឹងបើកលែងជននោះសិន ហើយបញ្ជូនតែពាក្យកត់ហេតុទៅក៏បានដែរ ។ អ្នកដែលយល់ដូច្នេះ អាងដល់មាត្រា ៣៧ ក.ព.ព. ដែលមានសេចក្តីដូចតទៅនេះ ៖ «មុខក្រសួងក្រុមនគរបាលយុត្តិធម៌ ត្រូវស៊ើបរកបទល្មើសជាឧក្រិដ្ឋ មជ្ឈិម និងលហុ ប្រមូលភស្តុតាង និងជូនខ្លួនមនុស្ស ដែលបានប្រព្រឹត្តបទល្មើសទាំងនេះ ទៅសាលាសម្រាប់ធ្វើទោសមនុស្ស ដែលបានប្រព្រឹត្តបទល្មើសនោះ ។

តាមយោបល់អ្នកខ្លះទៀត បទបញ្ញត្តិនៃមាត្រានេះមិនជាក់ច្បាស់គ្រប់គ្រាន់ទេ ព្រោះគ្មានមាត្រាឯទៀត មកប្រកបសេចក្តីផងថា នាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌មានសិទ្ធិចាប់មនុស្សកាលគ្រាន់តែបានទទួលបណ្តឹង ។ គេអាចយល់បានថាអ្នកតែងច្បាប់មានបំណងបើកអំណាចឲ្យនាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ចាប់អ្នកប្រព្រឹត្តបទល្មើស បានតែក្នុងរឿងបទល្មើសដែលទាន់ជាក់ស្តែង និងកាលបានទទួលបង្គាប់ពីតុលាការមុខក្រសួង ។

នាម៉ឺននិងភ្នាក់ងាររាជការ ដែលពុំមែនជានាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ មានសិទ្ធិចាប់មនុស្សឬទេ? ត្រង់នេះមាន



សេចក្តីយល់ផ្សេងៗគ្នា ព្រោះគ្មានបទបញ្ញត្តិឯណាសំដែងឲ្យជាក់ច្បាស់ ។

ប្រការ៤.—នរណាមានអំណាចឃុំឃាំង? ដើម្បីនឹងឃុំឃាំងត្រូវធ្វើតាមរបៀបដូចម្តេចខ្លះ ទើបត្រឹមត្រូវតាមច្បាប់ ?

មានតែតុលាការប៉ុណ្ណោះ ដែលមានអំណាចឃុំឃាំង ។ ដើម្បីនឹងឃុំឃាំងបាន តុលាការមុខក្រសួងត្រូវចេញសាលក្រមកាត់ទោសដាក់គុក ឬចេញដីកាតុលាការ ។ ដីកាតុលាការដែលបើកអំណាចឲ្យឃុំឃាំងបាននោះ គឺដីកាចាប់ខ្លួន និងដីកាឃុំខ្លួន ។

ដីកាចាប់ខ្លួន យើងបានអធិប្បាយរួចមកហើយ ។ ឯដីកាឃុំខ្លួន គឺជាពាក្យបង្គាប់ឲ្យទទួលខ្លួនអ្នកត្រូវចោទទៅឃុំទុកក្នុងគុក ។ ការចេញដីកាឃុំខ្លួននេះ មិនមែនជាការផ្ដាញ់ផ្ដាល ឬជាការដាក់ទណ្ឌកម្មទេ គឺជាការប្រយ័ត្ន កុំឲ្យអ្នកត្រូវចោទគេចខ្លួនបាត់ឬកុំឲ្យអ្នកជាប់ចោទទៅគុបគិតនឹងសាក្សី ឬបំបាត់ភស្តុតាងបាន ក្នុងពេលដែលស៊ើបសួរ ។

ការឃុំឃាំង ដោយមានដីកាតុលាការនេះ ច្បាប់គ្មានកំណត់ថា ដល់ពេលយូរត្រឹមណាត្រូវបើកលែងទេ ស្រេចតែលើចៅក្រម តែចៅក្រមអាចដោះឲ្យនៅក្រៅឃុំបាន ។ សម្រាប់មនុស្ស

ណាដែលទើបនឹងត្រូវចោទតែមួយដង ហើយដែលគួរត្រូវទោសត្រឹមតែជាបទមជ្ឈិមថ្នាក់ទី១ នោះច្បាប់ប្រណីឲ្យចាប់មកឃុំបានត្រឹមតែបីថ្ងៃ រួចឲ្យបើកលែងនៅក្រៅឃុំ តែបើបទល្មើសនៃអ្នកត្រូវចោទនោះ ជាបទមជ្ឈិមដែលធ្ងន់ជាក់ស្តែង ច្បាប់ក៏មិនប្រណីដូច្នេះដែរ (មាត្រា១៨៨ក.ព.ព.) ។

ឯដីកានាំខ្លួន ដែលបានអធិប្បាយរួចមកហើយនោះ មិនមែនបើកអំណាចឲ្យឃុំឃាំងបានទេ គឺគ្រាន់តែឲ្យចាប់ខ្លួនបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ។

ប្រការ៥.— នរណាចាប់ឬឃុំឃាំងគេខុសពីច្បាប់ត្រូវទទួលទោសយ៉ាងណាខ្លះ ?

ជនណាចាប់មនុស្សយកទៅឃុំឃាំងហើយឃាត់ខ្លួន ដោយគ្មានបង្គាប់អំពីរាជការត្រឹមត្រូវតាមច្បាប់ ហើយពីបទល្មើសជាឧក្រិដ្ឋ ឬមជ្ឈិមដែលធ្ងន់ជាក់ស្តែង ជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី២ បើការឃុំឃាំងមិនយូរលើសពី១០ថ្ងៃ ។ បើការឃុំឃាំងយូរលើសពី១០ថ្ងៃ ត្រូវដាក់ទោសមជ្ឈិមថ្នាក់ទី៣ ។ (មាត្រា៤៨២ក.ព.)។

បើជនដែលឃុំឃាំងគេនោះ ធ្វើបាបមិនថែទាំ ឬបង្អត់អាហារ



អ្នកជាប់ឃុំថែមទៀតផង ត្រូវធ្វើទោសជននោះយ៉ាងធ្ងន់បំផុតតាមថ្នាក់ខាងលើនេះ ឬនឹងធ្វើទោសតាមថ្នាក់ធ្ងន់ទៅទៀតក៏បាន (មាត្រា៤៨៣ ក.ព.) ។

ជនណាឲ្យគេហដ្ឋានដោយចេតនា ដើម្បីឲ្យគេឃុំឃាំងមនុស្ស ទោះឥតយកឈ្នួលក្តី ទោះយកឈ្នួលក្តី ជននោះត្រូវទទួលទោសដូចអ្នកឃុំឃាំងគេនោះដែរ (មាត្រា ៤៨៦ក.ព.) ។

តុលាការណាចេញបង្គាប់ឲ្យឃុំឃាំងមនុស្ស ដែលគ្មានត្រូវចោទជាបទឧក្រិដ្ឋ ឬមជ្ឈិម ហើយដែលគ្មានត្រូវកាត់ទោសអាជ្ញា ឬទោសរដ្ឋប្បវេណីបង្ខំដល់រាងកាយទេ តុលាការនោះ ត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៩ ក.ព.) ។

ក្រៅពីតុលាការមុខក្រសួង បើមន្ត្រីឬអ្នកតំណាងរាជការណាចេញបង្គាប់ឲ្យចាប់មនុស្សទៅឃុំឃាំង មន្ត្រីឬអ្នកតំណាងរាជការនោះ ត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៨ក.ព.) ។

ជនណាជានាយក ឬជាអ្នករក្សាគេហដ្ឋានសម្រាប់ឃុំឃាំង ទទួលមនុស្សយកទៅឃុំឃាំងដោយឥតដីកាតុលាការ ឬឥតសេចក្តី

ស្រង់សាលក្រម ដែលតុលាការបានចេញឲ្យ ជននោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី២ (មាត្រា២៥០ ក.ព.) ។

ជនណាត្រូវគេកែងក្លាយឬគំរាមតុលាការជាបទទេក្រិដ្ឋឬមជ្ឈិមដោយឥត្ថាពុក្យបាទ កាលបើតុលាការរកឃើញហើយមិនឃើញដូចបណ្តឹងកាត់សេចក្តីលែងខ្លួន ឬលើកលែងទោសប្រេកាន់ ជននោះអាចប្តឹងយកអ្នកដើមបណ្តឹងទុច្ចរិតឲ្យត្រូវទោសមជ្ឈិមថ្នាក់ទី ២ បាន (មាត្រា ៥១៤ក.ព.) ។

វគ្គទី ២.— នឹងឃុំឃាំងជនណាបាន លុះតែមានចៅក្រមពិនិត្យការឃុំឃាំងនោះឃើញថាត្រឹមត្រូវតាមច្បាប់ហើយយល់ព្រមផង ដោយចង្អុលហេតុផលក្នុងរយៈវេលាដែលមានកំណត់ទុកក្នុងច្បាប់ ។

ការតែងពាក្យក្នុងវគ្គនេះ មិនបានច្បាស់លាស់ល្អ ។

អត្ថបទ (texte) ដែលរដ្ឋសភាបានបញ្ចេញមតិរៀបរៀងឡើងនោះ គឺដូច្នេះ៖ "ដែលនឹងឃុំឃាំងជនណាទុកតទៅទៀតបាននោះ លុះតែក្នុងរវាង ៤៨ ម៉ោងដំបូង មានចៅក្រមសាកសួរជននោះ ឲ្យដឹងថាការចាប់មកឃុំឃាំងនោះ គេត្រូវតាមច្បាប់ឬទេ ។ មួយទៀតដែលនឹងឃុំឃាំងទុកយូរទៅទៀតបាននោះ លុះតែ ១៥ ថ្ងៃមុន



១៥ថ្ងៃមុនរៀងតទៅ ចៅក្រមដដែលនោះចេញដីកាថ្លែងហេតុផលបង្គាប់ឲ្យឃុំឃាំងតទៅទៀត[(១)] ។"

បំណងរបស់អ្នកតែងច្បាប់ គឺថាមិនត្រូវបើកអំណាចឲ្យចាប់មនុស្សមកឃុំទុកចោលបានទេ ។ ដូច្នេះទើបមានបញ្ញត្តិជាពីរដូចតទៅនេះ ៖

១ ១— កាលចាប់ជនណាមកឃុំត្រូវឲ្យចៅក្រមសាកសួរជននោះ ក្នុងរវាងវេលាដែលមានកំណត់ទុកក្នុងច្បាប់ (២៤ ម៉ោង ឬ ៤៨ ម៉ោង ស្រេចតែនឹងដាក់កំណត់ក្នុងច្បាប់ទៅថ្ងៃក្រោយ) ។

---

(១) ក្នុងរឿងនេះ តមកព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ប្រជុំក្នុងព្រះបរមរាជវាំង ពិនិត្យសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ព្រមទាំងសេចក្តីសុំកែប្រែរបស់រដ្ឋសភាដើម្បីនឹងយកជាការស្រេច ទីប្រជុំយល់ថាគួរទុកសេចក្តីឲ្យនៅនដែលចុះ តែគួរកុំកំណត់ពេលឲ្យច្បាស់លាស់ពេក ទុកឲ្យរដ្ឋសភាតាំងច្បាប់កំណត់ពេលទៅថ្ងៃក្រោយវិញល្អជាង ព្រោះការកំណត់ពេលនេះ អាចប្រែប្រួលទៅតាមកាលសម័យ ។ បើនឹងត្រូវការប្រែកំណត់ពេល គ្រាន់តែកែប្រែច្បាប់បានហើយ កុំឲ្យចាំបាច់កែប្រែដល់រដ្ឋធម្មនុញ្ញ ។ ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ព្រាស់ឲ្យលុបកំណត់ពេល ៤៨ ម៉ោងនិង ១៥ ថ្ងៃចោលចេញ ហើយឲ្យរៀបពាក្យជាថ្មីទុកសេចក្តីឲ្យនៅតាមទំនងដដែល ។

ជាការគួរស្តាយណាស់ ដែលអ្នកទទួលព្រះបរមរាជឱង្ការពុំបានតែងពាក្យឲ្យច្បាស់លាស់ ហើយទីប្រជុំស្មានថាត្រឹមត្រូវហើយ ក៏ពុំបានពិនិត្យជាថ្មីទៀតឲ្យល្អិតល្អ ការប្រែវគ្គទី ២ នេះ ពីភាសាបារាំងមកជាភាសាខ្មែរ ក៏មានល្អៀងទៀតផង ។

កាលដល់កំណត់ពេលហើយ គ្មានចៅក្រមណាសាកសួរទេ ត្រូវ
ឲ្យបើកលែងអ្នកជាប់ឃុំនោះចេញ ។ កាលបើចៅក្រមសាកសួរ
ទៅហើយ យល់ឃើញថាការចាប់មកឃុំត្រឹមត្រូវតាមច្បាប់ហើយ
ចៅក្រមអាចបើកឲ្យនៅក្រៅឃុំក៏បាន ឬនឹងបង្គាប់ឲ្យឃុំតទៅទៀត
ក៏បាន ស្រេចតែចៅក្រមនឹងយល់ថាជាការគួរ ។

១២.– កាលចៅក្រមបង្គាប់ឲ្យឃុំតទៅទៀត នោះត្រូវមាន
កំណត់វេលា (១៥ ថ្ងៃម្ដងឬ១ខែម្ដង ស្រេចតែនឹងមានកំណត់ក្នុង
ច្បាប់ទៅថ្ងៃក្រោយ) ឲ្យចៅក្រមនោះគិតដល់អ្នកជាប់ឃុំម្ដងរៀងៗ
ទៅ ។ កាលដល់កំណត់វេលាហើយ បើចៅក្រមយល់ថានឹង
លែងមិនទាន់បានទេ ត្រូវឲ្យចៅក្រមនោះចេញដីកាបង្គាប់ឲ្យឃុំត
ទៅទៀតរាល់ៗដងតទៅ ។ ក្នុងដីកានោះ ចៅក្រមត្រូវដាក់ថា
ហេតុម្ដេចបានជាឲ្យឃុំតទៅទៀត ។ ប្រសិនជាដល់កំណត់វេលា
ហើយ ចៅក្រមមិនបានចេញដីកាឲ្យឃុំទៀតទេ ត្រូវឲ្យបើក
លែងអ្នកជាប់ឃុំនោះចេញ ។

តាមបញ្ញត្តិច្បាប់ដែលយើងប្រើមកដល់សព្វថ្ងៃនេះ កាល
បើចៅក្រមចេញដីកានាំខ្លួននោះ នឹងឃុំមនុស្សត្រូវចោទបានតែ



២៤ ម៉ោង ត្រូវឲ្យចៅក្រមដែលចេញដីកានាំខ្លួននោះសាកសួរ
(មាត្រា១៨០ ក.ព.ព.) ។ បើឃុំគ្រប់២៤ម៉ោងហើយ ចៅក្រម
នោះមិនបានសាកសួរទេ ត្រូវបើកលែងមនុស្សជាប់ឃុំចេញ ។

ប៉ុន្តែបើមនុស្សត្រូវចោទ ជាប់ឃុំដោយចៅក្រមបានចេញ
ដីកាចាប់ខ្លួនឬដីកាឃុំខ្លួនវិញ នោះអ្នកជាប់ឃុំអាចនៅក្នុងគុករហូត
ទៅឥតមានកំណត់ពេលឡើយ ។

វគ្គទី ៣.– ទារុណកម្មឬការបង្ខំ ដែលឥតប្រយោជន៍ក្នុងខណៈចាប់ខ្លួន
ណាមួយ, ការសង្កត់សង្កិនចិត្តឬការធ្វើបាបដល់រាងកាយចំពោះអ្នកជាប់ឃុំណាមួយ,
ការប្រព្រឹត្តដែលបណ្ដាលឲ្យធ្ងន់ថែមទៅលើទណ្ឌកម្មដែលតុលាការ បានតម្រូវតាមច្បាប់
ទៅលើអ្នកមានទោសណាមួយស្រេចហើយ នោះច្បាប់ហាមមិនឲ្យប្រព្រឹត្ត, ហើយ
ក្នុងបទទាំងនេះ អ្នកដែលល់ អ្នកមេគំនិតឬអ្នកសមគំនិតត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន ។

១.– ក្នុងខណៈចាប់មនុស្ស ត្រូវប្រព្រឹត្តទៅលើមនុស្សនោះ
តែអំពើណាដែលល្មមគ្រប់គ្រាន់នឹងចាប់ខ្លួន ហើយនាំខ្លួនទៅបាន
កុំឲ្យគេចរត់បាត់ខ្លួនតែប៉ុណ្ណោះ ។ ហាមមិនឲ្យធ្វើទារុណកម្ម គឺអំ-
ពើក្ដៅតឹងតែងដែលឥតប្រយោជន៍ ដូចជាដាក់ឃ្នាងចងស្លាបសេក
ជាដើម ហាមមិនឲ្យបង្ខំអ្នកត្រូវចាប់ឲ្យធ្វើអំពើឥតប្រយោជន៍ក្នុងការ
ចាប់ ដូចជាបង្ខំឲ្យឈរហាលថ្ងៃឲ្យរត់តាមបីស៊ីក្លែត ឬរត់មុខសេះ
ជាដើម ។

២.– ក្នុងខណៈដែលមនុស្សត្រូវចោទជាប់ឃុំឃាំង ហាមមិនឲ្យសង្កត់សង្កិនចិត្ត ដូចជាដេរស្តីកំហែងថា បើមិនឆ្លើយក្នុងសាលាថាដូច្នេះដូច្នោះ នឹងធ្វើយ៉ាងនេះមួយ យ៉ាងនោះមួយជាដើម; ហាមមិនឲ្យធ្វើបាបដល់រាងកាយដូចជាវាយគត់ជាដើម ។

៣.– ក្នុងខណៈដែលសាលាកាត់សេចក្តីដាក់គុកជនណាហើយ ហាមមិនឲ្យដាក់ទណ្ឌកម្មធ្ងន់លើសពីទោស ដែលច្បាប់តម្រូវឲ្យដាក់ ដូចជាដាក់គុកងងឹត កាលច្បាប់មិនបង្គាប់ឲ្យដាក់ ដាក់ច្រវាក់ ឬឲ្យនៅកន្លែងចង្អៀត ដល់ជាដេកសន្ធឹងជើងឲ្យត្រង់ពុំបានជាដើម។

ជនណាប្រព្រឹត្តល្មើសបទបញ្ញត្តិខាងលើនេះ ជននោះត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន បើទោះជាដៃដល់ គឺបានប្រព្រឹត្តខ្លួនឯងក្តី ទោះជាអ្នកមេគំនិត គឺប្រើគេ ពឹងគេ ជួលគេឲ្យប្រព្រឹត្តក្តី ទោះជាអ្នកសមគំនិតគឺចូលដៃប្រព្រឹត្ត ជួយគេប្រព្រឹត្តក្តី ។ ពាក្យថា "ខុសត្រូវផ្ទាល់ខ្លួន" ប្រែសេចក្តីដូចតទៅនេះ ។ ឧបមាថាមានភ្នាក់ងារក្រុមនគរបាល(agent de la police nationale) ម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស សេចក្តីខុសត្រូវអាចធ្លាក់ទៅលើក្រុមនគរបាលទាំងមូល ។ កាលបើបទល្មើសនោះ មានសណ្ឋានដូចខាងលើនេះ រដ្ឋធម្មនុញ្ញបញ្ញត្តថាសេចក្តីខុសត្រូវ ត្រូវធ្លាក់ទៅលើភ្នាក់ងារ



នោះដោយចំពោះខ្លួន មិនមែនឲ្យធ្លាក់ទៅលើក្រុមនគរបាលទេ ។

មានព្រះរាជក្រមមួយចុះថ្ងៃ១៨ខែសីហា(អ៊ូត)គ.ស. ១៩៥០ ហាមមិនឲ្យដាក់ច្រវាក់អ្នកទោស វៀរលែងតែអ្នកទោសណាដែលធ្លាប់រត់មកហើយ ។ ព្រះរាជក្រមនេះ នៅប្រើបានលុះមកដល់សព្វថ្ងៃ ។

មាត្រា ៩.– និរាបណាតុលាការមិនទាន់ប្រកាសថាអ្នកត្រូវចោទមានទោសទេ និរាបនោះត្រូវទុកអ្នកត្រូវចោទជាមនុស្សឥតទោស ។

ទណ្ឌកម្មដែលបំបាត់ឬបន្ថយសេរីភាពដល់អ្នកប្រព្រឹត្តខុសត្រូវដាក់ដោយញ៉ាំងឲ្យកែខ្លួនបានល្អឡើងវិញ ។

សេចក្តីអធិប្បាយ:

វគ្គទី១.– មនុស្សត្រូវចោទ ទោះសេចក្តីចោទនោះជាបទមជ្ឈិម ឬឧក្រិដ្ឋធ្ងន់យ៉ាងណាក្តី ទោះបទមជ្ឈិម ឬឧក្រិដ្ឋនោះគេដាក់ថា មនុស្សត្រូវចោទបានប្រព្រឹត្តមែនយ៉ាងណាក្តី ត្រូវទុកអ្នកត្រូវចោទនោះជាមនុស្សឥតទោស គឺជាមនុស្សពុំបានប្រព្រឹត្តខុសទេ ជាដរាបទៅ លុះវេលាដែលសាលាកាត់សេចក្តីថា មនុស្សត្រូវចោទមានទោស ទើបទុកជាមនុស្សមានទោសបាន ។

ដូច្នេះ ការចាប់ខ្លួនអ្នកត្រូវចោទ ត្រូវធ្វើទៅដោយប្រាថ្នានាំយកខ្លួនទៅជូនតុលាការដើម្បីជំនុំជំរះតែប៉ុណ្ណោះ; ការឃុំឃាំងអ្នកត្រូវចោទ ក៏ត្រូវធ្វើទៅដោយប្រាថ្នាឲ្យការសាកសួរ ការស៊ើបសួរ ការជំនុំជំរះអាចមានដំណើរទៅដោយស្រួលបាន គឺបង្ការមិនឲ្យអ្នកត្រូវចោទបំបាត់ភស្តុតាង ស្លុកប៉ាន់សាក្សី...គេចរត់បាត់ខ្លួនតែប៉ុណ្ណោះ ។ ការចាប់ ការឃុំឃាំង មិនត្រូវធ្វើទៅដោយប្រាថ្នាផ្ដន្ទាទោសអ្នកត្រូវចោទទេ ។ ហេតុនេះ ត្រូវហាមមិនឲ្យបង្ខំអ្នកត្រូវចោទឲ្យធ្វើការ ។ បើនឹងស្រដីដោយខ្លីទៅ គឺថាហាមមិនឲ្យប្រព្រឹត្តទៅលើមនុស្សត្រូវចោទ ដូចប្រព្រឹត្តទៅលើមនុស្ស ដែលតុលាការបានកាត់ទោសហើយ ។

វគ្គទី ២.— កាលសាលាជំនុំជំរះទៅឃើញថាអ្នកត្រូវចោទបានប្រព្រឹត្តបទល្មើសមែន សាលាកាត់សេចក្ដីដាក់ទោស ទោសនោះរដ្ឋធម្មនុញ្ញ ហាមមិនឲ្យដាក់ដោយចង់ផ្ចាញ់ផ្ចាល ឬចង់សងសឹក, ត្រូវដាក់ដោយប្រាថ្នានឹងទូន្មានប្រដៅអ្នកប្រព្រឹត្តខុសឲ្យប្រែគំនិតមារយាទទៅថ្ងៃក្រោយ ។

ពាក្យថា "បំបាត់សេរីភាព" ក្នុងទីនេះបានដល់ការបំបាត់សេរីភាពខាងរាងកាយគឺការបង្ខំមិនឲ្យទៅណាមកណា បានតាមចិត្ត



ប្រែថា ដាក់គុក ។ ពាក្យថា "បន្ថយសេរីភាព" ក្នុងទីនេះ បានសេចក្ដីស្រាលជាង "បំបាត់សេរីភាព" ។ បុគ្គលដែលត្រូវគេបន្ថយសេរីភាព អាចទៅណាមកណាបានខ្លះ ដូចជាត្រូវនៅបានតែក្នុងក្រុងណាមួយ ហើយត្រូវហាមមិនឲ្យធ្វើដំណើរចេញពីទីក្រុងនោះ ។

មាត្រា ៦.— ខេមរជនមិនអាចត្រូវនិរទេសពីដែនខ្មែរបានឡើយ ។ ការហាមខេមរជនមិនឲ្យនៅក្នុងកន្លែងណាមួយ ឬការបង្ខំឲ្យនៅក្នុងកន្លែងណាមួយត្រូវធ្វើតែក្នុងករណីដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

សេចក្ដីអធិប្បាយ.— មាត្រានេះ ស្ដីអំពីការបន្ថយសេរីភាព ។ ការបន្ថយសេរីភាពមាន ៣ សណ្ឋាន ៖

១.— បញ្ជូនខ្លួនឲ្យផុតពីដែនខ្មែរ តែមិនឃុំឃាំងទេ ទៅណាមកណាបានតាមចិត្ត កុំឲ្យតែចូលមកដែនខ្មែរវិញ ។ នេះហៅថានិរទេស ។

២.— ហាមមិនឲ្យនៅក្នុងកន្លែងណាមួយ ដូចជាខេត្រណាមួយនៅក្នុងដែនខ្មែរ តែក្រៅពីខេត្រនោះចង់នៅឯណាបានតាមចិត្ត ។

៣.— បង្ខំឲ្យនៅក្នុងកន្លែងណាមួយ ដូចជាដំបន់ណា ឬ

ក្រុងណាមួយ ក្នុងដែនខ្មែរ ហើយហាមមិនឲ្យទៅក្រៅទីនោះ ។

ការបន្ថយសេរីភាពសណ្ឋានទី ២ និងទី ៣ នឹងធ្វើបានតែតាមបញ្ញត្តិច្បាប់ ។ ពាក្យ "ករណី" ប្រែថា ហេតុ, ហេតុការណ៍ក្នុងទីនេះនឹងប្រែថា "បទ" ក៏បាន ។ ប្រយោគទី២នៃមាត្រានេះអាចរៀបរៀងបានដូច្នេះវិញ ៖ "នឹងហាមខេមរជនណាមិនឲ្យនៅក្នុងកន្លែងណាមួយ ឬនឹងបង្ខំឲ្យនៅក្នុងកន្លែងណាមួយបាន លុះតែខេមរជននោះបានប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់" ។ ករណីដែលនាំឲ្យបន្ថយសេរីភាពខាងរាងកាយក្នុងសណ្ឋានទី ២ និងទី ៣ រដ្ឋសភាអាចតាំងច្បាប់បញ្ញត្តទុកបាន ឯការបន្ថយសេរីភាពក្នុងសណ្ឋានទី១ គឺការនិរទេសខេមរជន រដ្ឋធម្មនុញ្ញហាមមិនឲ្យមានជាដាច់ខាត ប្រែសេចក្ដីថា រដ្ឋសភាមិនអាចតាំងច្បាប់ឲ្យនិរទេសខេមរជនពីដែនខ្មែរបានឡើយ ។

មាត្រា ៧. – កម្មសិទ្ធិឋិតនៅក្នុងការឃុំគ្រងនៃច្បាប់ ។ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ ក៏ដោយហេតុជាសាធារណប្រយោជន៍ ក្នុងករណីដែលច្បាប់បានបញ្ញត្តទុករួចហើយត្រូវឲ្យសោហ៊ុយជួសជុលជាមុនដោយយុត្តិធម៌ ។



សេចក្ដីអធិប្បាយ.– ពាក្យថា "កម្មសិទ្ធិ" ប្រែថា សិទ្ធិដាច់ស្រេច, សិទ្ធិដាច់ខាត ឬអំណាចដាច់ខាត ដែលបុគ្គលមានលើវត្ថុណានីមួយ ។ ដីដែលយើងកាន់កាប់ ផ្ទះដែលយើងនៅ អាចជាវត្ថុដែលគេឲ្យយើងខ្ចី ឬឲ្យយើងជួល ។ ក្នុងករណីដូច្នេះ ដីឬផ្ទះនោះ មិនមែនជាកម្មសិទ្ធិរបស់យើងទេ ។ បើដីឬផ្ទះនោះ យើងបានមកពីការទិញដូរ ឬពីការទទួលមត៌ក ដីឬផ្ទះនោះជាកម្មសិទ្ធិរបស់យើង ។ យើងជាម្ចាស់ដីឬផ្ទះនោះពេញទី ។

កម្មសិទ្ធិឋិតនៅក្នុងការឃុំគ្រងនៃច្បាប់ ប្រែសេចក្ដីថាច្បាប់ត្រូវរក្សាការពារកម្មសិទ្ធិ កុំឲ្យនរណាបៀតបៀនឬរំលោភយកកម្មសិទ្ធិបាន ពោលគឺកុំឲ្យនរណាយកទ្រព្យគេមកធ្វើទ្រព្យខ្លួនតាមចិត្តបាន ។

ខេមរជនមានសេរីភាពលក់ដូរ ឬមិនលក់ដូរវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ។ តែរដ្ឋធម្មនុញ្ញបញ្ញត្តពីករណីមួយ ដែលគេអាចដកហូតកម្មសិទ្ធិបាន គឺកាលជាសាធារណប្រយោជន៍ ។ សាធារណប្រយោជន៍ គឺប្រយោជន៍ដល់ជនទាំងអស់គ្នា ។ ឧបមាដូចជាដីភូមិដែលខ្ញុំតាំងផ្ទះនៅសព្វថ្ងៃ ។ ភូមិនេះជាប្រយោជន៍ដល់ខ្លួនខ្ញុំតែមួយនាក់ ។ ប្រសិនជារាជការ ត្រូវការយកភូមិខ្ញុំទៅប្រើការសម្រាប់សង់សាលារៀន ភូមិនោះនឹងជាប្រយោជន៍ដល់ខេមរជនទាំង

ជាតិ ព្រោះអ្នករៀនចេះដឹងក្នុងសាលានេះ នឹងអាចធ្វើប្រយោជន៍ដល់ជាតិខ្មែរទាំងមូល ។ នេះគឺសាធារណប្រយោជន៍ ។ ដោយហេតុថាប្រយោជន៍នៃជនទាំងអស់គ្នា ធំជាងប្រយោជន៍នៃជនម្នាក់ៗ រដ្ឋធម្មនុញ្ញ ទើបបើកអំណាចឲ្យដកហូតកម្មសិទ្ធិពីជនទីមួយៗ ទៅធ្វើជាប្រយោជន៍ដល់ជនទាំងអស់គ្នាបាន ។

តែការដកហូតកម្មសិទ្ធិ ត្រូវមានលក្ខខណ្ឌ ៣ ប្រការទើបធ្វើទៅបាន ៖ ១) ត្រូវឲ្យជាសាធារណប្រយោជន៍ ដូចពោលមកខាងលើនេះ ។ ២) រាជការមិនចេះតែអាងថាជាសាធារណប្រយោជន៍ ហើយយកដីរាស្ត្រតាមចិត្តបានទេ ។ រាជការនឹងដកហូតកម្មសិទ្ធិបាន លុះត្រាតែមានបញ្ញត្តក្នុងច្បាប់ ថាការដកហូតកម្មសិទ្ធិនោះ ជាសាធារណប្រយោជន៍មែន ។ ៣) កាលបើជាសាធារណប្រយោជន៍ ហើយមានបញ្ញត្តិច្បាប់ឲ្យដកហូតកម្មសិទ្ធិបាន តែប៉ុណ្ណោះក៏មិនគ្រប់គ្រាន់ទៀត ។ រដ្ឋធម្មនុញ្ញតម្រូវឲ្យរាជការចេញសោហ៊ុយជួសជុលឲ្យអ្នកម្ចាស់ទ្រព្យ ។ សោហ៊ុយនោះត្រូវកំណត់ឲ្យយុត្តិធម៌ ហើយត្រូវចេញឲ្យជាមុនទៀតផង ។



មាត្រា ៨– **សេរីភាពខាងជំនឿ** ត្រូវបើកឲ្យមានដោយបរិបូណ៌ ។ សេរីភាពក្នុងការប្រតិបត្តិ ខាងផ្លូវសាសនា ក៏ត្រូវបើកឲ្យមានដូច្នោះដែរ បើនឹងបន្ថយខ្លះ បានតែត្រង់ណាដែលវៀរពុំបាន ដើម្បីកុំឲ្យខូចសេចក្ដីស្ងប់រៀបរយនៃមហាជន ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

សេចក្ដីអធិប្បាយ.– សេរីភាពខាងជំនឿត្រូវបើកឲ្យមានដោយបរិបូណ៌ គឺថាបុគ្គលមានសេរីភាពពេញទីខាងជំនឿ ។ តាមន័យមួយទៀត គឺថាបុគ្គលគ្រប់រូប មិនថារូបណា ចង់ជឿតាមសាសនាណា ឬមិនជឿតាមសាសនាណា បានតាមចិត្ត ។

សេចក្ដីត្រង់នេះ សម្រាប់ប្រទេសខ្មែរ គ្មានសារៈសំខាន់ប៉ុន្មានទេ ព្រោះជនជាតិខ្មែរ ដែលកាន់ព្រះពុទ្ធសាសនាមិនដែលបង្ខំជនណាឲ្យជឿតាមខ្លួនសោះឡើយ ។ ព្រះពុទ្ធសាសនាតែងតែផ្សាយទៅដោយសេចក្ដីស្លូតត្រង់ នាំហេតុនាំផលមកពន្យល់ឲ្យមនុស្សចុះចូល ដោយស្ម័គ្រពីចិត្តឯង ។ តែសម្រាប់សាសនាដទៃខ្លះ មិនដូច្នេះទេ ។ ក្នុងប្រទេសរ៉ូមសម័យបុរាណ មនុស្សកាន់គ្រិស្តសាសនាជាដំបូង ត្រូវរាជការសង្កត់សង្កិនធ្វើបាប ត្រូវយកទៅប្រហារជីវិត ឬយកទៅឲ្យសត្វសាហាវខាំសម្លាប់បរិភោគក៏មាន ។ ក្នុងទ្វីបអឺរ៉ុប អ្នកកាន់សាសនាប្រូតេស្តង់ ក៏ត្រូវរាជការសង្កត់សង្កិនណាស់ដែរក្នុងសតវត្សទី ១៦–១៧ ដល់ជាបង្កើតចំបាំងសាសនាឡើង ។

ក្នុងលំដាប់គអារ្យធម៌បានចំរើនខ្ពស់ៗឡើង ទើបតាំងឲ្យមានសេរីភាពខាងសាសនាបាន មានត្រាទុកក្នុងរដ្ឋធម្មនុញ្ញ នៃអារ្យប្រទេសនានា ៗ ការណ៍ដែលមានចុះសេរីភាពខាងជំនឿក្នុងរដ្ឋធម្មនុញ្ញខ្មែរ ក៏ជាហេតុមួយសំដែងឲ្យឃើញថាជាតិយើង មិនមែនជាជាតិព្រៃផ្សៃទេ ៗ

សេចក្ដីខាងលើនេះ បានដល់ផ្លូវចិត្ត ៗ សេរីភាពខាងផ្លូវចិត្តចំពោះសាសនា ជាសេរីភាពដាច់ខាត គឺថារដ្ឋ (ឬរាជការ) មិនអាចតាំងច្បាប់មកបំបាត់ ឬបន្ថយសេរីភាពនេះបានឡើយ ៗ

ប៉ុន្តែសេចក្ដីជឿក្នុងចិត្តរមែងសំដែងចេញមកខាងក្រៅដោយកាយនឹងវាចា ៗ សេចក្ដីសំដែងចេញមកខាងក្រៅនេះ ហៅថាការប្រតិបត្តិសាសនា បានដល់ការធ្វើពិធីបុណ្យរាយជូន ទូងស្គរលេងភ្លេងហែក្បួនសូត្រធម៌ទេសនា ជាដើម ៗ សេរីភាពខាងការប្រតិបត្តិសាសនានេះក៏មានដែរ តែមិនមែនជាសេរីភាពដាច់ខាត ៗ រដ្ឋអាចបន្ថយសេរីភាពនេះបានខ្លះ កាលបើការប្រតិបត្តិនោះ នាំឲ្យខូចសេចក្ដីសុខរៀបរយដល់មហាជន ៗ ប្រែសេចក្ដីថាកាលបើការប្រតិបត្តិសាសនាណាមួយ អាចនាំឲ្យមានចលាចលក្នុងប្រទេស ហើយប្រសិនជារដ្ឋយល់ថានឹងបណ្ដោយឲ្យប្រតិបត្តិតទៅទៀតពុំ



បាន នោះរដ្ឋអាចហាមមិនឲ្យមានការប្រតិបត្តិសាសនានោះ ៗ

តាមសេចក្ដីក្នុងវគ្គទី ១ ដូចអធិប្បាយខាងលើនេះ សាសនាណាក៏អាចតាំងនៅបាន ក្នុងប្រទេសខ្មែរដូចគ្នា ៗ តែវគ្គទី ២ សំដែងថាបណ្ដាសាសនាទាំងឡាយ ដែលតាំងនៅក្នុងប្រទេសខ្មែរ មានសាសនាមួយដែលមានឋានៈខ្ពង់ខ្ពស់ជាងគេទាំងអស់គឺ៖ ព្រះពុទ្ធសាសនា ព្រោះមានតែព្រះពុទ្ធសាសនាមួយនេះទេ ដែលលើកជាសាសនារបស់រដ្ឋ ៗ

ដូច្នេះចាប់តាំងពីថ្ងៃប្រកាសប្រើរដ្ឋធម្មនុញ្ញនេះតទៅ (គឺថ្ងៃទី ៦ ឧសភា គ. ស. ១៩៤៧) សាសនាទាំងឡាយដែលមាននៅក្នុងព្រះរាជអាណាចក្រ អាចចែកជាពីរថ្នាក់៖ ១) សាសនារបស់រដ្ឋ គឺព្រះពុទ្ធសាសនាដែលមានឋានៈខ្ពស់ជាងគេ; ២) សាសនាឯទៀតដែលមានឋានៈទាបចុះមកស្មើគ្នាទាំងអស់ ៗ របៀបថ្មីនេះខុសពីរបៀបមុន ។ កាលមុនយើងមានរដ្ឋធម្មនុញ្ញ សាសនាទាំងឡាយដែលមាននៅក្នុងព្រះរាជអាណាចក្រ តោងជាសាសនាដែលរដ្ឋ (គឺរាជការ) បានព្រមទទួលស្គាល់ហើយ ៗ សាសនាដែលរដ្ឋបានទទួលស្គាល់ហើយនោះមានឋានៈស្មើគ្នាទាំងអស់ គឺព្រះពុទ្ធសាស-

នាគ្រិស្តសាសនា សាសនាមហាម៉ាត់ (១) ។ល។ ក្រៅពីសាសនាដែ
រដ្ឋបានទទួលស្គាល់ សាសនាឯទៀតគ្មានសិទ្ធិតាំងនៅក្នុងព្រះ
អាណាចក្រទេ ។ ជនណាប្រតិបត្តិសាសនាដែលរដ្ឋមិនបានទ
ស្គាល់ ជននោះអាចត្រូវទោសថ្នាក់មជ្ឈិមទី ១ តាមមាត្រា ២
នឹងមាត្រា២១៤ក្រមព្រហ្មទណ្ឌ ។ មាត្រាទាំង២ជាមោឃៈ (អ
សូន្យ) ទៅហើយ ព្រោះផ្ទុយសេចក្តីនៃរដ្ឋធម្មនុញ្ញ (
មាត្រា ១០៣ នៃរដ្ឋធម្មនុញ្ញ) ។

មាត្រា ៩ — ខេមរជនមានសេរីភាព ក្នុងការនិយាយ–សរសេរ–
និងការផ្សាយដល់មហាជន ។ ខេមរជនអាចសំដែង–ផ្សាយឬការពារមតិគ្រប់យ៉ាង
ផ្លូវកាសែតក្តី តាមវិធីណាឯទៀតក្តី កុំឲ្យតែប្រើសិទ្ធិនេះដោយរំលោភ ហើយ
ញុំាងឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។

មិនត្រូវបង្ខំឬបង្គាប់នរណាឲ្យសំដែងមតិជាធ្វូប្លេះឬធ្វូប្លោះបានឡើយ ។

សេចក្តីអធិប្បាយ.— មាត្រាមុនស្តីអំពីសេរីភា
ជំនឿ ។ មាត្រានេះស្តីអំពីសេរីភាពខាងគំនិត រហូតដល់សេ

(១) ក្នុងទីខ្លះសរសេរជា មោហម្មេទ ។



ខាងការសំដែងសេចក្តីគិតយល់នោះដោយវាចាក្តី ដោយលាយលក្ខណ៍អក្សរក្តី ។

ការសរសេរ បានដល់ការសំដែងគំនិត ដោយលាយលក្ខណ៍អក្សរ ចំពោះបុគ្គលមួយនាក់ក្តី ច្រើននាក់ក្តី ។ ក្នុងសម័យមុន ដើម្បីនឹងបោះពុម្ពសៀវភៅបាន ត្រូវជូនរឿងដែលតែងនោះទៅកុងស៊ីយ៍សេនាបតី (១) ឲ្យត្រួតមើលជាមុន ។ បើកុងស៊ីយ៍សេនាបតីឲ្យអនុញ្ញាតទើបបោះពុម្ពបាន ។ ឥឡូវនេះមិនចាំបាច់សុំអនុញ្ញាតពីគណៈរដ្ឋមន្ត្រីទេ ។

ការធ្វើកាសែត ក៏មិនចាំបាច់សុំអនុញ្ញាតដែរ រូបសេចក្តីដែលចុះក្នុងកាសែតទៀត ក៏មិនត្រូវឲ្យរាជការត្រួតដូចពីមុនដែរ ។

ពាក្យថា"ផ្សាយមតិ" ប្រែថាធ្វើមនុស្សចំនួនច្រើនឲ្យដឹង-ឮ ថាខ្លួនមានយោបល់ មានសេចក្តីគិតឃើញដូចម្តេច ។

ពាក្យថា"អាចការពារមតិ" ប្រែថាកាលយើងផ្សាយគំនិត ផ្សាយយោបល់របស់យើងទៅហើយ បើមាននរណាទទឹងទាស់ ឬ ប្រកាន់ថាមិនត្រូវ ឬ មិនពិត នោះយើងអាចឆ្លើយកែខដោះស្រាយ ឬ

(១)ពាក្យនេះប្រើក្នុងពេលមុនមានរដ្ឋធម្មនុញ្ញ ដែលសព្វថ្ងៃត្រូវប្រើពាក្យថាគណៈរដ្ឋមន្ត្រីជំនួសវិញ ។

ពន្យល់បាន ថាជាការត្រូវ ឬ ជាការពិត ។

ការសំដែងផ្សាយ ឬការពារមតិ ក្រៅពីផ្លូវកាសែតនោះបានដល់ការនិយាយដោយមាត់ទទេ ការនិយាយដោយអាស្រ័យគ្រឿងបំពងសំឡេង ការនិយាយតាមផ្លូវវិទ្យុ ការបោះពុម្ពជាសន្លឹកក្រដាសចែកចាយដល់មហាជន ឬ បិទនឹងជញ្ជាំងនឹងដើមឈើជាដើម ។ សេចក្តីក្នុងវគ្គទី ២ នៃមាត្រានេះបំភ្លឺឲ្យកាន់តែឃើញជាក់ច្បាស់ឡើងត្រង់សេរីភាព ក្នុងការសំដែងមតិ ។ គ្មាននរណាបង្ខំ ឬ បង្គាប់នរណាឲ្យសំដែងមតិតាមចិត្តខ្លួនបានឡើយ ។

តែសេរីភាពដែលត្រាទុកក្នុងមាត្រានេះ មិនមែនជាសិទ្ធិដាច់ខាតដូចសេរីភាពខាងជំនឿទេ ព្រោះមានកម្រិត មានក្របខ័ណ្ឌ ។

ឯកម្រិតនោះមាន ៣ ប្រការ ៖

១.—មិនត្រូវប្រើដោយរំលោភ ។ ការរំលោភក្នុងទីនេះបានដល់ការជេរប្រមាថ មើលងាយគេដល់ការបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះគេជាដើម ។

២— មិនត្រូវធ្វើឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន ។ ការធ្វើឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន គឺធ្វើឲ្យខូចសុខក្នុងប្រទេស បានដល់ការនាំឲ្យកើតចលាចល នាំឲ្យបះបោរ នាំរាស្ត្រមិនឲ្យស្តាប់បង្គាប់រាជការ មិនឲ្យបង់ពន្ធជាដើម ។



៣— កម្រិតទាំងពីរប្រការខាងលើនេះមាននិយាយក្នុងវគ្គទី ១ ខាងចុង ។ តែនៅកម្រិតមួយទៀត ដែលនឹងមាននិយាយក្នុងមាត្រា ១៤ ។ កម្រិតនោះគឺថាកាលណាបើមានភយន្តរាយមកដល់ជាតិ ដូចជាក្នុងពេលចំបាំងជាដើម នោះរដ្ឋសភាអាចតាំងច្បាប់ឲ្យឈប់ប្រើសេរីភាពខាងការសំដែងគំនិតនេះបាន ។

ក្រៅអំពីកម្រិត ៣ ប្រការនេះ ការប្រើសេរីភាពខាងការបោះពុម្ព ត្រូវធ្វើទៅតាមលក្ខខ័ណ្ឌដែលមានត្រាទុកក្នុងច្បាប់ (មើលមាត្រា ៣) ។

របៀបប្រជាធិបតេយ្យ ជារបៀបដែលយកស្រេចតែលើសេចក្តីបំណងនៃភាគច្រើនរបស់ប្រជារាស្ត្រ ។ តាមន័យមួយទៀតគឺថាក្នុងរបៀបប្រជាធិបតេយ្យ រដ្ឋ(គឺរាជការ) មិនអាចធ្វើអ្វីតាមអំពើចិត្តបានឡើយ ត្រូវប្រតិបត្តិការឲ្យស្រេចតាមសេចក្តីយល់របស់ប្រជារាស្ត្រ ពោលគឺមតិមហាជន ។ មតិមហាជនមិនអាចកើតឡើងបាន ហើយគ្មាននរណាអាចដឹងមតិមហាជនបាន បើគ្មានសេរីភាពក្នុងការសំដែងគំនិតដែលត្រាទុកក្នុងមាត្រានេះ ។ ដូច្នេះត្រូវរាប់សេរីភាពនេះ ជាសេរីភាពសំខាន់បំផុត ក្នុងរបៀបប្រជាធិបតេយ្យ ។ គេតែងហៅសេរីភាពនេះ ថាសេរីភាពប្រជាធិបតេយ្យ

(liberté démocratique) ។ មានសេរីភាពប្រជាធិបតេយ្យ ២ យ៉ាងទៀត គឺសេរីភាពខាងការប្រជុំនិងសេរីភាពខាងការតាំងសមាគម ។

មាត្រា ១០ — ខេមរជនទាំងពួង មានសិទ្ធិរួបរួមគ្នាជាសមាគមដោយសេរី កុំឲ្យតែសមាគមនោះ ធ្វើឲ្យខូចសេរីភាពទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឲ្យមាន ។

ត្រូវបើកឲ្យមានសេរីភាពខាងការប្រជុំផងដែរ ។

សេចក្តីអធិប្បាយ:

វគ្គទី ១.— "រួបរួមគ្នាជាសមាគម" គឺព្រមព្រៀងគ្នារវាងបុគ្គលតាំងពីពីរនាក់ឡើងទៅ ដើម្បីរួមចំណេះ រួមប្រាជ្ញា រួមកំឡាំងគ្នា ស្វែងរកប្រយោជន៍ផ្សេងៗក្រៅពីប្រយោជន៍ដើម្បីចែកចំណេញគ្នា ។ "ក្រៅពីប្រយោជន៍ដើម្បីចែកចំណេញគ្នា" ប្រែសេចក្តីថា សមាគមដែលពោលក្នុងមាត្រានេះ មិនមែនជាសមាគមជំនួញទេ ។ ប្រយោជន៍ផ្សេងៗនោះគឺដូចជាប្រយោជន៍ ដើម្បីនឹងបណ្តុះបណ្តាលការហាត់ប្រាណ (ឧ. សមាគមកីឡា), ដើម្បីធ្វើឲ្យមានសាមគ្គីរវាងមនុស្ស ដែលធ្លាប់បានរៀនសូត្រក្នុងសាលាណាមួយដូចគ្នា



(ឧ. សមាគមសិស្សចាស់នៃសាលាវិទ្យាល័យស៊ីសុវត្ថិ), ដើម្បីនឹងគិតការនយោបាយ (ឧ. គណៈបក្សប្រជាធិបតេយ្យ) ដូច្នេះជាដើម ។

ពាក្យថា "ដោយសេរី" ប្រែថា តាមចិត្ត ។ ខេមរជនអាចតាំងសមាគមដូចមានឧទាហរណ៍ខាងលើនេះបាន មិនចាំបាច់មានអនុញ្ញាតពីរាជការ តែក៏គោរពធ្វើទៅតាមបែបបទដែលមានត្រាទុកក្នុងច្បាប់ដែរ ។ ក្របខ័ណ្ឌនៃសេរីភាព ក្នុងការតាំងសមាគម គឺការរក្សាសេរីភាពទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឲ្យមាន ។ ប្រែសេចក្តីថា បើសមាគមដែលយើងចង់តាំង មិនធ្វើឲ្យខូច ឬមិនញុំាងឲ្យខូចសេរីភាពទាំងឡាយ ដែលរដ្ឋធម្មនុញ្ញនេះធានាអះអាងឲ្យមាននោះទេ យើងមានសិទ្ធិតាំងសមាគមនោះជាដរាប រាជការមិនអាចឃាត់ហាមបានឡើយ ។

ធ្វើឲ្យខូចឬញុំាងឲ្យខូចសេរីភាពដែលរដ្ឋធម្មនុញ្ញធានាអះអាងឲ្យមាននោះគឺគិតបំបាត់គេ លួចគេ ប្លន់គេ ចាប់មនុស្សយកទៅបង្ខាំងបំពួនទុកឲ្យគេយកប្រាក់ទៅលោះជាដើម ។

ពាក្យ "ញុំាង" ដែលប្រើក្នុងទីនេះ មិនមែនបានសេចក្តីត្រឹមតែថា "ប្រើ" ថា "បង្គាប់" ប៉ុណ្ណោះទេ គឺបានសេចក្តីធំទូលាយទៅទៀតថា "បណ្តាល" ឬ "នាំ" ។

វគ្គទី២.– វគ្គទី១ ស្ដីអំពីសេរីភាពក្នុងការតាំងសមាគម, វគ្គទី២ ស្ដីអំពីសេរីភាពក្នុងការប្រជុំ ។ ការប្រជុំជាការរួបរួមគ្នាបែបការតាំងសមាគមដែរ, តែការប្រជុំគ្រាន់តែការជួបជុំគ្នា ការរួបរួមគ្នាមួយដងមួយគ្រា ដោយបានណាត់គ្នាជាមុនឬមិនបានណាត់គ្នាក៏មាន ។ ឯការតាំងសមាគម គឺជាការរួបរួមគ្នាជាប់ជាយូរកាលវេលា ។ ខេមរជនមានសិទ្ធិប្រជុំគ្នាដោយសេរី ដូចមានសិទ្ធិរួបរួមគ្នាជាសមាគមដែរ តែក៏ត្រូវប្រតិបត្តិតាមបែបបទដែលមានត្រាទុកក្នុងច្បាប់ផងដូចគ្នា ។

មាត្រា ១១.– ទីលំនៅ មិនត្រូវនរណាចូលទៅរុករានបានឡើយ ។ នឹងចូលទៅក្នុងទីលំនៅគេបាន តែក្នុងករណីដែលច្បាប់បានបញ្ញត្តទុក ហើយឲ្យត្រូវតាមរបៀបច្បាប់ផង ។

សេចក្ដីអធិប្បាយ.– រដ្ឋធម្មនុញ្ញហាមមិនឲ្យរុករានទីលំនៅគេ ។ ពាក្យថា "រុករានទីលំនៅគេ" ប្រែសេចក្ដីថាកាលអ្នកនៅក្នុងទីនោះឬអ្នកតំណាងអ្នកនៅក្នុងទីនោះ មិនបានព្រមឲ្យចូល ឬមិនបានដឹងឮ ។



ច្បាប់ដែលយើងប្រើសព្វថ្ងៃនេះ មានកំណត់ទោសសម្រាប់អ្នករុករានទីលំនៅគេ ដូចម្ដេចខ្លះ ?

ក្រមព្រហ្មទណ្ឌមានស្ដីអំពីការរុករានទីលំនៅគេ ក្នុងពីរមាត្រា គឺមាត្រា ២៤៤ នឹងមាត្រា ៤៤០ ។

មាត្រា ២៤៤ ពោលអំពីនាម៉ឺននឹងអ្នករាជការ ដែលរុករានទីលំនៅគេ ក្នុងឱកាសប្រតិបត្តិការមុខក្រសួងរបស់ខ្លួន ។ បុគ្គលចំពូកនេះ ត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ១ ។ បើកាលចូលទៅក្នុងទីលំនៅគេ ដោយរុករានដូច្នេះហើយ មានកំហែងឬវាយដំទៀតផង នោះត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ២ ឬទោសធ្ងន់លើសពីនោះទៅទៀត បើការវាយដំនោះជាទំងន់ឬមានការប្រើអាវុធផង ។

មាត្រា ៤៤០ ពោលអំពីជនធម្មតា ដែលរុករានទីលំនៅគេ ។ ជនដែលប្រព្រឹត្តដូច្នេះ ត្រូវទទួលទោសមជ្ឈិមថ្នាក់ទី ១ ។

តែក្នុងករណីខ្លះ ច្បាប់បើកឲ្យចូលទៅ ក្នុងទីលំនៅគេបានដោយឥតទោស ។ បុគ្គលដែលច្បាប់អនុញ្ញាតឲ្យចូលទៅក្នុងទីលំនៅគេបានដោយឥតទោស ហើយដោយមិនចាំបាច់ឲ្យអ្នកនៅក្នុងទីនោះ ឬអ្នកតំណាងអ្នកនៅក្នុងទីនោះយល់ព្រមផង នោះគឺនាម៉ឺននឹងអ្នកតំណាងរាជការ ដូចរាយរាប់តទៅនេះ ៖

១– កាលមានការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលទាន់ជាក់ស្តែង ក្នុងទីកន្លែងណា ព្រះរាជអាជ្ញាអាចចូលទៅកាន់ទីកន្លែងនោះ ហើយអាចចូលទៅក្នុងទីលំនៅអ្នកប្រព្រឹត្តបទល្មើសនោះ ដើម្បីឆែកឆេរ (មាត្រា ៨១ និង ៨២ ក.ព.ព) ។

២– សុភាចារបុរសអាចចូលទៅក្នុងទីលំនៅអ្នកត្រូវចោទបាន ដើម្បីនឹងឆែកឆេររកភស្តុតាង ហើយនឹងប្រតិបត្តិការគ្រប់យ៉ាង ដែលជាប្រយោជន៍ក្នុងការរកសេចក្តីពិត (មាត្រា ១៤៩ ក.ព.ព.) ។

៣– កាលមានការប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលទាន់ជាក់ស្តែង ច្បាប់អនុញ្ញាតឲ្យនាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌ (ដូចមានរាយរាប់ក្នុងកាសែតយើងលេខ ៦៤) ចូលឆែកឆេរទីលំនៅគេបាន មិនថាពេលថ្ងៃ ឬពេលយប់ ត្រូវមានមនុស្សត្រឹមត្រូវពីនាក់ទៅជាមួយ ជាសាក្សីផង (មាត្រា ៥៩ ក.ព.ព.) ។

៤– នាយភ្នាក់ងារក្រុមនគរបាលយុត្តិធម៌អាចចូលទៅក្នុងទីលំនៅគេបាន ដើម្បីសំរេចតាមសាលក្រម ឬតាមដីកានាំខ្លួន ឬដីកាចាប់ខ្លួន បើពុំនោះសោត ត្រូវមានគេហៅពីក្នុងទីលំនៅមកទើបចូលទៅបាន (មាត្រា ២៥៦ ក.ព.) ។



មាត្រា ១២.–សំបុត្រដែលផ្ញើទៅមករកគ្នា មិនត្រូវនរណាបើកមើលបានឡើយ វៀរលែងតែមានច្បាប់អនុញ្ញាតដោយជាក់ស្តែងជាបណ្តោះអាសន្នឲ្យបើក ក្នុងវេលាដែលប្រយោជន៍យ៉ាងធំរបស់ប្រជាជាតិ បង្គាប់ឲ្យធ្វើដោយខានពុំបាន ។

សេចក្តីអធិប្បាយ.– រដ្ឋធម្មនុញ្ញហាមមិនឲ្យបើកមើលសំបុត្រដែលគេផ្ញើទៅមករកគ្នា ។ ប៉ុន្តែក្នុងករណីខ្លះ រដ្ឋធម្មនុញ្ញអនុញ្ញាតឲ្យបើកមើលបាន ។

ករណីនោះយ៉ាងណាខ្លះ? គឺក្នុងវេលាដែលប្រយោជន៍យ៉ាងធំរបស់ប្រជាជាតិបង្គាប់ឲ្យធ្វើដោយខានពុំបាន ដូចជាក្នុងពេលសង្គ្រាមចលាចលក្នុងប្រទេសជាដើម ។ ក្នុងពេលអាសន្នយ៉ាងនេះ រដ្ឋាភិបាលត្រូវការស៊ើបរកមនុស្សក្បត់ជាតិ មនុស្សចូលដៃនឹងសត្រូវ ឲ្យដំណឹងទៅសត្រូវ ឬទទួលបង្គាប់ពីសត្រូវឲ្យធ្វើឃាតកម្មឬវិនាស-កម្មផ្សេងៗ ។

ក្នុងករណីដូច្នេះ នរណាដែលរដ្ឋធម្មនុញ្ញអនុញ្ញាតឲ្យបើកសំ-បុត្រគេមើលបាន? គឺរដ្ឋាភិបាល មិនមែនឯកជនទេ ។ នរណានឹងវិនិច្ឆ័យថាវេលាដល់ហើយ ល្មមត្រូវបើកសំបុត្រគេមើលបាន? ការ

វិនិច្ឆ័យនេះ រដ្ឋធម្មនុញ្ញមិនប្រគល់ឲ្យរដ្ឋាភិបាលទេ ព្រោះរដ្ឋាភិបា[ល] ជាអ្នកត្រូវការបើកសំបុត្រគេមើល រដ្ឋាភិបាលអាចរំលោភលើសិទ្ធិ[...] បុគ្គល បេះតែវិនិច្ឆ័យថា ដល់វេលាគួរឲ្យបើកសំបុត្រគេមើលហើ[យ] ដូច្នេះទៅក៏សឹងបាន ។ ហេតុនេះ ទើបរដ្ឋធម្មនុញ្ញប្រគល់សិទ្ធិវិនិច្ឆ័[យ] សេចក្ដីនេះ ទៅលើរដ្ឋសភាដែលជាទីតំណាងបុគ្គលពលគ្នា ។ យើ[ង] ពោលដូច្នេះ ព្រោះមាត្រានេះបញ្ញត្តថា «វៀរលែងតែមានច្បា[ប់] អនុញ្ញាត» ។ ពាក្យថា ច្បាប់មួយមាត់នេះ សំដែងថារដ្ឋសភាជាអ្[នក] អនុញ្ញាត ដ្បិតមានតែរដ្ឋសភាប៉ុណ្ណឹងទេ ដែលជាអ្នកតាំងច្បា[ប់] (មាត្រា៦៤) ។

ច្បាប់ដែលរដ្ឋសភាតាំងឡើង ដើម្បីអនុញ្ញាតឲ្យបើកសំបុ[ត្រ] គេមើលបាននោះសោត ត្រូវមានលក្ខណៈពីរយ៉ាងទៀតផង ទើ[ប] ប្រើការបាន៖ ១) ត្រូវដាក់ឲ្យជាក់ច្បាស់ថាបើកអំណាចឲ្យបើ[ក] សំបុត្រគេមើល, ២) ត្រូវដាក់ថាការបើកអំណាចនេះ ជាកា[រ] បណ្ដោះអាសន្ន មិនមែនបើកអំណាចជានិច្ចរហូតទៅទេ ។

មាត្រា ១៣.– ខេមរជនទាំងពួង ត្រូវទទួលតំណែងរាជការបានដូច[...] គ្នា ។ ក្រៅអំពីគុណសម្បត្តិ និងសមត្ថភាពរបស់សាមីខ្លួន គ្មានអ្វីជាហេតុបណ្ដាល[...] ឲ្យជននេះទទួលបាន ជននោះទទួលពុំបានទេ ។



សេចក្ដីអធិប្បាយ.– គុណសម្បត្តិគឺសេចក្ដីល្អ សេចក្ដីបរិសុទ្ធិ ។ សមត្ថភាព គឺសេចក្ដីអាច សេចក្ដីលុះ ដំណើរធ្វើកើត ។ មាត្រានេះស្ដីអំពីសមភាពនៃខេមរជនដែលនឹងទទួលតំណែងរាជការបាន។ រដ្ឋធម្មនុញ្ញបញ្ញត្តថា ក្នុងការរកមនុស្សឲ្យទទួលតំណែងរាជការ ត្រូវជ្រើសយកតែមនុស្សណាជាមនុស្សល្អជាងគេ បេះធ្វើការក្នុងតំណែងនោះជាងគេឲ្យធ្វើ មិនត្រូវជ្រើសដោយយល់មុខ មិនត្រូវគិតដល់ហេតុអ្វី ក្រៅពីគុណសម្បត្តិនិងសមត្ថភាពនៃមនុស្សនោះយកមកជាទីតាំងឡើយ ។

ដែលមានបញ្ញត្តិដូច្នេះ ក៏ព្រោះតែប្រទេសខ្លះដូចជាប្រទេសបារាំងសម័យមុនជាង ១៥០ឆ្នាំមកហើយ មានច្បាប់តម្រូវថា បើមិនមែនជាអភិជន គឺមិនមែនជាមនុស្សមានត្រកូលខ្ពស់ទេ នឹងទទួលតំណែងជានាយទាហានពុំបាន ។ រដ្ឋធម្មនុញ្ញយើង ហាមមិនឲ្យតាំងច្បាប់តាមទំនងនេះបានឡើយ ។

មាត្រា ១៤.– ខេមរជនមួយៗ មានសិទ្ធិចូលពាក្យប្ដឹងទៅអ្នកកាន់អំណាចសាធារណៈបាន ដើម្បីនាំឲ្យមានការពិចារណាបញ្ហាទាំងឡាយ ដែលមានផលប្រយោជន៍ចំពោះបុគ្គលឬដល់មហាជន ។

សេចក្តីអធិប្បាយ.— ការដែលបើកឲ្យខេមរជន មានសិទ្ធិនិងសេរីភាពដូចក្នុងមាត្រាទាំងឡាយខាងលើនេះ ជាការគាប់ប្រសើរណាស់ហើយ តែមិនមែនជាការណ៍គ្រប់គ្រាន់ទេ ។ ទើបក្នុងមាត្រានេះ រដ្ឋធម្មនុញ្ញបើកផ្លូវឲ្យខេមរជនការពារសិទ្ធិនិងសេរីភាពទាំងនោះបាន កាលបើរដ្ឋធ្វើឲ្យប៉ះពាល់ដល់សិទ្ធិនិងសេរីភាពនោះៗ បុគ្គលពលរូប កាលបើត្រូវរដ្ឋ(គឺរាជការ) ធ្វើបាបសង្កត់សង្កិន ក៏រមែងមានសេចក្តីក្តៅក្រហាយក្នុងចិត្តជាធម្មតា ។ បើកាលណាក្តៅក្រហាយហើយ ត្រូវគេបំបិទមាត់មិនឲ្យស្រែកទៀត ឬស្រែកទៅហើយគេមិនស្បៀតនឹងឮទៀត នោះសេចក្តីទោមនស្សក៏កាន់តែខ្លាំងណាស់ឡើង មិនងាយនឹងទ្រាំបាន ។

ដោយហេតុនេះ ទើបរដ្ឋធម្មនុញ្ញបញ្ញត្តថា ខេមរជនមានសិទ្ធិចូលពាក្យប្តឹងសុំទៅអ្នកកាន់អំណាចសាធារណៈ ។ ពាក្យថាសិទ្ធិបានសេចក្តីថា រដ្ឋធម្មនុញ្ញបង្ខំឲ្យអ្នកកាន់អំណាចសាធារណៈទទួលពាក្យប្តឹងសុំពីអ្នកមានទុក្ខមិនសុខចិត្ត ។ តាមន័យមួយទៀតគឺថា រដ្ឋធម្មនុញ្ញតាំងទុកជាករណីយកិច្ចរបស់អ្នកកាន់អំណាចសាធារណៈ ដែលនឹងទទួលពាក្យប្តឹងសុំពីអ្នកមានទុក្ខមិនសុខចិត្ត ។



ពាក្យថា អ្នកកាន់អំណាចសាធារណៈ បានដល់អ្នកកាន់អំណាចទាំងបីយ៉ាង គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

តាមធម្មតាអ្នកទទួលទុក្ខមិនសុខចិត្ត ដោយរាជការធ្វើឲ្យខូចសិទ្ធិនិងសេរីភាព ដែលរដ្ឋធម្មនុញ្ញធានាអះអាងឲ្យខ្លួនមាន អាចតវ៉ាដោយវិធីច្រើនយ៉ាង ៖

១- អ្នកទទួលទុក្ខអាចចូលពាក្យប្តឹងសុំទៅដល់អ្នករាជការណាដែលបានចាត់ការ បណ្តាលឲ្យក្តៅក្រហាយដល់ខ្លួន ដើម្បីឲ្យកែប្រែការដែលបានចាត់ទៅហើយនោះចេញ ;

២- អ្នកទទួលទុក្ខ អាចចូលពាក្យប្តឹងសុំដល់ចៅហ្វាយអ្នករាជការ ដែលបានចាត់ការបណ្តាលឲ្យក្តៅក្រហាយដល់ខ្លួន ដើម្បីឲ្យលុបលាងការដែលបានចាត់ទៅហើយនោះចេញ;

៣ – ខេមរជនអាចចូលពាក្យប្តឹងសុំដល់រដ្ឋសភា អំពីការណ៍ដែលរដ្ឋាភិបាលបានប្រើអំណាចរំលោភលើខ្លួន នេះជាបញ្ហាដែលមានផលប្រយោជន៍ចំពោះបុគ្គល ឬមួយអំពីការរៀបចំច្បាប់ថ្មីឡើងទៀត ឬកែសម្រួលច្បាប់ដែលមានមកហើយ (នេះជាបញ្ហា ដែលមានផលប្រយោជន៍ដល់មហាជន ) ។

រដ្ឋសភាចាត់ឲ្យមានគណៈកម្មការមួយពិនិត្យពាក្យប្ដឹងសុំទាំង ឡាយ ដែលបានទទួលពីគណៈកម្មការ ហើយអាចបញ្ជូនពាក្យប្ដឹងសុំនោះទៅរដ្ឋមន្ត្រីមុខក្រសួង ឬមួយដាក់ឲ្យរដ្ឋសភាពិចារណា ឬមួយទៀតសុំឲ្យរដ្ឋសភាវិនិច្ឆ័យជាមុនថា ត្រូវដាក់ទុកពាក្យប្ដឹងនោះទៅយ៉ាងណា ។

សេចក្ដីសង្កេត.– នៅប្រទេសបារាំង មានសាលាជំនុំ មួយឈ្មោះកុងស៊ីដេតាត៍ (Conseil d'Etat) សំរាប់ទទួលជំរះក្ដី ក្នុងការណ៍ដែលរដ្ឋាភិបាលប្រព្រឹត្តលើសកំណត់អំណាចរបស់ខ្លួន ។

នៅប្រទេសខ្លះ ដូចសហរដ្ឋអាមេរិក សាលាតុលាការជាន់ ភាមានអំណាចមិនព្រមយកច្បាប់ណាមួយមកប្រើកាត់សេចក្ដីបា កាលបើទៅក្រមយល់ថា ច្បាប់នោះទើសទាស់នឹងរដ្ឋធម្មនុញ្ញ

មាត្រា ១៩.– ការប្រើសិទ្ធិទាំងឡាយដែលរដ្ឋធម្មនុញ្ញនេះធានាអះអា មិនត្រូវបង្អាក់បង្អង់បានឡើយ ។ ប៉ុន្តែបើប្រជាជាតិត្រូវប្រកាសថានៅក្នុងភយន្តរាយ នោះសិទ្ធិដែលមានពណ៌នាក្នុងមាត្រា ៤-៩ (វគ្គទី១) -១០(វគ្គទី២) នឹង១២អា ត្រូវបង្អាក់ឲ្យឈប់ប្រើសិនបាន តាមកំរិតនឹងរបៀបដែលមានបញ្ញត្តទុកក្នុងច្បាប់ ។



ការបង្អាក់បង្អង់នេះ មិនត្រូវឲ្យលើសពីប្រាំមួយខែ ប៉ុន្តែនឹងបន្តជាថ្មីទៀតតាមរបៀបដដែលក៏បាន ។

ជនណារំលោភប្រើការបង្អាក់បង្អង់នេះ ដើម្បីធ្វើតាមទំនើងចិត្តឲ្យខូចសិទ្ធិអ្នកដទៃខាងភោគទ្រព្យក្ដី ខាងផ្លូវចិត្តក្ដី ជននោះត្រូវទទួលខុសត្រូវក្នុងបទនេះដោយផ្ទាល់ខ្លួន ។

ដល់ផុតពេលបង្អាក់បង្អង់នេះហើយ ជនណាយល់ថាខ្លួនត្រូវគេធ្វើតាមទំនើងចិត្តឲ្យឈឺចាប់ដល់រាងកាយក្ដី ឲ្យខូចខាតដល់ភោគទ្រព្យក្ដី ជននោះអាចប្ដឹងសាលាជំរះក្ដី ឲ្យជួសជុលខាងផ្លូវចិត្ត ឬខាងធនធានបាន ។

សេចក្ដីអធិប្បាយ.– មាត្រានេះមាន ៤វគ្គ ។

វគ្គទី ១– មាត្រាទាំងឡាយក្នុងជំពូក ២ នេះ រាប់តាំងពីមាត្រា ៣ រៀងមកពណ៌នាអំពីសិទ្ធិនៃបុគ្គល ដែលរដ្ឋធម្មនុញ្ញធានាអះអាងឲ្យមាន ។ ការណ៍ដែលរដ្ឋធម្មនុញ្ញព្រមទទួលស្គាល់សិទ្ធិទាំងនោះ សម្រាប់បុគ្គលនីមួយ ៗ ក៏ដូចជារដ្ឋធម្មនុញ្ញកំណត់អំណាចរបស់រដ្ឋឲ្យមានក្របខណ្ឌសីមា កុំឲ្យរដ្ឋប្រព្រឹត្តក្រៅពីក្របខ័ណ្ឌនោះបៀតបៀនដល់បុគ្គលនីមួយ ៗ បាន ។ ទាំងនេះក៏ព្រោះអ្នកតែងរដ្ឋធម្មនុញ្ញមានបំណងមិនឲ្យរដ្ឋសង្កត់សង្កិនបុគ្គល

នីមួយៗបាន ទើបក្នុងវគ្គទី ១ នេះមានដំរាមមិនឲ្យរដ្ឋបង្អាក់បង្ខានការប្រើសិទ្ធិនៃខេមរជន ។

ប៉ុន្តែកាលបើមានភយន្តរាយមកដល់ជាតិ ដូចជា មានការបះបោរក្នុងប្រទេស ឬ មានសត្រូវពីក្រៅ ចូលមកលុកលុយប្រទេសយើង នោះរដ្ឋត្រូវការពារសេចក្តីស្ងប់រៀបរយក្នុងប្រទេស ឬត្រូវការពារប្រទេសតយុទ្ធនឹងសត្រូវដែលមករុករាន ។ ក្នុងការការពារទាំងពីរយ៉ាងនេះ រដ្ឋរមែងត្រូវការមានអំណាចច្រើនឡើងទៀតចំពោះបុគ្គលនីមួយ ៗ នឹងអាក់ខានពុំបាន ៖ ដូចជាត្រូវការបន្ថយសេរីភាពខាងរាងកាយ (មាត្រា ៨) ក្នុងការដែលត្រូវចាប់ ឬឃុំឃាំងមនុស្សក្បត់ជាតិនឹងចារបុរស (espions) ដែលស៊ើបការណ៍ឲ្យសត្រូវជាដើម ; ត្រូវការបន្ថយសេរីភាពខាងការនិយាយ ការសរសេរ ការបោះពុម្ពនឹងការផ្សាយដល់មហាជន (មាត្រា ៩ វគ្គទី ១) ដែលអាចនាំឲ្យសត្រូវដឹងការសម្ងាត់របស់ជាតិយើង ឬអាចនាំឲ្យខេមរជនបែកសាមគ្គីរវាងគ្នាឯង ; ត្រូវការហាមមិនឲ្យមានការប្រជុំ (មាត្រា ១០ វគ្គទី ២) ដែលអាចនាំឲ្យមានចលាចលក្នុងប្រទេស ត្រូវ



ការបើកមើលសំបុត្រដែលផ្ញើទៅមករកគ្នា (មាត្រា ១២) ដើម្បីរកមើលក្រែងមានមនុស្សក្បត់ជាតិឬសត្រូវសំឡិបដំណឹងឲ្យគ្នា នឹងបានចាត់ការតាមករណី ។

ដោយហេតុប្រយោជន៍ជនទាំងជាតិធំជាងប្រយោជន៍ជននីមួយ ៗ រដ្ឋធម្មនុញ្ញទើបបើកឲ្យបង្អាក់បង្ខានប្រើសិទ្ធិទាំងនេះបាន ។ ប៉ុន្តែអ្នកតែងរដ្ឋធម្មនុញ្ញមានបារម្ភ ក្រែងរដ្ឋាភិបាលចង់មានអំណាចច្រើនលើបុគ្គល ក៏ចេះតែប្រកាសថា "ប្រជាជាតិនៅក្នុងភយន្តរាយទៅ ដោយឥតហេតុផលសមល្មម" ទើបដាក់បញ្ញត្តិថា "ការបង្អាក់បង្ខានត្រូវធ្វើទៅ "តាមកំរិតនឹងរបៀបដែលមានបញ្ញត្តទុកក្នុងច្បាប់" ។

ពាក្យខាងក្រោយនេះ បានសេចក្តីថារដ្ឋសភា (គឺតំណាងទាំងឡាយរបស់រាស្ត្រ) ជាអ្នកប្រកាសថា "ប្រជាជាតិនៅក្នុងភយន្តរាយ មិនមែនរដ្ឋាភិបាលទេ" ។ យើងត្រូវយល់ថាដូច្នេះ ព្រោះមានតែរដ្ឋសភាប៉ុណ្ណោះទេ ដែលជាអ្នកធ្វើច្បាប់ (មើលមាត្រា ៦៨) ។

វគ្គទី ២.— អ្នកតែងរដ្ឋធម្មនុញ្ញមានបារម្ភមួយយ៉ាងទៀត គឺក្រែងរដ្ឋាភិបាលបានសុំឲ្យរដ្ឋសភាចេញច្បាប់បង្អាក់បង្ខានការប្រើសិទ្ធិនៃបុគ្គលបានរួចហើយ ក៏រំលោភប្រើច្បាប់នោះ យូរអង្វែងហួសការចាំបាច់ពិត ៗ ទៅទៀត នឹងនាំឲ្យប្រជារាស្ត្របានសេចក្តីក្តៅក្រហាយ

ឥតប្រយោជន៍ ។ ហេតុនេះបានជាកំណត់វេលាឲ្យប្រើច្បាប់នោះបាន ត្រឹមតែ ៦ ខែ ។ បើរដ្ឋាភិបាលត្រូវការបង្អាក់បង្អង់ការប្រើសិទ្ធិនៃ បុគ្គលយូរទៅទៀត ត្រូវសុំឲ្យរដ្ឋសភាចេញច្បាប់ឲ្យម្តងទៀត ។

វគ្គទី ៣ .— ដើម្បីបង្ការមិនឲ្យអ្នករាជការឆ្លៀតឱកាស ក្នុង ពេលដែលប្រជាជាតិនៅក្នុងភយន្តរាយដូច្នេះ ធ្វើឲ្យខូចសិទ្ធិអ្នកដទៃ ខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី តាមទំនើងចិត្តខ្លួន រដ្ឋធម្មនុញ្ញបើក ឲ្យអ្នកទទួលទុក្ខប្តឹងឲ្យអ្នករាជការដែលធ្វើរំលោភនោះ ទទួលខុសត្រូវ ដោយផ្ទាល់ខ្លួន ។ "ធ្វើឲ្យខូចសិទ្ធិខាងភោគទ្រព្យ" គឺធ្វើបំពានលើ កម្មសិទ្ធិ ធ្វើឲ្យខូចខាតសម្បត្តិគេ ។ "ធ្វើឲ្យខូចសិទ្ធិខាងផ្លូវចិត្ត" គឺធ្វើឲ្យខូចកិត្តិយស ខូចកេរ្តិ៍ឈ្មោះ អាប់មុខ·អាប់មាត់គេជាដើម ។ កាលណា ទើបអ្នកទទួលទុក្ខមានសិទ្ធិប្តឹងបាន ?

វគ្គទី៤— វគ្គនេះបញ្ជាក់សេចក្តីក្នុងវគ្គទី ៣ ហើយស្តីអំពីពេល ដែលអ្នកទទួលទុក្ខប្តឹងបាន គឺក្រោយពេលដែលប្រជាជាតិនៅក្នុង ភយន្តរាយ ព្រោះក្នុងពេលនោះគេរមែងប្រើច្បាប់ពិសេស ហៅថា ច្បាប់អាជ្ញាសឹក ។



មាត្រា ១៦.— ខេមរជននីមួយៗ ត្រូវមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ត្រូវមានករណីយកិច្ចគោរពប្រតិបត្តិច្បាប់ ការពារប្រទេស ហើយជួយរដ្ឋាភិបាលដោយ បង់ពន្ធដារនឹងដោយវិធីគ្រប់យ៉ាងដែលមានបញ្ញត្តទុកក្នុងច្បាប់ ។

សេចក្តីអធិប្បាយ.— មាត្រាទាំងឡាយដែលយើងបាន អធិប្បាយមកហើយក្នុងជំពូកទី២នេះ បញ្ញត្តអំពីសិទ្ធិនៃខេមរជន នីមួយៗ ប៉ុន្តែកាលមានសិទ្ធិ ក៏ត្រូវមានករណីយកិច្ចផងជាគូគ្នា ។ ហេតុនេះទើបរដ្ឋធម្មនុញ្ញ ក្នុងមាត្រា ១៦ នេះ បញ្ញត្តអំពីករណីយ កិច្ចរបស់ខេមរជននីមួយៗ ចំពោះរដ្ឋ គឺចំពោះខេមរជនទាំង ពួងដែលរួមគ្នាជាសង្គម ព្រមទាំងករណីយកិច្ចចំពោះព្រះមហាក្សត្រិយ៍ដែលជាទីតំណាងយ៉ាងខ្ពស់បំផុតរបស់រដ្ឋ ។

ករណីយកិច្ចដែលមានពណ៌នាក្នុងមាត្រានេះ មាន៤យ៉ាង ៖

១— សេចក្តីស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ។ ក្នុងរបៀប ប្រជាធិបតេយ្យ ព្រះមហាក្សត្រិយ៍ទ្រង់សោយរាជ្យសម្បត្តិ តែមិន ទ្រង់គ្រប់គ្រងប្រទេសទេ ។ ការគ្រប់គ្រងប្រទេសជាភារៈលើប្រជា រាស្ត្រដែលនឹងជ្រើសតាំងអ្នកតំណាងឲ្យរៀបចំរដ្ឋាភិបាលហើយត្រួត មើលការប្រព្រឹត្តិនៃរដ្ឋាភិបាល ។ ការផែនដីនឹងចំរើនឬនឹងវិនាស ទៅអនាគត ក៏ស្រេចតែលើប្រជារាស្ត្រ ។ មិនត្រូវគាត់អន់ចិត្តនឹងព្រះ-

ឥតប្រយោជន៍ ។ ហេតុនេះបានជាកំណត់វេលាឲ្យប្រើច្បាប់នោះបានត្រឹមតែ ៦ ខែ ។ បើរដ្ឋាភិបាលត្រូវការបន្អាក់បន្ថានការប្រើសិទ្ធិនៃបុគ្គលយូរទៅទៀត ត្រូវសុំឲ្យរដ្ឋសភាចេញច្បាប់ឲ្យម្តងទៀត ។

វគ្គទី ៣ .— ដើម្បីបង្ការមិនឲ្យអ្នករាជការឆ្លៀតឱកាស ក្នុងពេលដែលប្រជាជាតិនៅក្នុងភយន្តរាយដូច្នេះ ធ្វើឲ្យខូចសិទ្ធិអ្នកដទៃខាងភោគទ្រព្យក្តី ខាងផ្លូវចិត្តក្តី តាមទំនើងចិត្តខ្លួន រដ្ឋធម្មនុញ្ញបើកឲ្យអ្នកទទួលទុក្ខប្តឹងឲ្យអ្នករាជការដែលធ្វើរលោភនោះ ទទួលខុសត្រូវដោយផ្ទាល់ខ្លួន ។ "ធ្វើឲ្យខូចសិទ្ធិខាងភោគទ្រព្យ" គឺធ្វើបំពានលើកម្មសិទ្ធិ ធ្វើឲ្យខូចខាតសម្បត្តិគេ ។ "ធ្វើឲ្យខូចសិទ្ធិខាងផ្លូវចិត្ត" គឺធ្វើឲ្យខូចកិត្តិយស ខូចកេរ្តិ៍ឈ្មោះ អាប់មុខ·អាប់មាត់គេជាដើម ។ កាលណា ទើបអ្នកទទួលទុក្ខមានសិទ្ធិប្តឹងបាន ?

វគ្គទី៤— វគ្គនេះបញ្ជាក់សេចក្តីក្នុងវគ្គទី ៣ ហើយស្តីអំពីពេលដែលអ្នកទទួលទុក្ខប្តឹងបាន គឺក្រោយពេលដែលប្រជាជាតិនៅក្នុងភយន្តរាយ ព្រោះក្នុងពេលនោះគេរមែងប្រើច្បាប់ពិសេស ហៅថា ច្បាប់អាជ្ញាសឹក ។



មាត្រា ១៦.— **ខេមរជននីមួយៗ ត្រូវមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ត្រូវមានករណីយកិច្ចគោរពប្រតិបត្តិច្បាប់ ការពារប្រទេស ហើយជួយរដ្ឋាភិបាលដោយបង់ពន្ធដារនឹងដោយវិធីគ្រប់យ៉ាងដែលមានបញ្ញត្តទុកក្នុងច្បាប់ ។**

សេចក្តីអធិប្បាយ.— មាត្រាទាំងឡាយដែលយើងបានអធិប្បាយមកហើយក្នុងជំពូកទី២នេះ បញ្ញត្តអំពីសិទ្ធិនៃខេមរជននីមួយ ៗ ប៉ុន្តែកាលមានសិទ្ធិ ក៏ត្រូវមានករណីយកិច្ចផងជាគូគ្នា ។ ហេតុនេះទើបរដ្ឋធម្មនុញ្ញ ក្នុងមាត្រា ១៦ នេះ បញ្ញត្តអំពីករណីយកិច្ចរបស់ខេមរជននីមួយ ៗ ចំពោះរដ្ឋ ពោលគឺចំពោះខេមរជនទាំងពួងដែលរួមគ្នាជាសង្គម ព្រមទាំងករណីយកិច្ចចំពោះព្រះមហាក្សត្រិយ៍ដែលជាទីតំណាងយ៉ាងខ្ពស់បំផុតរបស់រដ្ឋ ។

ករណីយកិច្ចដែលមានពណ៌នាក្នុងមាត្រានេះ មាន៤យ៉ាង ៖

១— សេចក្តីស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍ ។ ក្នុងរបៀបប្រជាធិបតេយ្យ ព្រះមហាក្សត្រិយ៍ទ្រង់សោយរាជ្យសម្បត្តិ តែមិនទ្រង់គ្រប់គ្រងប្រទេសទេ ។ ការគ្រប់គ្រងប្រទេសជាភារៈលើប្រជារាស្ត្រដែលនឹងជ្រើសតាំងអ្នកតំណាងឲ្យរៀបចំរដ្ឋាភិបាលហើយត្រួតមើលការប្រព្រឹត្តិនៃរដ្ឋាភិបាល ។ ការដែនដីនឹងចម្រើនឬនឹងវិនាសទៅអនាគត ក៏ស្រេចតែលើប្រជារាស្ត្រ ។ មិនត្រូវគាត់អន់ចិត្តនឹងព្រះ-

តំណាងរបស់ប្រជាជាតិ ។ សេចក្ដីត្រង់នេះមានបញ្ជាក់ឲ្យច្បាស់លាស់ថែមទៀតក្នុងមាត្រា ៦៤ ដែលបញ្ញត្តថា " មានតែរដ្ឋសភាប៉ុណ្ណោះទេដែលមានសិទ្ធិបញ្ចេញមតិតាំងច្បាប់ " ។ រដ្ឋធម្មនុញ្ញបញ្ញត្តដូច្នេះ ក៏ព្រោះចង់ឲ្យច្បាប់ទាំងឡាយ មានច្បាប់ស្ដីអំពីពន្ធដារជាដើម សមល្មមតាមចិត្តប្រជារាស្ត្រទាំងអស់ កុំឲ្យមានសេចក្ដីក្ដៅក្រហាយដល់រាស្ត្រពេក ។

វាក្យៈទី ២ នៃវគ្គនេះ បញ្ញត្តអំពីសមភាពនៃខេមរជនចំពោះច្បាប់ ។ ច្បាប់ត្រូវប្រើទៅលើជនទាំងអស់ ដោយស្មើមុខគ្នា ។ ឧទាហរណ៍ដូចជាច្បាប់ដែលឃុំគ្រងទីលំនៅ រក្សាការពារមិនឲ្យនរណារុករាន ។ ច្បាប់មិនមែនគ្រាន់មិនឲ្យរុករានតែទីលំនៅក្សត្រិយ៍ នាម៉ឺនធំ ៗ ឬសេដ្ឋីទេ ។ សូម្បីតែទីលំនៅអ្នកក្រីក្រថោកទាបដូចម្ដេច ក៏ត្រូវហាមមិនឲ្យរុករានដូចគ្នា ។ ឧទាហរណ៍មួយទៀតដូចជាច្បាប់បញ្ញត្តថា ជនណាឆបោកគេត្រូវជាប់ទោសមជ្ឈិមថ្នាក់ទី ៣ ។ បើទោះជនឆបោកគេនោះ ជាមនុស្សខ្ពង់ខ្ពស់ ឬថោកទាបយ៉ាងណាក៏ដោយ ក៏ត្រូវជាប់ទោសមជ្ឈិមទី ៣ដូចគ្នា ។ ឧទាហរណ៍មួយវិញទៀត គឺឧបមាថាច្បាប់បង្ខំឲ្យក្មេងស្រីប្រុសចូលរៀនទាំងអស់គ្នា នោះកូននរណាក៏ដោយត្រូវចូលរៀនដូចគ្នា គ្មានរើសមុខ ។



វគ្គទី២.- រដ្ឋធម្មនុញ្ញបែបប្រជាធិបតេយ្យនេះប្រគល់អំណាចឲ្យរដ្ឋសភាច្រើនណាស់ ។ រដ្ឋសភាអាចធ្វើច្បាប់យ៉ាងណាបានតាមចិត្ត ។ ដូច្នេះអ្នកតែងរដ្ឋធម្មនុញ្ញបារម្ភថា ក្រែងរដ្ឋសភាតាំងច្បាប់ណាមួយលុបលាងសិទ្ធិនៃបុគ្គល ដែលមានរាយរាប់ក្នុងរដ្ឋធម្មនុញ្ញនេះ ដូចជាលុបសេរីភាពខាងការនិយាយ សរសេរ បោះពុម្ព ឬលុបសេរីភាពខាងការប្រជុំនិងតាំងសមាគមជាដើម ដែលនាំឲ្យខូចរបៀបប្រជាធិបតេយ្យ ។ ទើបដាក់កំរិតមិនឲ្យរដ្ឋសភាតាំងច្បាប់ ធ្វើឲ្យខូចសេរីភាពនិងសិទ្ធិ ដែលមានរាយរាប់ក្នុងចំពូកទី ២ មុននេះ ។

**មាត្រា ១៨.-** ច្បាប់ធានាអះអាងឲ្យមនុស្សទាំងពួងមានសិទ្ធិឲ្យតុលាការទទួលជំនុំជំរះ ។ សេចក្ដីខ្វះខាតធនធានមិនគ្រប់គ្រាន់ មិនអាចជាឧបសគ្គក្នុងការឲ្យតុលាការទទួលជំនុំជំរះនេះបានឡើយ ។

សេចក្ដីអធិប្បាយ.- មាត្រានេះបញ្ញត្តអំពីសមភាពក្នុងការប្ដឹងតុលាការឲ្យជំនុំជំរះក្ដី ។ ពាក្យថា " មានសិទ្ធិ " ប្រែថារដ្ឋធម្មនុញ្ញបង្គាប់ឲ្យសាលាជំរះក្ដីទទួលជំនុំជំរះឲ្យអ្នកប្ដឹងរាល់រូបដោយមិនរើសមុខ បើទោះបីអ្នកប្ដឹងនោះក្រីក្រគ្មានប្រាក់បង់ជូន

សាលា ក៏សាលាត្រូវទទួលជំនុំជំរះដែរ ឲ្យតែពិនិត្យទៅឃើញថាក្រែក្រពិតមែន ។

មាត្រា ១៩.– វៀរលែងតែមានបញ្ញត្តិពិសេសដោយដាក់ច្បាស់ក្នុងច្បាប់ ច្បាប់មិនត្រូវយកទៅប្រើលើអំពើដែលកន្លងទៅហើយមុនពេលឲ្យប្រតិបត្តិតាមនោះទេ ។ ប៉ុន្តែជនណាក៏ដោយ នឹងអាចត្រូវតុលាការជំនុំជំរះនឹងដាក់ទណ្ឌកម្មបាន លុះតែជននោះបានប្រព្រឹត្តបទល្មើសមានក្នុងច្បាប់ណាមួយដែលបានប្រកាសឲ្យប្រើហើយ ហើយដែលត្រូវប្រើមុនមានបទល្មើសនោះ ។

សេចក្តីអធិប្បាយ.– ខេមរជនមានករណីយកិច្ចប្រតិបត្តិតាមច្បាប់ ។ វគ្គទី២នៃមាត្រា៣បញ្ញត្តថា៖ "អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ" ។ ប្រែសេចក្តីថា បើច្បាប់មិនបង្គាប់ឲ្យធ្វើនូវអំពើអ្វីមួយ ជនណាក៏ដោយអាចមិនធ្វើនូវអំពើនោះបានឥតមានទោសភ័យអ្វីឡើយ ។ ប៉ុន្តែកាលបើមិនបានធ្វើទៅហើយ មិនយូរប៉ុន្មានស្រាប់តែមានច្បាប់ចេញមកជាក្រោយបង្គាប់ឲ្យធ្វើអំពើនោះចាប់តាំងពីមួយឆ្នាំឬ ២ ឆ្នាំមុនមក ជនដែលយើងពោលមកខាងលើនេះ ក៏ត្រឡប់ជាមានទោសខុសទៅវិញ បើដូច្នេះនាំឲ្យមានសេចក្តីអយុត្តិធម៌ខ្លាំងណាស់ ។ ហេតុនេះ បានជារដ្ឋធម្មនុញ្ញហាមមិនឲ្យយកច្បាប់ទៅប្រើលើអំពើដែល



កន្លងទៅហើយមុនពេលឲ្យប្រតិបត្តិតាម ។ តាមន័យមួយវិញទៀត ច្បាប់ត្រូវមានអំណាចតែក្នុងបច្ចុប្បន្ននិងអនាគត មិនត្រូវមានអំណាចក្នុងអតីតទេ ។

ប៉ុន្តែក្នុងករណីខ្លះ នឹងយកគោលការណ៍នេះមកប្រើតាំងស្រុងពុំបាន ។ ដូចជានាម៉ឺនម្នាក់ត្រូវឡើងសក្តិ ព្រមទាំងឡើងបៀវត្សរ៍ តែពុជការមិនបានដំឡើងឲ្យ ដោយមិនបានគិតដល់ ឬដោយហេតុអ្វីផ្សេងទៀត ដែលជាកំហុសលើពុជការ ។ ទំរាំតែពុជការចេញអត្ថបទ (texte) ដំឡើងឲ្យ អស់វេលា១បមាថា ៦ខែឬមួយឆ្នាំ ។ ប្រសិនជាត្រូវប្រើគោលការណ៍ខាងលើនេះតាំងស្រុង នោះនាម៉ឺនក្នុងឧទាហរណ៍នេះនឹងទទួលប្រាក់បៀវត្សរ៍ថ្មីបាន តែត្រឹមថ្ងៃចេញអត្ថបទនោះតទៅមុខ ។ ម្ល៉ោះហើយក៏នឹងខាតប្រាក់បន្ថែមដែលគួរបានតាំងពី ៦ខែ ឬ១ឆ្នាំមកហើយនោះ ។ ដើម្បីវៀរមិនឲ្យសេចក្តីអយុត្តិធម៌បែបនេះកើតមានឡើងបាន ទើបរដ្ឋធម្មនុញ្ញបើកឲ្យប្រើច្បាប់ទៅលើអតីតបានផងដែរ តែត្រូវដាក់ជាបញ្ញត្តិពិសេសក្នុងច្បាប់នោះឲ្យជាក់ច្បាស់ ។ គឺសេចក្តីនេះហើយដែលមានក្នុងពាក្យថា "វៀរលែងតែមានបញ្ញត្តិពិសេសក្នុងច្បាប់..." ។

ប៉ុន្តែកាលរដ្ឋធម្មនុញ្ញបើកឲ្យការវៀរលែងដូច្នេះអាចកើតមាន

ហើយ ក៏ដូចជាចំហឱកាសឲ្យរដ្ឋសភាដែលជាអ្នកតាំងច្បាប់ប្រព្រឹត្តរំលោភបាន ។ ឧបមាថារដ្ឋសភាកាន់អំណាចនីតិបញ្ញត្តិហើយ រដ្ឋសភាអាចតាំងច្បាប់មួយនៅថ្ងៃនេះ(១) មានសេចក្តីថា៖ « ខេមរជនណាមានភរិយាលើសពីពីរនាក់ ត្រូវទទួលទោសជាប់គុកមួយឆ្នាំ » ។ រួចដាក់បញ្ញត្តិពិសេសក្នុងច្បាប់នោះថា៖ «ច្បាប់នេះឲ្យប្រើតាំងពីថ្ងៃទី១មករា (យ៉ាំងវីយេរ) គ.ស. ១៩៤៧» មក ។ ម៉្លោះហើយ ខេមរជនដែលមានប្រពន្ធ៣នាក់ក៏គង់ត្រូវគុកទាំងអស់គ្នា ទោះបីជាពលរដ្ឋល្អចង់ប្រតិបត្តិតាមច្បាប់ដូចម្តេចក៏ដោយ ព្រោះថាកាលបើដឹងថាមានច្បាប់ចេញដូច្នេះហើយនឹងលែងប្រពន្ធទី៣ភ្លាមហោលទៅ ក៏នៅតែមិនរួចទោសដែរ ។ ឯត្រង់ថា ឲ្យគ្នាលែងប្រពន្ធទី ៣ ឲ្យរួចមុន ថ្ងៃទី១មករា គ.ស.១៩៤៧ ដែលជាវេលាកន្លងទៅហើយជាង ៧ ខែនោះ ជាការហួសវិស័យ ។

ដូច្នេះទើបរដ្ឋធម្មនុញ្ញហាម ក្នុងវគ្គទី២នៃមាត្រានេះ មិនឲ្យតុលាការប្រើច្បាប់ដូចក្នុងឧទាហរណ៍ខាងលើនេះ ជំនុំជំរះនឹងដាក់ទោសជនណាបានឡើយ ។

(១)ថ្ងៃនេះគឺកាលបរិច្ឆេទដែលលោក អៀវកើសកំពុងសរសេរវាំងក្នុងខែសីហា ១៩៤៧ ពេលនោះរដ្ឋសភានៅជាបណ្តោះអាសន្ន មិនទាន់កាន់អំណាចនីតិបញ្ញត្តិទេ ។



មាត្រា ២០.— ច្បាប់ត្រូវប្រតិបត្តិតាម ៖

–នៅភ្នំពេញ កំណត់មួយថ្ងៃគត់ក្រោយដែលបានចុះច្បាប់នោះក្នុងរាជកិច្ច ។

–នៅទីឯទៀត គឺក្នុងដែនស្រុកនីមួយៗកំណត់ប្រាំថ្ងៃគត់ ក្រោយរាជកិច្ចដែលមានចុះច្បាប់នោះ ទៅដល់សាលាស្រុក ។

ប៉ុន្តែបើច្បាប់បានសំដែងថាជាការប្រញាប់ ច្បាប់នោះត្រូវប្រើភ្លាមៗនៅក្រុងភ្នំពេញ ក្រោយដែលបានយកទៅបិទនៅសាលាក្រុង ហើយនៅក្នុងស្រុកនីមួយៗ ក្រោយដែលបានយកទៅបិទនៅសាលាស្រុក ។

សេចក្តីអធិប្បាយ.— កាលរដ្ឋបានធ្វើច្បាប់ត្រឹមត្រូវតាមលក្ខខណ្ឌក្នុងរដ្ឋធម្មនុញ្ញនេះគ្រប់សព្វហើយ រដ្ឋអាចយកច្បាប់នោះទៅប្រើលើបុគ្គលនីមួយៗភ្លាម ដោយមិនបានឲ្យបុគ្គលនោះបានដឹងឮជាមុន ។ ដើម្បីការពារបុគ្គលកុំឲ្យរដ្ឋធ្វើរំលោភដូច្នេះបាន ទើបរដ្ឋធម្មនុញ្ញដាក់បញ្ញត្តិទុកបង្ការជាស្រេចក្នុងមាត្រានេះ ។ ប៉ុន្តែនឹងតម្រូវឲ្យរដ្ឋតាក់ភ្នាក់ងារដើរប្រាប់បុគ្គលគ្រប់រូបឲ្យដឹងថា ថ្ងៃនេះមានច្បាប់ចេញថ្មីមកថាដូច្នេះដូច្នោះ ឃើញថាជាការហួសវិស័យ ។ ហេតុនេះ ទើបរដ្ឋធម្មនុញ្ញបញ្ញត្តថាឲ្យយកច្បាប់ទៅចុះក្នុងរាជកិច្ច(១) ។

(១) រាជកិច្ចគឺជាកាសែតមួយដែលរាជការបោះពុម្ព លក់ផ្សាយអំពីកិច្ចដែលរាជការ (ឬរដ្ឋ) បានប្រព្រឹត្តហើយនិងជាច្បាប់ព្រះរាជក្រិត្យ អនុក្រិត្យ ដីកា សារាចរ បទបញ្ជាជាដើម ។ រាជកិច្ចមានរូបជាសៀវភៅចេញទៀងកំណត់ថ្ងៃរៀងរាបទៅ ។

ច្បាប់ណាដែលបានចុះក្នុងរាជកិច្ចហើយ ដល់គន្លងមួយថ្ងៃគត់តទៅ លោកទុកជាប្រជាជនបានដឹងឮហើយក្នុងទីក្រុងភ្នំពេញ ទើបកំណត់ឲ្យប្រើច្បាប់នោះ គិតតាំងពីពេលនោះរៀងទៅ ។ សម្រាប់ទីតំបន់ឯទៀតក្នុងស្រុកនីមួយៗ លោកឲ្យប្រើច្បាប់នោះរាប់តាំងពីប្រាំថ្ងៃគត់ក្រោយពេលដែលរាជកិច្ចបានទៅដល់សាលាស្រុក ។

ប៉ុន្តែមានច្បាប់ខ្លះ រដ្ឋអាចត្រូវការប្រើភ្លាមៗ ដូចជាច្បាប់ដែលហាមមិនឲ្យនាំមាសចេញទៅលក់ក្រៅព្រះរាជអាណាចក្រជាដើម ។ ប្រសិនបើឲ្យដឹងមួយថ្ងៃឬប្រាំថ្ងៃមុន ដូចជាបញ្ញត្តិខាងលើនេះ អ្នកជំនួញនឹងអាចនាំមាសចេញទៅប្រទេសក្រៅ ក្នុងរយៈវេលានោះបាន ។ ទើបក្នុងការប្រញាប់យ៉ាងនេះរដ្ឋធម្មនុញ្ញបើកឲ្យរាជការយកច្បាប់ថ្មីទៅបិទនៅសាលាក្រុង នឹងសាលាស្រុក រួចហើយក៏ចាប់ប្រើច្បាប់នោះបានភ្លាម ។

ពាក្យថា "...បើច្បាប់បានសំដែងថាជាការប្រញាប់." ប្រែសេចក្តីថារដ្ឋធម្មនុញ្ញមិនប្រគល់អំណាចវិនិច្ឆ័យថាជាការប្រញាប់ទៅឲ្យរដ្ឋាភិបាលទេ ព្រោះតែក្រែងរដ្ឋាភិបាលប្រើអំណាចរំលោភ



ទៅលើបុគ្គល ( ឬរាស្ត្រ ) ។ អំណាចនេះរដ្ឋធម្មនុញ្ញ ប្រគល់ទៅឲ្យអ្នកតំណាងទាំងឡាយ ដែលប្រជុំគ្នាជារដ្ឋសភា ។

**មាត្រា ២១** — អំណាចគ្រប់យ៉ាងមកអំពីព្រះមហាក្សត្រិយ៍ ។ អំណាចទាំងនោះត្រូវប្រើទៅតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ ។

សេចក្តីអធិប្បាយ .— ក្នុងរបៀបសម្បូណ៌ាញាសិទ្ធិរាជ្យ អំណាចគ្រប់យ៉ាង ជារបស់ព្រះមហាក្សត្រិយ៍ ហើយបុគ្គលដទៃដែលកាន់អំណាច គឺបានទទួលអំណាចនោះមកពីព្រះមហាក្សត្រិយ៍ទាំងអស់គ្នា ។ គោលការណ៍នេះ រដ្ឋធម្មនុញ្ញទទួលទុកនៅដដែល ប៉ុន្តែការប្រើអំណាចនៃព្រះមហាក្សត្រិយ៍ ត្រូវធ្វើទៅតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ។ នេះជាការកំណត់តាំងខណ្ឌសីមានៃវិធីប្រើអំណាចព្រះមហាក្សត្រិយ៍ ដែលនាំឲ្យរបៀបសម្បូណ៌ាញាសិទ្ធិរាជ្យ ប្រែទៅជារបៀបបរិមិតាញាសិទ្ធិរាជ្យ ដោយអនុលោមទៅតាមលទ្ធិប្រជាធិបតេយ្យ ។ អំណាចនៃព្រះមហាក្សត្រិយ៍មានបីយ៉ាង គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ព្រះមហាក្សត្រិយ៍នឹងទ្រង់ប្រើព្រះរាជអំណាច

ទាំងបីយ៉ាងដោយវិធីណា នោះមានកំណត់ទុកក្នុងមាត្រា ២២-២៣ និង២៤តទៅនេះ ។

មាត្រា ២២ — **រដ្ឋសភាជាអ្នកប្រើអំណាចនីតិបញ្ញត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។**

**អ្នកមានសិទ្ធិផ្ដើមគំនិតតែងច្បាប់នោះ គឺព្រះមហាក្សត្រិយ៍ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា និងសមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។**

សេចក្ដីអធិប្បាយ.— ព្រះមហាក្សត្រិយ៍ទ្រង់ប្រើអំណាចនីតិបញ្ញត្តិ ដោយអាស្រ័យរដ្ឋសភា ។ តាមន័យមួយទៀត គឺថា ព្រះមហាក្សត្រិយ៍មិនទ្រង់ប្រើអំណាចនេះ ដោយព្រះអង្គឯងទេ ទ្រង់ប្រគល់ព្រះរាជអំណាចនេះទៅរដ្ឋសភា ឲ្យរដ្ឋសភាប្រើក្នុងព្រះបរមនាមនៃព្រះអង្គ ។ "ក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍" ប្រែថាតាងព្រះមហាក្សត្រិយ៍ ។

អំណាចនីតិបញ្ញត្តិ គឺអំណាចតាំងច្បាប់ អំណាចធ្វើច្បាប់ ។ ដើម្បីធ្វើច្បាប់នីមួយៗ ត្រូវឲ្យមានអ្នកព្រាងច្បាប់នោះ ហើយនាំយកទៅជូនក្រុមអភិបាលរដ្ឋសភា ។ ក្រុមអភិបាលរដ្ឋសភា មានសមាជិកយ៉ាងតិច ៩នាក់ គឺប្រធាន១នាក់ អនុប្រធាន២នាក់ និងលេខាធិការយ៉ាងតិច២នាក់ ។ ក្រុមអភិបាលដាក់សេចក្ដីព្រាងច្បាប់



នោះឲ្យរដ្ឋសភាពិភាក្សា ហើយបញ្ចេញមតិព្រមតាំងឡើងជាច្បាប់ ឬបដិសេធចោល ស្របតែសេចក្ដីយល់របស់អ្នកតំណាងរាស្ត្រទាំងឡាយ ។

ការនាំសេចក្ដីព្រាងច្បាប់ទៅជូនក្រុមអភិបាលដូចពោលមកនេះ ហៅថាការផ្ដើមគំនិតតែងច្បាប់ ។ វគ្គទី ២ នៃមាត្រានេះ រាយរាប់អំពីអ្នកដែលមានសិទ្ធិផ្ដើមគំនិតតែងច្បាប់ដូចតទៅនេះ ៖

១— ព្រះមហាក្សត្រិយ៍,

២— គណៈរដ្ឋមន្ត្រី គឺរដ្ឋមន្ត្រីទាំងគណៈ ដែលបានប្រជុំព្រមព្រៀងហើយ មិនមែនជារដ្ឋមន្ត្រីរូបណាមួយទេ,

៣— សមាជិកនៃរដ្ឋសភា គឺអ្នកតំណាងរាស្ត្រ,

៤— សមាជិកនៃក្រុមប្រឹក្សាព្រះរាជអាណាចក្រ គឺទីប្រឹក្សាព្រះរាជអាណាចក្រ ។

មាត្រា ២៣.— **គណៈរដ្ឋមន្ត្រីជាអ្នកប្រើអំណាចនីតិប្រតិបត្តិក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។**

សេចក្ដីអធិប្បាយ.— ព្រះមហាក្សត្រិយ៍ទ្រង់ប្រើអំណាចនីតិប្រតិបត្តិ ដោយអាស្រ័យគណៈរដ្ឋមន្ត្រី គឺព្រះអង្គទ្រង់

ប្រគល់ព្រះរាជអំណាចនេះទៅគណៈរដ្ឋមន្ត្រី ឲ្យប្រើក្នុងព្រះបរមនាមនៃព្រះអង្គ ។

អំណាចនីតិប្រតិបត្តិ គឺអំណាចធ្វើសំរេចតាមច្បាប់ដែលរដ្ឋសភាបានតាំងរួចហើយ ។

មាត្រា ២៤.- សាលាជំរះក្តី គ្រប់ជាន់គ្រប់ប៉ែកជាអ្នកប្រើអំណាចតុលាការក្នុងព្រះបរមនាមនៃព្រះមហាក្សត្រិយ៍ ។

សេចក្តីអធិប្បាយ.- ព្រះមហាក្សត្រិយ៍ទ្រង់ប្រើអំណាចតុលាការ ដោយអាស្រ័យសាលាជំរះក្តីគ្រប់ជាន់-គ្រប់ប៉ែក គឺព្រះអង្គទ្រង់ប្រគល់ព្រះរាជអំណាចនេះ ឲ្យសាលាជំរះក្តីប្រើក្នុងព្រះបរមនាមនៃព្រះអង្គ ។

អំណាចតុលាការគឺអំណាចធ្វើសំរេចតាមច្បាប់ ដូចអំណាចនីតិប្រតិបត្តិដែរ, តែអំណាចនីតិប្រតិបត្តិ ប្រើច្បាប់ដើម្បីគ្រប់គ្រងប្រទេស ឯខាងអំណាចតុលាការ យកច្បាប់ទៅប្រើដើម្បីអារកាត់ករណីវិវាទរវាងបុគ្គលនឹងបុគ្គល ហើយនឹងដើម្បីផ្តន្ទាទោសអ្នកប្រព្រឹត្តល្មើសច្បាប់ ។



## ជំពូក ៤

## អំពីព្រះមហាក្សត្រិយ៍

មាត្រា ២៥.- រាជសម្បត្តិរបស់ប្រទេសកម្ពុជា ជាមត៌ករបស់ក្សត្រាទាំងឡាយ ដែលជាតំណពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង ។

សេចក្តីអធិប្បាយ.- មាត្រានេះកំណត់អំពីឥស្សរៈជនដែលមានសិទ្ធិគ្រងរាជ្យជាព្រះមហាក្សត្រិយ៍នៃប្រទេសខ្មែរ ។ ឥស្សរៈជននោះគឺជាក្សត្រិយ៍ ហើយក្សត្រិយ៍នោះគឺជាប់ព្រះខ្សែព្រះវង្សពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គឌួងមក ។

ពាក្យថា "ក្សត្រា" បញ្ជាក់សេចក្តីថា ក្សត្រិយ៍នោះត្រូវមានភេទជាបុរស ។

មាត្រា ២៦.- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទ នឹងព្រះរាជអំណាចដកព្រះរជ្ជទាយាទពីតំណែងបាន ដោយទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ពិគ្រោះជាមុនហើយ ។

សេចក្តីអធិប្បាយ ។— ក្នុងក្របខណ្ឌនៃមាត្រា២៥មុននេះ ព្រះមហាក្សត្រិយ៍ទ្រង់តែងតាំងក្សត្រិយ៍អង្គណា ជាព្រះរជ្ជទាយាទ(១) តាមសព្វព្រះរាជហឫទ័យ កាលបើទ្រង់តែងតាំងក្សត្រិយ៍អង្គណាមួយរួចទៅហើយ ហើយទ្រង់យល់ក្រោយថាមិនគួរទុកឲ្យជាព្រះរជ្ជទាយាទតទៅទៀតទេ ដោយមានហេតុអ្វីមួយបណ្តាលឡើង នោះទ្រង់អាចដកក្សត្រិយ៍អង្គនោះចេញពីតំណែងព្រះរជ្ជទាយាទបាន ។

តាមបទបញ្ញត្តិនៃមាត្រានេះ មុននឹងតែងតាំងក្តី មុននឹងដកហូតក្តី ព្រះមហាក្សត្រិយ៍ត្រូវទ្រង់ប្រជុំក្រុមប្រឹក្សារាជសម្បត្តិសិន ។ ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកដូចពណ៌នាក្នុងមាត្រា ២៨ តទៅនេះស្រាប់ ។ ការណ៍ដែលទ្រង់ប្រជុំក្រុមប្រឹក្សានេះ គ្រាន់តែដើម្បីពិគ្រោះប៉ុណ្ណោះ មិនមែនត្រូវទ្រង់ប្រតិបត្តិតាមមតិនៃក្រុមប្រឹក្សាដោយខានពុំបានទេ ។ កាលទ្រង់ពិគ្រោះហើយ ព្រះមហាក្សត្រិយ៍អាចទ្រង់សំរេចយកតាមសព្វព្រះរាជហឫទ័យ ។

(១) រជ្ជទាយាទ មកពី រជ្ជៈពាក្យបាលីត្រង់នឹងពាក្យសំស្ក្រឹតថា រាជ្យនឹងទាយាទ គឺអ្នកទទួលអំណោយ អ្នកទទួលមត៌ក ។ រជ្ជទាយាទប្រែថាអ្នកទទួលរាជ្យជាមរតក ។



មាត្រា២៧.- កាលបើរាជសម្បត្តិទំនេរ ប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានតែងតាំងព្រះរជ្ជទាយាទដូចខាងលើនេះទេ នោះក្រុមប្រឹក្សារាជសម្បត្តិតែងតាំងព្រះមហាក្សត្រិយ៍អង្គថ្មី ដោយតាមមតិនៃភាគច្រើនក្នុងទីប្រជុំ បើមតិនៃទីប្រជុំបែកជាពីរភាគស្មើគ្នា នោះត្រូវយកតាមមតិនៃប្រធាន ។

សេចក្តីអធិប្បាយ.— "រាជសម្បត្តិទំនេរ" ប្រែថាគ្មានព្រះមហាក្សត្រិយ៍ ដោយទ្រង់សោយព្រះទិវង្គត ឬដោយទ្រង់លាចាករាជសម្បត្តិ ។

ក្នុងករណីដូច្នេះ ប្រសិនបើព្រះមហាក្សត្រិយ៍បានទ្រង់តែងតាំងព្រះរជ្ជទាយាទរួចស្រេចមកហើយ ព្រះរជ្ជទាយាទក៏ទ្រង់ឡើងគ្រងរាជសម្បត្តិតព្រះសន្តតិវង្សទៅ ។ តែបើព្រះមហាក្សត្រិយ៍ ពុំបានទ្រង់តែងតាំងព្រះរជ្ជទាយាទទេ នោះត្រូវមានការតែងតាំងព្រះមហាក្សត្រិយ៍អង្គថ្មីឡើង ។

នរណាជាអ្នកធ្វើការតែងតាំងនេះ ? ឆ្លើយថា គឺក្រុមប្រឹក្សារាជសម្បត្តិ ។ ក្រុមប្រឹក្សានេះត្រូវតែងតាំងព្រះមហាក្សត្រិយ៍អង្គថ្មី ដោយអាស្រ័យគោលការណ៍អ្វីខ្លះជាមូលដ្ឋាន ? ត្រង់នេះរដ្ឋធម្មនុញ្ញគ្មានបញ្ញត្តទេ ។ ហេតុនេះ ក្រុមប្រឹក្សារាជសម្បត្តិអាចតែងតាំងក្សត្រិយ៍អង្គណាក៏បាន តែត្រូវទៅតាមសេចក្តីក្នុងមាត្រា ២៥ ។ ក្នុងការពិចារណាពិភាក្សានៃក្រុមប្រឹក្សារាជសម្បត្តិ ករណី

មួយក្នុងចំណោមករណី ៣ ដូចតទៅនេះ អាចកើតមានឡើង ៖

១) សមាជិកនៃក្រុមប្រឹក្សាអាចមូលមតិគ្នាជាឯកច្ឆន្ទថាគួរតាំងក្សត្រិយ៍អង្គណាមួយជាព្រះមហាក្សត្រិយ៍អង្គថ្មី ។ ក្នុងករណីដូច្នេះ ក្សត្រិយ៍អង្គនោះត្រូវបានទទួលតែងតាំងជាព្រះមហាក្សត្រិយ៍ ។

២) សមាជិកទាំងឡាយអាចមានសេចក្ដីយល់ផ្សេងពីគ្នា ។ ក្រុមប្រឹក្សារាជសម្បត្តិអាចចែកជា ២-៣-៤ ភាគ ។ មួយភាគយល់ថា គួរតាំងតាំងក្សត្រិយ៍អង្គនេះ, មួយភាគទៀតយល់ថាគួរតាំងតាំងក្សត្រិយ៍អង្គនោះ, មួយភាគទៀតអាចមិនយល់ព្រម ចង់ឲ្យតាំងតាំងក្សត្រិយ៍អង្គណាមួយផ្សេងទៅទៀត ។ល។ បើមានករណីដូច្នេះកើតឡើង លោកឲ្យយកតាមមតិនៃភាគច្រើនៗ ពាក្យថា"ភាគច្រើន" គឺភាគណាដែលមានសមាជិកច្រើនលើសគេយ៉ាងតិចមួយរូប ។

៣) ក្នុងការពិចារណាពិភាក្សានៃក្រុមប្រឹក្សារាជសម្បត្តិ សមាជិកទាំងឡាយអាចចែកជា ២-៣-៤ ភាគប៉ុនគ្នា មានសេចក្ដីយល់ផ្សេងគ្នា ។ ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកចំនួន ៧ រូបរួមបញ្ចូលទាំងប្រធានផង ( មាត្រា២៨ ) ។ បើសមាជិកបានមកប្រជុំគ្រប់រូប ករណីដូច្នេះមិនអាចកើតមានឡើយ ព្រោះចំនួន ៧ នឹងចែកជាភាគ



ស្មើគ្នាពុំបាន វៀរលែងតែចែកជា ៧ ភាគ ។ តែបើដោយហេតុអ្វីមួយ សមាជិក ១ រូប ៣ រូបឬ ៥រូបពុំបានមកប្រជុំ នោះក្រុមប្រឹក្សា អាចចែកជា ២-៣-៤-៥ ឬ ៦ភាគស្មើគ្នា ។ ក្នុងករណីដូច្នេះ បើប្រធាននៅក្នុងភាគណា លោកឲ្យយកតាមមតិនៃភាគនោះ ។

សេចក្ដីសង្កេត.– នៅមានករណីមួយទៀត ជាករណីទី៤ រដ្ឋធម្មនុញ្ញពុំបានបញ្ញត្តទុក គឺករណីដែលប្រធានក្រុមប្រឹក្សារាជសម្បត្តិពុំបានមកប្រជុំ ។ បើករណីទី៣ នឹងទី៤កើតឡើងព្រមគ្នា តាមន័យមួយទៀត គឺថាបើក្នុងការពិចារណាពិភាក្សា ក្រុមប្រឹក្សារាជសម្បត្តិ ចែកជា២ឬ៣ភាគស្មើគ្នា ហើយគ្មានប្រធាននៃក្រុមនេះមកប្រជុំផង តើនឹងវិនិច្ឆ័យទៅយ៉ាងណា ? ការពិបាកក៏នឹងកើតឡើង ។ តាមប្រក្រតី ក្នុងទីប្រជុំត្រូវតែមានបុគ្គលមួយរូបជាប្រធាន កាលបើអ្នកកាន់ដំណែងប្រធានពុំបានមកប្រជុំក្នុងពេលប្រជុំណាមួយ ទីប្រជុំត្រូវតាំងតាំងសមាជិកមួយរូបជាប្រធានសម្រាប់ពេលប្រជុំនោះឡើង ។ ការតាំងតាំងប្រធានសម្រាប់ពេលប្រជុំណាដែលប្រធានក្រុមប្រឹក្សារាជសម្បត្តិមិនបានមកប្រជុំ នឹងធ្វើទៅដោយវិធីណា នេះក៏គ្មានបញ្ញត្តទុកក្នុងអត្ថបទណាមួយឡើយ ។ វិធីតាំងតាំងអាចធ្វើទៅដោយសន្មត់យកបុគ្គលណា មានអាយុច្រើនជាងគេ ឬ

ដោយវិធីបោះឆ្នោតសម្ងាត់ ឬដោយសន្មតយកតាមលំដាប់ឈ្មោះសមាជិក ដែលមានរាយរាប់ក្នុងមាត្រា២៨ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ២៨.– ក្រុមប្រឹក្សារាជសម្បត្តិមានសមាជិកដូចតទៅនេះ:

- អធិបតីនៃក្រុមសង្គហៈព្រះរាជវង្សានុវង្ស
- នាយករដ្ឋមន្ត្រី
- ប្រធានរដ្ឋសភា
- ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ
- ព្រះសង្ឃនាយកទាំងពីរគណៈ
- ចាងហ្វាងសាលាតុលាការជាន់ខ្ពស់

អធិបតីក្រុមសង្គហៈព្រះរាជវង្សានុវង្ស ជាប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ ។

សេចក្ដីអធិប្បាយ.– សេចក្ដីក្នុងមាត្រានេះ ច្បាស់លាស់ល្មមស្ដាប់បានដោយងាយ មិនចាំបាច់អធិប្បាយ ។ មានតែពាក្យ "ក្រុមសង្គហៈ[១]ព្រះរាជវង្សានុវង្ស" នឹងពាក្យ "សាលាតុលាការជាន់ខ្ពស់" ប៉ុណ្ណោះ ដែលអ្នកអានខ្លះមិនទាន់ស្គាល់ ។

ក្រុមសង្គហៈព្រះរាជវង្សានុវង្ស ជាគណៈមួយតាំងឡើងដោយក្សត្រិយ៍ នឹងឥស្សរជនដែលមានឋានៈដ៏ខ្ពង់ខ្ពស់ ដើម្បីសង្គ្រោះដល់ក្សត្រិយ៍ដទៃ ៗ ដែលជាព្រះរាជវង្សានុវង្ស ឲ្យបានថ្លៃថ្នូរទាំងផ្លូវកាយទាំងផ្លូវចិត្ត សមល្មមជាក្សត្រិយ៍ ។

(១)បាលីថា សង្គហៈ, សំស្ក្រឹតថា សំគ្រហៈ = ខ្មែរ សង្គ្រោះ ។



សាលាតុលាការជាន់ខ្ពស់ ជាសាលាជំរះក្ដីមួយ ដែលតាំងឡើងដើម្បីជំនុំជំរះរដ្ឋមន្ត្រីដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបានធ្វើខុសជាទម្ងន់ក្នុងវេលាធ្វើការមុខក្រសួងរបស់ខ្លួន ។

( មាត្រា ៩២ – ៩៣ នឹង៩៤ មានស្រដីអំពីសាលាតុលាការជាន់ខ្ពស់នេះស្រាប់) ។

មាត្រា ២៩.– និតិភាពនៃព្រះមហាក្សត្រិយ៍ កំណត់តាំងពីព្រះជន្មាយុដប់ប្រាំបីវស្សា ។ បើប្រសិនជាព្រះមហាក្សត្រិយ៍ឋិតនៅក្នុងអនីតិភាពឬគ្មានសមត្ថភាពនឹងទ្រង់ប្រើព្រះរាជសិទ្ធិទេ នោះព្រះរាជសិទ្ធិនោះត្រូវជាភារៈរបស់ព្រះរាជានុសិទ្ធមួយព្រះអង្គ ។

ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ហើយបើមានករណីដូច្នោះ ក្រុមប្រឹក្សារាជសម្បត្តិ ត្រូវចាត់តាំងក្សត្រិយ៍មួយព្រះអង្គ ក្នុងព្រះរាជវង្សានុវង្ស ជាព្រះរាជានុសិទ្ធ ។

សេចក្ដីអធិប្បាយ.– មនុស្សយើងកាលនៅក្នុងវ័យក្មេងនៅឡើយ មិនទាន់ដឹងខុសត្រូវពេញទីទេ, លោកហៅថានៅក្នុង អនីតិភាព ។ កាលធំខ្លួនដឹងខុសត្រូវពេញទីហើយ ឬតាមន័យមួយទៀតថា កាលជាមនុស្សបានការហើយ លោកថាដល់ និតិភាព[១] ហើយ ។

(១) នីតិ ប្រែថាច្បាប់, "និតិភាព" គឺភាវៈដែលច្បាប់កំណត់ថាជាមនុស្សបានការ ។

នៅប្រទេសខ្មែរយើង មាននីតិភាពច្រើនយ៉ាង ។ នីតិភាពក្នុងផ្លូវអាជ្ញាកំណត់ពីអាយុ ១៨ ឆ្នាំបរិបូណ៌ឡើងទៅ ប្រែសេចក្ដីថា បើបុគ្គលដែលប្រព្រឹត្តបទល្មើសមានអាយុ ១៨ ឆ្នាំបរិបូណ៌ឡើងទៅទើបសាលាកាត់សេចក្ដីដាក់ទោសពេញកំណត់បាន ។ នីតិភាពខាងផ្លូវពន្ធដារក៏កំណត់ពីអាយុ១៨ឆ្នាំទៅដែរ ប្រែសេចក្ដីថា ចាប់តាំងពីអាយុ១៨ឆ្នាំបរិបូណ៌ឡើងទៅ ទើបពលរដ្ឋខ្មែរត្រូវជាប់ពន្ធផ្ទាល់ខ្លួន(១) ។ នីតិភាពខាងផ្លូវរដ្ឋប្បវេណី កំណត់ពីអាយុ ២១ ឆ្នាំបរិបូណ៌ឡើងទៅ ទើបពលរដ្ឋខ្មែរអាចធ្វើកិច្ចសន្យាផ្សេង ៗ អាចលក់ផ្ទេរអសង្ហារិមវត្ថុ ។ល។ នីតិភាពខាងផ្លូវនយោបាយ កំណត់ពីអាយុ២០ ឆ្នាំ ប្រែសេចក្ដីថា ចាប់តាំងពីអាយុ ២០ ឆ្នាំបរិបូណ៌ឡើងទៅ ទើបពលរដ្ឋខ្មែរមានសិទ្ធិជ្រើសតាំងអ្នកតំណាងរាស្ត្រ និងអ្នកតំណាងឯទៀតបាន ។

សម្រាប់ព្រះមហាក្សត្រិយ៍ រដ្ឋធម្មនុញ្ញកំណត់នីតិភាពចាប់តាំងពីព្រះជន្មាយុ ១៨ ព្រះវស្សាឡើងទៅ ប្រែសេចក្ដីថា បើព្រះជន្មាយុមិនទាន់បានគ្រប់ ១៨ ព្រះវស្សាទេ លោកថាព្រះមហាក្សត្រិយ៍ឋិតនៅក្នុងអនីតិភាព នោះព្រះមហាក្សត្រិយ៍មិនអាចទ្រង់គ្រងរាជសម្បត្តិ

(១)ពាក្យថាពន្ធផ្ទាល់ខ្លួន= impôt personnel ។ក្នុងពេលដែលលោកអ:-ក សរសេរ រដ្ឋសភាមិនទាន់បានលុបពន្ធនេះនៅឡើយ ។



បានឡើយ ។ ព្រះមហាក្សត្រិយ៍ដែលគ្មានសមត្ថភាព ដូចជាទ្រង់វិកលចរិត ( ឆ្កួត ) ជាដើម ក៏មិនអាចគ្រងរាជ្យបានដែរ ។

បើព្រះមហាក្សត្រិយ៍ឋិតនៅក្នុងអនីតិភាព ឬគ្មានសមត្ថភាពដូច្នេះ នោះក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងក្សត្រិយ៍មួយព្រះអង្គជាព្រះរាជានុសិទ្ធ ដើម្បីគ្រងរាជ្យជួសព្រះមហាក្សត្រិយ៍ ។ ពាក្យថា "ក្សត្រា" ដែលប្រើក្នុងមាត្រានេះធ្វើឲ្យឃើញច្បាស់ថាព្រះរាជានុសិទ្ធត្រូវមានភេទជាបុរស ។

នរណានឹងវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ? មាត្រានេះបញ្ញត្តថា គឺក្រុមប្រឹក្សារាជសម្បត្តិ ។

មាត្រា ៣០.– កាលបើរាជសម្បត្តិទំនេរ ហើយប្រសិនបើព្រះមហាក្សត្រិយ៍ពុំបានចាត់តាំងព្រះរជ្ជទាយាទទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវតែប្រជុំក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ដែលធ្វើឲ្យរាជសម្បត្តិទំនេរ ដើម្បីចាត់តាំងព្រះមហាត្រិយ៍អង្គថ្មី ព្រមទាំងព្រះរាជានុសិទ្ធ បើព្រះមហាក្សត្រិយ៍អង្គថ្មីឋិតនៅក្នុងអនីតិភាព ។

ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិត្រូវធ្វើដោយប្រធានអញ្ជើញ បើប្រធានមិនអញ្ជើញទេ ត្រូវប្រជុំនៅថ្ងៃទីបីនៃរយៈវេលាដែលមានកំណត់ក្នុងវគ្គមុននេះ ។

បើត្រូវវិនិច្ឆ័យថា ព្រះមហាក្សត្រិយ៍ក្នុងរាជសម្បត្តិគ្មានសមត្ថភាព នោះត្រូវប្រធានក្រុមប្រឹក្សារាជសម្បត្តិ អញ្ជើញសមាជិកមកប្រជុំដោយតំរិះព្រះអង្គឯងក៏បាន ដោយសេចក្ដីសុំនៃសមាជិកយ៉ាងតិចត្រឹមពីរនាក់ក៏បាន ដើម្បីនឹងវិនិច្ឆ័យថាព្រះមហាក្សត្រិយ៍មានសមត្ថភាពឬទេ ហើយបើព្រះមហាក្សត្រិយ៍ គ្មានសមត្ថភាពទេ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងព្រះរាជានុសិទ្ធមួយអង្គឡើង ។

សេចក្ដីអធិប្បាយ.— វគ្គទី ១ នឹងទី ២ នៃមាត្រានេះ ស្ដីអំពីករណីដែលរាជសម្បត្តិទំនេរ ហើយព្រះមហាក្សត្រិយ៍ពុំបានទ្រង់ចាត់តាំងព្រះរជ្ជទាយាទពីមុនទុកមក ។ វគ្គទី ៣ ស្ដីអំពីករណីដែលព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព ។ រដ្ឋធម្មនុញ្ញបានតាំងគោលការណ៍សម្រាប់ករណីទាំងពីរនេះរួចមកហើយ ក្នុងមាត្រា២៧នឹង ២៩ ។ ក្នុងមាត្រា៣០នេះ រដ្ឋធម្មនុញ្ញត្រឡប់មកស្ដីអំពីករណីដដែលទៀត ហើយពង្រីកសេចក្ដីឲ្យពិស្ដារឡើង ។ ទាំងនេះក៏ដោយហេតុមានបំណងមួយយ៉ាង គឺថាវៀរមិនឲ្យរាជសម្បត្តិនៅទំនេរយូរ ក្រែងស្ទុះដំណើរនៃកិច្ចការផែនដី ។

ដោយហេតុនេះ ទើបកំណត់ឲ្យក្រុមប្រឹក្សារាជសម្បត្តិប្រជុំក្នុងរវាងបីថ្ងៃក្រោយព្រឹត្តិការណ៍ដែលធ្វើឲ្យរាជសម្បត្តិទំនេរៗ ព្រឹត្តិការណ៍នោះតាមធម្មតាគឺកាលកិរិយាដែលបណ្ដាលមកពីជរាភាពឬព្រះរោគៗ ពាក្យថា "រវាងបីថ្ងៃ" ប្រែថាយ៉ាងយូរបីថ្ងៃ ។ ក្រុមប្រឹក្សារាជ



សម្បត្តិអាចប្រជុំក្នុងថ្ងៃទី ២ ឬថ្ងៃទី ១ ក្រោយពេលដែលរាជសម្បត្តិទំនេរ ។ បើប្រជុំបានក្នុងពេលឆាប់ក៏កាន់តែល្អ ។

ដើម្បីឲ្យក្រុមប្រឹក្សារាជសម្បត្តិប្រជុំក្នុងរវាង ៣ថ្ងៃកុំឲ្យខានបានជារដ្ឋធម្មនុញ្ញថ្វាយភារៈទៅប្រធាននៃក្រុមប្រឹក្សានេះ ឲ្យទ្រង់អញ្ជើញសមាជិកមកប្រជុំក្នុងកំណត់វេលា ។ ប៉ុន្តែបើដោយហេតុអ្វីមួយប្រធានមិនទ្រង់អញ្ជើញប្រជុំ សមាជិកអាចនៅរង់ចាំហួសបីថ្ងៃទៅ ។ ហេតុនេះ រដ្ឋធម្មនុញ្ញ ទើបបញ្ញត្តថា បើប្រធានមិនទ្រង់អញ្ជើញប្រជុំទេ សមាជិកទាំងឡាយត្រូវតែមកប្រជុំក្នុងថ្ងៃទី៣ ។

ក្រុមប្រឹក្សារាជសម្បត្តិដែលប្រជុំនេះ គឺដើម្បីជ្រើសតាំងព្រះមហាក្សត្រិយ៍អង្គថ្មី ។ ប៉ុន្តែបើព្រះមហាក្សត្រិយ៍អង្គថ្មី ឋិតនៅក្នុងអនីតិភាពពោលគឺមិនទាន់មានព្រះជន្មាយុគ្រប់១៨ព្រះវស្សាបរិបូណ៌ទេ នោះក្រុមប្រឹក្សារាជសម្បត្តិត្រូវជ្រើសតាំងក្សត្រាមួយព្រះអង្គទៀត ដែលលុះនីតិភាពហើយជាព្រះរាជានុសិទ្ធ ដើម្បីកាន់ព្រះរាជអំណាចជំនួសព្រះអង្គទំរាំដល់ព្រះជន្មាយុ ១៨ព្រះវស្សា ។

កាលបើព្រះមហាក្សត្រិយ៍គ្មានសមត្ថភាព តាមធម្មតាគឺដោយហេតុព្រះចរិតមិនប្រក្រតី នោះប្រធាននៃក្រុមប្រឹក្សារាជសម្បត្តិ ត្រូវទ្រង់អញ្ជើញសមាជិកមកប្រជុំដើម្បីពិនិត្យមើល ហើយវិនិច្ឆ័យថា

ព្រះមហាក្សត្រិយ៍នឹងអាចទ្រង់បំពេញព្រះរាជភារៈតទៅទៀតឬទេ ។ បើពិនិត្យទៅឃើញថាព្រះមហាក្សត្រិយ៍គ្មានសមត្ថភាពមែន នោះក្រុមប្រឹក្សារាជសម្បត្តិចាត់តាំងព្រះរាជានុសិទ្ធមួយព្រះអង្គឡើងដើម្បីឲ្យទទួលព្រះរាជភារៈជំនួស ។

ប៉ុន្តែបើព្រះមហាក្សត្រិយ៍គ្មានសមត្ថភាពមែន ហើយបើដោយហេតុអ្វីមួយ ប្រធានក្រុមប្រឹក្សារាជសម្បត្តិមិនអញ្ជើញសមាជិកមកប្រជុំ នោះនឹងតាំងព្រះរាជានុសិទ្ធក៏ពុំបាន ។ កិច្ចការផែនដីក៏នឹងមិនមានដំណើរទៅដោយស្រួល ។ ហេតុនេះ ទើបរដ្ឋធម្មនុញ្ញបញ្ញត្តទុកក្នុងវគ្គទី ៣ នៃមាត្រានេះថា បើប្រធានមិនទ្រង់អញ្ជើញសមាជិកមកប្រជុំដោយតំរិះព្រះអង្គឯងទេ សមាជិកអាចសុំឲ្យប្រធានអញ្ជើញប្រជុំ ។ បើសមាជិកអ្នកសុំនោះ មានចំនួន ២ រូបឬលើសពី ២ រូប ប្រធានត្រូវតែអញ្ជើញសមាជិកមកប្រជុំនឹងខានពុំបាន ។

មាត្រា ៣១.– ក្នុងរវាង៨ថ្ងៃក្រោយវេលាផ្លាស់ប្តូររជ្ជកាល រដ្ឋសភាត្រូវប្រជុំដោយខានពុំបាន ដើម្បីទទួលសច្ចាប្រណិធានអំពីព្រះមហាក្សត្រិយ៍ ឬអំពីព្រះរាជានុសិទ្ធ ។



សេចក្តីអធិប្បាយ.– កាលរាជសម្បត្តិទំនេរ ហើយបើព្រះមហាក្សត្រិយ៍ បានទ្រង់ចាត់តាំងព្រះរជ្ជទាយាទទុករួចមកហើយ ថ្ងៃដែលរាជសម្បត្តិទំនេរនេះ រាប់ថាជាវេលាផ្លាស់ប្តូររជ្ជកាល ។

ប្រសិនជាព្រះមហាក្សត្រិយ៍ ពុំបានទ្រង់ចាត់តាំង ព្រះរជ្ជ-ទាយាទទុកមកទេ កាលណារាជសម្បត្តិទំនេរ ក្រុមប្រឹក្សារាជសម្បត្តិត្រូវចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មីតាមមាត្រា ២៧ និង ៣០ ។ ថ្ងៃណាដែលក្រុមប្រឹក្សារាជសម្បត្តិ ចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មីជាស្រេច ថ្ងៃនោះរាប់ថាជាវេលាផ្លាស់ប្តូររជ្ជកាល ។

មាត្រានេះបញ្ញត្តឲ្យរដ្ឋសភាក្នុងរវាង៨ថ្ងៃរាប់ពីវេលាផ្លាស់ប្តូររជ្ជកាលនោះទៅ ដើម្បីទទួលសច្ចាប្រណិធាន (សម្បថ) អំពីព្រះមហាក្សត្រិយ៍អង្គថ្មី ។

ប្រសិនបើជាព្រះមហាក្សត្រិយ៍អង្គថ្មីឋិតនៅក្នុងអនីតិភាព នោះព្រះអង្គពុំទ្រង់ប្រើព្រះរាជសិទ្ធិបានភ្លាមទេ , ដូច្នេះក៏ពុំត្រូវទ្រង់តាំងសច្ចាប្រណិធានក្នុងរវាង៨ថ្ងៃនោះដែរ ។ បើមានករណីដូច្នេះ ព្រះរាជានុសិទ្ធដែលទ្រង់ប្រើព្រះរាជសិទ្ធិជួសព្រះមហាក្សត្រិយ៍ ត្រូវតាំងសច្ចាប្រណិធានក្នុងរដ្ឋសភាក្នុងរវាង៨ថ្ងៃ រាប់តាំងពីវេលាផ្លាស់ប្តូររជ្ជកាល ។

មាត្រា ៣២.- មុននឹងទទួលព្រះរាជអំណាច ព្រះមហាក្សត្រិយ៍ទ្រង់ថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភា មានជាសេចក្ដីដូចតទៅនេះ :

"ខ្ញុំតាំងសច្ចាថា នឹងប្រព្រឹត្តតាមរដ្ឋធម្មនុញ្ញ នឹងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រ ហើយនឹងតាំងចិត្តធ្វើផលប្រយោជន៍ដល់រដ្ឋនឹងប្រជារាស្ត្រ" ។

(សេចក្ដីក្នុងមាត្រានេះ ច្បាស់លាស់ល្មមស្ដាប់បានហើយ មិនចាំបាច់អធិប្បាយទេ ) ។

មាត្រា ៣៣.- មុននឹងទទួលតំណែង ព្រះរាជានុសិទ្ធត្រូវថ្លែងសច្ចាប្រណិធានក្នុងទីប្រជុំរដ្ឋសភា មានសេចក្ដីដូចក្នុងមាត្រាខាងលើនេះ ហើយបន្ថែមពាក្យថា " ខ្ញុំតាំងសច្ចាថាខ្ញុំមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រិយ៍" ។

សេចក្ដីអធិប្បាយ.- មាត្រានេះក៏មិនចាំបាច់អធិប្បាយទេ។ ការតាំងសច្ចាប្រណិធានដូចពោលក្នុងមាត្រា ៣២ និង ៣៣ នេះជាប្រពៃណីនៃព្រះមហាក្សត្រិយ៍ទាំងឡាយ ដែលសោយរាជ្យសម្បត្តិក្នុងប្រទេសនានាក្នុងទ្វីបអឺរ៉ុបកាលលើកលែងប្រើរបៀបសម្បូណ៌ាញាសិទ្ធិរាជ្យទៅហើយ ។ ប្រពៃណីនេះជាប្រពៃណីថ្មីសម្រាប់ប្រទេសខ្មែរយើង ។



មាត្រា ៣៤ ចាប់ផ្ដើមតាំងពីវេលាដែលរាជសម្បត្តិទំនេរ រហូតដល់វេលាដែលព្រះមហាក្សត្រិយ៍អង្គថ្មី ឬព្រះរាជានុសិទ្ធថ្លែងសច្ចាប្រណិធាន ក្នុងរវាងវេលានោះ ប្រធានរដ្ឋសភាប្រើអំណាចជាប្រមុខរបស់រដ្ឋស្នងព្រះអង្គដោយទទួលសេចក្ដីខុសត្រូវលើខ្លួន ។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍មិនបានគង់នៅក្នុងប្រទេសកម្ពុជា ឬពុំអាចទ្រង់ទទួលព្រះរាជភារៈបាន ព្រះមហាក្សត្រិយ៍ទ្រង់ប្រគល់ព្រះរាជភារៈនោះទៅក្រុមប្រឹក្សាមួយក្រុមជាបណ្ដោះអាសន្ន ព្រះមហាក្សត្រិយ៍ទ្រង់តាំងអធិបតីនឹងសមាជិកនៃក្រុមប្រឹក្សានោះ ដោយចាត់តាំងយកក្រៅពីសមាជិកនៃរដ្ឋាភិបាល ។

សេចក្ដីអធិប្បាយ:

វគ្គទី១.- រវាងវេលាដែលរាជសម្បត្តិទំនេរ ទៅទល់នឹងវេលាដែលព្រះមហាក្សត្រិយ៍អង្គថ្មី ឬព្រះរាជានុសិទ្ធតាំងសច្ចាប្រណិធានមិនជាយូរថ្ងៃប៉ុន្មានទេ ។ បើព្រះមហាក្សត្រិយ៍អង្គមុនពុំបានទ្រង់ចាត់តាំងព្រះរជ្ជទាយាទទេ ក្រុមប្រឹក្សារាជសម្បត្តិប្រជុំក្នុងរវាង៣ថ្ងៃក្រោយវេលាដែលរាជសម្បត្តិទំនេរ (មាត្រា៣) ។ ការចាត់តាំងព្រះមហាក្សត្រិយ៍អង្គថ្មីតែមួយព្រះអង្គឬព្រមទាំងព្រះរាជានុសិទ្ធផង តាមធម្មតាមែងសំរេចបានក្នុងថ្ងៃទី៣នោះ ដែលរាប់ថាជាថ្ងៃផ្លាស់ប្ដូររជ្ជកាល ។ តពីថ្ងៃនោះយ៉ាងយូរ៨ថ្ងៃ រដ្ឋសភាត្រូវប្រជុំដើម្បីទទួលសច្ចាប្រណិធានៗ គិតទៅមិនលើសពី១១ថ្ងៃ ។

ក្នុងរវាង ១១ ថ្ងៃយ៉ាងយូរនេះ រដ្ឋខ្មែរគ្មានប្រមុខ ៗ ម្យ៉ាងហើយកិច្ចការផែនដីដែលជាការៈនៃប្រមុខរបស់រដ្ឋ ដូចជាការប្រកាសឲ្យប្រើច្បាប់ទាំងឡាយជាដើម (មាត្រា ៣៦) មិនអាចមានដំណើរទៅបាន ៗ តាមន័យមួយទៀតគឺថាក្នុងវេលា ១១ ថ្ងៃយ៉ាងយូរនេះ រដ្ឋខ្មែរមិនអាចតាំងច្បាប់ថ្មី មិនអាចចេញព្រះរាជក្រឹត្យថ្មីបានឡើយ ៗ ទាំងនេះជាការណ៍ដែលអាចនាំឲ្យខូចផលប្រយោជន៍ដល់ប្រទេស ៗ

ដើម្បីវៀរវៀសមិនឲ្យមានការមិនស្រួលដូច្នេះ ត្រូវឲ្យមានអ្នកទទួលសំរេចភារៈនៃប្រមុខរបស់រដ្ឋជាប់ជានិច្ច ៗ កាលបើព្រះមហាក្សត្រិយ៍ ឬព្រះរាជានុសិទ្ធពុំអាចទ្រង់ទទួលសំរេចភារៈនេះបានដូចក្នុងករណីខាងលើនេះ ត្រូវតែតាំងឥស្សរជនណាមួយឲ្យសំរេចជាបណ្ដោះអាសន្នសិន ៗ រដ្ឋធម្មនុញ្ញបញ្ញត្តក្នុងមាត្រានេះថា ឥស្សរជននោះ គឺប្រធានរដ្ឋសភា ៗ អ្នកអានអាចឆ្ងល់ថាហេតុម្ដេចក៏រដ្ឋធម្មនុញ្ញមិនបញ្ញត្តយកនាយករដ្ឋមន្ត្រីវិញ ? គឺមកពីនាយករដ្ឋមន្ត្រី ជាអ្នកកាន់អំណាចនីតិប្រតិបត្តិ ៗ តាមន័យមួយទៀតគឺថាកំឡាំងរបស់ជាតិទាំងប៉ុន្មាន មានកំឡាំងទាហានជាដើម នៅក្នុងកណ្ដាប់



ដៃរបស់នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីឯទៀតដែលនៅក្នុងឱវាទរបស់ខ្លួន ៗ ប្រសិនជានាយករដ្ឋមន្ត្រី កាន់អំណាចជាប្រមុខរបស់រដ្ឋផងទៀត ការប្រើអំណាចដោយរំលោភនឹងអាចកើតមានឡើង នាំឲ្យមានភយន្តរាយដល់ជាតិ ៗ

វគ្គទី ២.—ក្នុងពេលដែលព្រះមហាក្សត្រិយ៍មិនបានគង់នៅក្នុងប្រទេសកម្ពុជា ដូចកាលទ្រង់យាងទៅកាន់ប្រទេសបារាំងពីខែមេសា ( អាព្រិល ) គ.ស. ១៩៤៦ ឬពុំអាចទ្រង់ទទួលព្រះរាជការៈបាន ដូចកាលទ្រង់ព្រះផ្នួសក្នុង គ.ស. ១៩៤៧នេះ ព្រះមហាក្សត្រិយ៍ទ្រង់ប្រគល់ព្រះរាជការៈ ទៅក្រុមប្រឹក្សាមួយទាំទ្រង់ទទួលព្រះរាជការៈវិញបាន ៗ ព្រះមហាក្សត្រិយ៍ទ្រង់ចាត់តាំងអធិបតីនិងសមាជិកនៃក្រុមប្រឹក្សានេះតាមទ្រង់សព្វព្រះរាជហឫទ័យ ៗ រដ្ឋធម្មនុញ្ញគ្រាន់តែបញ្ញត្តមិនឲ្យទ្រង់ចាត់តាំងសមាជិក[១] នៃរដ្ឋាភិបាលឲ្យទទួលតំណែងក្នុងក្រុមប្រឹក្សានេះតែប៉ុណ្ណោះ ៗ ទាំងនេះក៏ដោយប្រាថ្នាមិនឲ្យបុគ្គលដែលកាន់អំណាចនីតិប្រតិបត្តិ ទទួលកាន់ព្រះរាជអំណាចផងថែមទៀត ៗ

---

( ១ ) សមាជិកនៃរដ្ឋាភិបាលបានដល់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

មាត្រា ៣៤ .- ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ អង្គព្រះមហាក្សត្រិយ៍ជាទីគោរពសក្ការៈ នរណាទំងល្មើសពុំបាន ។

សេចក្ដីអធិប្បាយ .- យើងនឹងចែកសេចក្ដីអធិប្បាយជា ៣ វគ្គដូចតទៅនេះ ៖

១-ព្រះមហាក្សត្រិយ៍ទ្រង់ជាអគ្គប្រមុខនៃរដ្ឋ ។ ប្រយោគនេះគេប្រើក្នុងរបៀបប្រជាធិបតេយ្យ មានសេចក្ដីស្របគ្នានឹងប្រយោគមួយទៀត ដែលគេធ្លាប់ប្រើក្នុងរបៀបសម្បូណាញាសិទ្ធិរាជ្យ គឺ "ព្រះមហាក្សត្រិយ៍ទ្រង់ជាម្ចាស់ផែនដី" ។

"អគ្គប្រមុខនៃរដ្ឋ" ប្រែថា មេធំបំផុតនៃរដ្ឋ ។ ក្នុងសាធារណរដ្ឋ ប្រមុខនៃរដ្ឋ គឺប្រធានាធិបតី ។ ប្រមុខនៃរដ្ឋជាអ្នកតំណាងខ្ពស់បំផុតរបស់រដ្ឋ ឬរបស់ប្រទេស ។

២-អង្គព្រះមហាក្សត្រិយ៍ជាទីគោរពសក្ការៈ ។ ខាងរាជការត្រូវដំកើងព្រះកិត្តិយសនៃព្រះមហាក្សត្រិយ៍លើសបុគ្គលដទៃ ។ ក្នុងពេលដែលព្រះអង្គគង់ក្នុងព្រះបរមរាជវាំងក្ដី ក្នុងពេលដែលស្ដេចយាងទៅកាន់ទីណាក្ដី ត្រូវចាត់ឲ្យមានការគោរពសក្ការៈយ៉ាងថ្លៃថ្នូរ ហើយត្រូវថ្វាយរូបិយកណ្ឌច្រើន លើសបៀវត្សអ្នករាជការទូទៅ



ឲ្យទុកសមស័ក្ដិជាអគ្គប្រមុខនៃរដ្ឋ ។ ឯខាងប្រជានុរាស្ត្រក្រោមល្អងធូលីព្រះបាទ ក៏ត្រូវទុកការសំដែងគារវៈចំពោះព្រះមហាក្សត្រិយ៍ជាករណីយកិច្ចមួយសម្រាប់ខ្លួនគ្រប់គ្នា ។

ដើម្បីទ្រង់គង់ជាទីគោរពសក្ការៈបានដោយពេញបរិបូណ៌ ៖

ក) រដ្ឋធម្មនុញ្ញដំកល់អង្គព្រះមហាក្សត្រិយ៍ខ្ពស់ផុតចាកសេចក្ដីទិទៀននិន្ទា ។ តាមន័យមួយទៀត គឺថាព្រះមហាក្សត្រិយ៍មិនទ្រង់ទទួលសេចក្ដីខុសត្រូវក្នុងកិច្ចការណាមួយឡើយ ។ ហេតុនេះទើបក្នុងព្រះរាជកិច្ចដែលទ្រង់សំរេចទាំងអម្បាលម៉ាន រដ្ឋធម្មនុញ្ញបញ្ញត្តឲ្យមានបុគ្គលយ៉ាងតិចមួយរូបចុះហត្ថលេខាជាមួយផង ដើម្បីទទួលព្រះរាជទុក្ខរដំកល់លើត្បូង ។ បុគ្គលនោះត្រូវទទួលសេចក្ដីខុសត្រូវជួសព្រះមហាក្សត្រិយ៍ ព្រោះត្រូវទុកជាអ្នកក្រាបទូលស្នើសុំឲ្យព្រះមហាក្សត្រិយ៍ ទ្រង់សំរេចព្រះរាជកិច្ចនោះ ។ ដោយអាស្រ័យហេតុនេះ នៅប្រទេសអង់គ្លេស គេតាំងជាគោលការណ៍មួយថា "ព្រះមហាក្សត្រិយ៍ មិនអាចទ្រង់ប្រព្រឹត្តខុស" ។

ព្រះមហាក្សត្រិយ៍ទ្រង់គង់ខ្ពស់ផុត អំពីគណបក្សនយោបាយទាំងឡាយ ។ ប្រែសេចក្ដីថា ព្រះមហាក្សត្រិយ៍ពុំទ្រង់ចូលខាងគណៈបក្សណាមួយទេ ព្រោះព្រះអង្គជាប្រមុខនៃខេមរជនរាល់រូប

ទ្រង់ព្រះមេត្តាប្រោសដល់ប្រជានុរាស្ត្រពល់គ្នា មិនថាជាពួកខាងគណៈបក្សណា ៗ ពាក្យថា “ អង្គព្រះមហាក្សត្រិយ៍” ដែលមានប្រើក្នុងមាត្រានេះ សំដៅយកព្រះមហាក្សត្រិយ៍ក្នុងឋានៈដែលទ្រង់ជាមនុស្សមួយរូប គឺថាពុំមែនក្នុងឋានៈដែលទ្រង់ជាអគ្គប្រមុខនៃរដ្ឋទេ ៗ ក្នុងឋានៈដែលទ្រង់ជាមនុស្សមួយរូប ព្រះមហាក្សត្រិយ៍អាចទ្រង់សព្វព្រះរាជហឫទ័យនឹងគណៈបក្សណាមួយជាងគណៈបក្សឯទៀត ប៉ុន្តែបើព្រះមហាក្សត្រិយ៍ទ្រង់ប្រតិបត្តិព្រះរាជកិច្ច ជាអ្នកកណ្ដាលហើយ ក៏រាប់បានថាទ្រង់ប្រព្រឹត្តត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ៗ

៣- នរណានឹងល្មើសអង្គព្រះមហាក្សត្រិយ៍ពុំបាន ៗ ដោយហេតុដូច្នេះ ទើបមានជាបញ្ញត្តិហើយនឹងទំនៀមដូចតទៅនេះ៖

រដ្ឋធម្មនុញ្ញក្នុងមាត្រា៩៧នឹង៩៨ហាមមិនឲ្យកែប្រែសណ្ឋាននៃរដ្ឋខ្មែរដែលមានព្រះមហាក្សត្រិយ៍ជាប្រមុខ ឲ្យទៅជាសាធារណ-រដ្ឋ ហើយហាមមិនឲ្យបន្ថយព្រះរាជសិទ្ធិនៃព្រះមហាក្សត្រិយ៍ ៗ ក្នុងរដ្ឋសភា ប្រធានត្រូវហាមមិនឲ្យមានការពិភាក្សា ដែលនាំឲ្យអាប់ព្រះយសដល់ព្រះមហាក្សត្រិយ៍ ៗ

សាលាតុលាការមិនទទួលពាក្យប្ដឹង ដែលចោទប្រកាន់ព្រះមហាក្សត្រិយ៍ ព្រោះអ្នករងទុក្ខត្រូវប្ដឹងយកបុគ្គលដែលទទួលខុសត្រូវ



ជួសព្រះអង្គជាដរាប ៗ នៅប្រទេសអង់គ្លេសដែលគេតាំងជាគោលការណ៍ថា “ព្រះមហាក្សត្រិយ៍មិនអាចទ្រង់ប្រព្រឹត្តខុស,, បើទោះបីព្រះមហាក្សត្រិយ៍ទ្រង់សម្លាប់ជនណាដោយព្រះអង្គឯងក៏ដោយ គេក៏មិនរាប់ថាទ្រង់ប្រព្រឹត្តខុសដែរ, តាមច្បាប់អង់គ្លេសមានឧទាហរណ៍ថា បើព្រះមហាក្សត្រិយ៍ទ្រង់សម្លាប់រដ្ឋមន្ត្រី ម្នាក់ដោយព្រះហស្តព្រះអង្គឯង ខាងណាស់គេគ្រាន់តែយកទោសនាយករដ្ឋមន្ត្រីប៉ុណ្ណឹង ៗ តែបើព្រះមហាក្សត្រិយទ្រង់សម្លាប់នាយករដ្ឋមន្ត្រីនោះ គ្មាននរណាទទួលទោសឡើយ ៗ ដូច្នេះព្រះមហាក្សត្រិយ៍ ទ្រង់គង់ជាអម្ចាស់ជីវិតលើត្បូងដដែល ៗ ប៉ុន្តែក្នុងប្រទេសអង់គ្លេសគេមិនដែលឃើញមានព្រះមហាក្សត្រិយ៍អង្គណាមួយទេ ដែលទ្រង់ប្រព្រឹត្តឃាតកម្មដូច្នេះ ទាំងនេះក៏ព្រោះថាបើគេមិនអាចផ្ដន្ទាទោសព្រះមហាក្សត្រិយ៍តាមផ្លូវច្បាប់បានក៏មែនពិតហើយ តែនៅផ្លូវសង្គមមួយទៀត ៗ គឺថាបើព្រះមហាក្សត្រិយ៍អង្គណាទ្រង់ប្រព្រឹត្តដូច្នេះ ហើយប្រជាជនក៏នឹងអស់សេចក្ដីកក្ដីស្នេហាចំពោះព្រះអង្គ ៗ ព្រះមហាក្សត្រិយ៍អង្គនោះនឹងអស់ជាទីគោរពសក្ការៈនៃប្រជាជនទាំងពួង ហើយក៏ពុំអាចនឹងគង់ក្នុងរាជសម្បត្តិតទៅបានឡើយ ៗ នេះជាហេតុមួយដែលនាំ

ឲ្យព្រះមហាក្សត្រិយ៍ក្នុងរបៀបប្រជាធិបតេយ្យ ទ្រង់ប្រកបដោយទសពិធរាជធម៌ជាដរាប ។

មាត្រា ៣៦ ។ ព្រះមហាក្សត្រិយ៍ទ្រង់ប្រកាសឲ្យប្រើច្បាប់ទាំងឡាយតាមមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនេះ ។

ក្នុងរយៈវេលាដែលមានកំណត់សម្រាប់ការប្រកាសឲ្យប្រើនេះ ព្រះមហាក្សត្រិយ៍អាចផ្ញើព្រះរាជសារទៅឲ្យរដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ពិចារណាច្បាប់នោះជាថ្មីទៀត ឯរដ្ឋសភានិងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវតែព្រមតាមព្រះរាជឱង្ការ ។

សេចក្តីអធិប្បាយ ៖– តាមមាត្រា៧៨ កាលបើរដ្ឋសភាពិចារណាពិភាក្សាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ណាមួយ ហើយបញ្ចេញមតិឲ្យអនុម័តហើយ ត្រូវបញ្ជូនទៅក្រុមប្រឹក្សា ព្រះរាជអាណាចក្រ ឲ្យពិនិត្យផង ។ ក្រុមប្រឹក្សាព្រះរាជអាណាចក្រឲ្យសេចក្តីយល់ថាដូចម្តេច ក្នុងរយៈវេលា ១ ខែបើជាការធម្មតា ឬ៥-ថ្ងៃបើជាការប្រញាប់ ។

ច្បាប់ណាដែលរដ្ឋសភាបញ្ចេញមតិតាំងឡើង ហើយដែលក្រុមប្រឹក្សាព្រះរាជអាណាចក្រឲ្យយោបល់ព្រមផង ឬពុំបានឲ្យយោ-បល់ថាដូចម្តេចទេ ក្នុងរយៈវេលាខាងលើនេះ ច្បាប់នោះត្រូវនាំទៅក្រាបថ្វាយព្រះមហាក្សត្រិយ៍ ដើម្បីទ្រង់ព្រះមេត្តាប្រោស



ប្រកាសឲ្យប្រើក្នុងរយៈវេលា ១០ថ្ងៃបើជាការធម្មតា ឬ២ថ្ងៃបើជាការប្រញាប់ ។

ដើម្បីទ្រង់ប្រកាសឲ្យប្រើច្បាប់នោះ ព្រះមហាក្សត្រិយ៍ទ្រង់ចេញព្រះរាជក្រឹត្យប្រាប់អាណាប្រជានុរាស្ត្រជាឡាក់ហានថា រដ្ឋសភាបានបញ្ចេញមតិតាំងច្បាប់នោះហើយ ក្រុមប្រឹក្សាព្រះរាជអាណាច-ក្រពុំបានយល់ទាស់ទេ ។ ទើបទ្រង់មានព្រះបរមរាជឱង្ការឲ្យប្រតិបត្តិតាម ។

ច្បាប់ណាដែលពុំទាន់ទ្រង់ព្រះមេត្តាប្រោសប្រកាសឲ្យប្រើទេ នឹងទុកជាច្បាប់គ្រប់លក្ខណៈពុំបាន ច្បាប់នោះអាចត្រូវសើរើឡើងវិញ ព្រោះក្នុងរយៈវេលា១០ថ្ងៃ ឬ២ ថ្ងៃដូចពោលខាងលើនេះ ព្រះ-មហាក្សត្រិយ៍អាចទ្រង់ផ្ញើព្រះរាជសារទៅរដ្ឋសភា នឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ឲ្យពិនិត្យច្បាប់នោះជាថ្មីឡើងវិញ ។ អង្គការទាំងពីរនេះ ត្រូវតែទទួលពិនិត្យតាមព្រះបរមរាជឱង្ការ នឹងរើងទទឹងពុំបាន ។ ក្នុងការពិនិត្យជាថ្មីនេះ អាចត្រូវលុបចោលក៏មាន អាចត្រូវកែប្រែក៏មាន អាចនៅគង់រូបដដែលក៏សឹងមាន ។

មាត្រា ៣៧.– ព្រះមហាក្សត្រិយ៍ទ្រង់ប្រាស្រ័យនឹងរដ្ឋសភា ហើយនឹងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ដោយព្រះរាជសារ ។

សេចក្ដីអធិប្បាយ:– កាលបើព្រះមហាក្សត្រិយ៍មានព្រះបំណងឲ្យរដ្ឋសភាឬក្រុមប្រឹក្សាព្រះរាជអាណាចក្របានដឹងសេចក្ដីអ្វីមួយ នោះទ្រង់ព្រះមេត្តាប្រោសផ្ញើព្រះរាជសារទៅតាមរដ្ឋមន្ត្រីមួយរូបជាអ្នកអានព្រះរាជសារនោះក្នុងរដ្ឋសភា ឬក្នុងក្រុមប្រឹក្សាព្រះរាជអាណាចក្រ ។

មាត្រា ៣៨:– ព្រះមហាក្សត្រិយ៍ទ្រង់ហៅប្រជុំរដ្ឋសភា តាមបទបញ្ញត្តិនៃមាត្រា ៥៨ និង ៥៩ នៃរដ្ឋធម្មនុញ្ញនេះ ។ ព្រះអង្គទ្រង់នូវព្រះរាជសិទ្ធិរំលាយរដ្ឋសភាបាន តាមសេចក្ដីណែនាំនៃគណៈរដ្ឋមន្ត្រី ។ ព្រះមហាក្សត្រិយ៍ទ្រង់រំលាយរដ្ឋសភាបាន តែមួយដងដោយហេតុនិងផល ។ បើមានការរំលាយរដ្ឋសភាដូចខាងលើនេះ ការជ្រើសតាំងជាថ្មីត្រូវឲ្យមានក្នុងរយៈវេលាពីរខែយ៉ាងយូរ ។

សេចក្ដីអធិប្បាយ:– ការណ៍ដែលព្រះមហាក្សត្រិយ៍ទ្រង់ត្រាស់ហៅប្រជុំរដ្ឋសភា យើងនឹងអធិប្បាយក្នុងឱកាសក្រោយ កាលយើងនឹងអធិប្បាយដល់មាត្រា ៥៨ ។

គណៈរដ្ឋមន្ត្រី ( គឺរដ្ឋាភិបាល ) ដែលកាន់អំណាចនីតិប្រតិបត្តិ នឹងរដ្ឋសភាដែលកាន់អំណាចនីតិបញ្ញត្តិ ត្រូវមានគំនិតស្របគ្នា ដើម្បី



ព្រួតដៃប្រតិបត្តិការផែនដីជាដរាប ។ កាលបើទាស់ទែងខ្វែងគំនិតគ្នា រវាងអង្គការទាំងពីរនេះ ត្រូវតែអង្គការមួយរលំរលាយទៅ ហើយតាំងជាថ្មី ដើម្បីឲ្យបានស្របគំនិតគ្នានឹងអង្គការមួយទៀតដែលគង់នៅ ។ តាមធម្មតា អង្គការដែលរលំរលាយទៅនោះ ច្រើនតែជារដ្ឋាភិបាល ( គឺគណៈរដ្ឋមន្ត្រី ) ។

ប៉ុន្តែ ចួនកាលរដ្ឋសភាក៏អាចត្រូវរំលាយដែរ គឺក្នុងករណីខ្លះ ដូចជាក្នុងករណី ដែលរដ្ឋសភាចេះតែរំលំរដ្ឋាភិបាលញឹកញយពេក ឥតសមហេតុសមផល ឬក្នុងករណីដែលអ្នកតំណាងរាស្ត្រក្នុងរដ្ឋសភាបែកគ្នាជាច្រើនគណៈបក្ស គ្មានគណៈបក្សណាមួយមានគ្នាលើសពីពាក់កណ្ដាល នៃចំនួនអ្នកតំណាងរាស្ត្រទាំងអស់ ។ ក្នុងករណីដូច្នេះ គណៈបក្សពីរឬបីត្រូវរួបរួមគ្នា ទើបបានជាភាគច្រើនល្មមទ្រទ្រង់រដ្ឋាភិបាលបាន ។ កាលបើគណៈបក្សមួយបែកចេញពីភាគច្រើន ទៅចូលនឹងគណៈបក្សឯទៀត ដែលជាភាគតិច ភាគច្រើនក៏ត្រឡប់ទៅជាភាគតិច ភាគតិចក៏ត្រឡប់ទៅជាភាគច្រើនវិញ ។ រដ្ឋាភិបាលក៏តាំងនៅមិនរឹងជំហរ ចេះតែរលំជាញឹកញយ នាំឲ្យកិច្ចការផែនដីប្រែប្រួលច្របល់រកចំរើនមិនរួច ។

បើមានហេតុការណ៍យ៉ាងនេះកើតឡើង រដ្ឋាភិបាលអាចក្រាបទូលព្រះមហាក្សត្រិយ៍ សូមឲ្យទ្រង់រំលាយរដ្ឋសភា នោះព្រះមហាក្សត្រិយ៍ អាចទ្រង់ព្រះមេត្តាប្រោសរំលាយរដ្ឋសភាតាមសេចក្ដីសុំ ឬសេចក្ដីណែនាំនៃរដ្ឋាភិបាល ។

អ្នកខ្លះអាចយល់ថាការរំលាយរដ្ឋសភា ជាទំនាស់នឹងលទ្ធិប្រជាធិបតេយ្យ ព្រោះរដ្ឋសភាគឺប្រជារាស្ត្របានជ្រើសតាំងដោយបោះឆ្នោតសាកល ទុកជាទីតំណាងប្រជារាស្ត្រទាំងមូល ។ សេចក្ដីពិត ការរំលាយរដ្ឋសភាជាការគោរពដល់ទឹកចិត្តប្រជារាស្ត្រ ព្រោះកាលរំលាយរដ្ឋសភាហើយ ត្រូវឲ្យប្រជារាស្ត្រជ្រើសតាំងអ្នកតំណាងរាស្ត្រថ្មីឲ្យស្រេចក្នុងរយៈវេលាពីរខែ ។ ដូច្នេះការរំលាយរដ្ឋសភាជាការនាំរឿងវិវាទរវាងរដ្ឋសភានឹងរដ្ឋាភិបាល ទៅឲ្យប្រជារាស្ត្រអាគាត់សេចក្ដី ។ បើប្រជារាស្ត្រជ្រើសតាំងអ្នកតំណាងរាស្ត្រក្នុងគណៈបក្សដែលទាស់នឹងរដ្ឋាភិបាល បានចំនួនប្រហែលពីមុន ឬច្រើនលើសមុន នោះប្រែសេចក្ដីថាប្រជារាស្ត្រឲ្យខុសទៅខាងរដ្ឋាភិបាល ។ រដ្ឋាភិបាលត្រូវរលំទៅ រដ្ឋធម្មនុញ្ញហាមមិនឲ្យរំលាយរដ្ឋសភាម្ដងទៀតក្នុងការវិវាទដដែលនេះទេ ។ បើប្រជារាស្ត្រជ្រើសតាំងអ្នកតំណាងរាស្ត្រពួកខាងរដ្ឋាភិបាល បានឡើងជាភាគ



ច្រើនក្នុងរដ្ឋសភា នោះប្រែសេចក្ដីថា ប្រជារាស្ត្រឲ្យត្រូវទៅខាងរដ្ឋាភិបាល ។ រដ្ឋាភិបាលក៏នឹងគង់នៅក្នុងតំណែងតទៅទៀត ។

ព្រះរាជសិទ្ធិត្រង់រំលាយរដ្ឋសភានេះនាំឲ្យការផែនដីមានតុល្យភាពល្អ ។ រដ្ឋសភានឹងរដ្ឋាភិបាលមានអាវុធស្មើកម្លាំងគ្នា ។ អ្នកតំណាងរាស្ត្រ មុននឹងរំលំរដ្ឋាភិបាល តោងសំឡឹងដល់ចិត្តរាស្ត្រ ។ បើរលំទៅសមនឹងចិត្តរាស្ត្រទើបហ៊ានរលំ ។ បើមើលទៅឃើញថាប្រហែលមិនសមនឹងចិត្តរាស្ត្រទេ រដ្ឋាភិបាលអាចសុំព្រះមហាក្សត្រិយ៍ឲ្យទ្រង់រំលាយរដ្ឋសភា ។ អ្នកតំណាងរាស្ត្រក៏នឹងពិបាកបង់កំឡាំងបង់ធនធាន ធ្វើការឃោសនាជាថ្មី ហើយប្រហែលជារាស្ត្រមិនបោះឆ្នោតឲ្យខ្លួនទេបើខ្លួនខុស ។ ឯរដ្ឋាភិបាលក៏ដែរ បើមិនជាក់ចិត្តថាប្រជារាស្ត្រនឹងឲ្យខ្លួនត្រូវទេ ក៏មិនហ៊ានសុំរំលាយស៊ូលាងារឈប់វិញល្អជាង ព្រោះបើបោះឆ្នោតជាថ្មីប្រជារាស្ត្រឲ្យខ្លួនខុស ក៏នឹងអាប់មុខយ៉ាងខ្លាំង ។

រឿងនេះនឹងមានបរិយាយតទៅទៀត កាលយើងអធិប្បាយដល់មាត្រា៦៩នឹង៩០ ។

មាត្រា ៣៩.- ព្រះមហាក្សត្រិយ៍ទ្រង់ជ្រើសយកនាយករដ្ឋមន្ត្រី ហើយទ្រង់តែងតាំងនាយករដ្ឋមន្ត្រី ព្រមទាំងរដ្ឋមន្ត្រីដែលនាយកនោះក្រាបបង្គំទូលសុំឲ្យតាំង។

សេចក្តីអធិប្បាយ.- ការជ្រើសយកនាយករដ្ឋមន្ត្រី ការតែងតាំងនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីឯទៀត ព្រះមហាក្សត្រិយ៍ទ្រង់ប្រព្រឹត្តដោយមើលទៅតដល់ចិត្តអាណាប្រជានុរាស្ត្រក្រោមល្អងធូលីព្រះបាទឲ្យបានសមល្មមនឹងមតិមហាជន ដូចមានសេចក្តីពិស្តារក្នុងមាត្រា៨០ នៃរដ្ឋធម្មនុញ្ញនេះដែលយើងនឹងអធិប្បាយតទៅខាងមុខ។

មាត្រា ៤០.- ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិជាអធិបតីទីប្រជុំគណៈរដ្ឋមន្ត្រី ។ សេចក្តីកត់ហេតុទាំងឡាយនៃពេលប្រជុំគណៈរដ្ឋមន្ត្រី ត្រូវនាំយកទៅក្រាបបង្គំថ្វាយព្រះមហាក្សត្រិយ៍ ។

សេចក្តីអធិប្បាយ.-គណៈរដ្ឋមន្ត្រីត្រូវប្រជុំរាល់សប្តាហ៍ (រាល់អាទិត្យ) តាមបទបញ្ញត្តិនៃមាត្រា៨៦ ។ ព្រះមហាក្សត្រិយ៍ទ្រង់នូវព្រះរាជសិទ្ធិស្តេចយាងមករួមប្រជុំផងជាព្រះរាជាធិបតី តែគ្រាន់តែជាព្រះរាជសិទ្ធិទេ គឺថាបើពុំស្តេចយាងមកប្រជុំក៏បានដែរ ។ បើទោះស្តេចយាងមកក្តី ពុំស្តេចយាងមកក្តី សេចក្តីកត់ហេតុនៃពេលប្រជុំ (គឺលិខិតដែលមានចុះទុកនូវរឿងរ៉ាវគ្រប់យ៉ាងដែលរដ្ឋ



មន្ត្រីទាំងឡាយបានពិនិត្យពិចារណាពិភាក្សាក្នុងទីប្រជុំនីមួយៗ) ត្រូវនាំយកទៅក្រាបបង្គំថ្វាយព្រះមហាក្សត្រិយ៍ ដើម្បីទ្រង់ជ្រាបកិច្ចការផែនដីជាដរាប ។

យើងធ្លាប់ពោលមកថាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ព្រះមេត្តាប្រោសលែងទ្រង់ប្រើព្រះតេជះ គឺអំណាចអធិបតេយ្យដោយផ្ទាល់ព្រះអង្គដូចមុនទៀតហើយ ព្រះអង្គបានទ្រង់ប្រគល់អំណាចនោះ ដែលចែកជាអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ អំណាចតុលាការ ឲ្យទៅអង្គការផ្សេងៗ របស់ប្រជារាស្ត្រ ឲ្យបានសមនឹងកាលសម័យ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីថ្កុំថ្កើងរបស់ជាតិ ។ ប្រដូចជាមាតាបិតាកាលឃើញបុត្រទាំងឡាយធំខ្លួនដឹងសេចក្តីខុសត្រូវល្មមហើយ ក៏លែងប្រើអំណាចលើបុត្រដូចកាលបុត្រនៅក្នុងវ័យក្មេងខ្លីសេចក្តីនៅឡើយ តែនៅស្រឡាញ់បុត្រអាណិតអាសូរជួយដាស់តឿនជាប្រក្រតី ។ ឯព្រះមហាក្សត្រិយ៍ក៏ដូច្នោះដែរ ពុំទ្រង់ប្រើព្រះតេជះទៀតទេ តែទ្រង់នូវព្រះគុណលើអាណាប្រជានុរាស្ត្រជាដរាប ។ គឺដោយហេតុនេះហើយទើបត្រូវនាំសេចក្តីកត់ហេតុ នៃពេលប្រជុំគណៈរដ្ឋមន្ត្រី ទៅក្រាបបង្គំថ្វាយ ដើម្បីទ្រង់ព្រះមេត្តាប្រោសជួយណែនាំ ជួយដាស់តឿន ដូចកាន់ការផែនដី